**របាយការណ៍**

**ស្តីពី**

**លទ្ធផលការងារវប្បធម៌ និង វិចិត្រសិល្បៈប្រចាំឆ្នាំ២០១១**

**៙៙៙៚៚**

I.**សេចក្តីផ្តើម :**

អនុវត្តតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និង **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២** សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ជាពិសេសអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ក្នុងពិធីប្រារព្ធទិវាវប្បធម៌ជាតិ ៣ មីនា លើកទី១៣ ឆ្នាំ២០១១ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីប្រចាំការ** ក្នុងឱកាសបិទសន្និបាតបូកសរុបការងារវប្បធម៌ឆ្នាំ២០១០ និងលើកផែនការឆ្នាំ២០១១ គឺជាវិធានការគន្លឹះប្រកបដោយខ្លឹមសារ និងជាគោលការណ៍ធានានូវប្រសិទ្ធភាពខ្ពស់បំផុត សម្រាប់ទិសដៅបំពេញភារកិច្ចរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

រយៈពេលមួយឆ្នាំនេះ គ្រប់អង្គភាពចំណុះក្រសួង បានខិតខំប្រឹងប្រែងបង្កើនកិច្ចសហការជាមួយអន្តរក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍជាតិ-អន្តរជាតិ ជាពិសេសវិស័យឯកជនតាមគោលការណ៍របស់រាជរដ្ឋាភិបាលគឺ **រដ្ឋគាំទ្រ ដៃគូឯកជនជាអ្នកអនុវត្ត** ស្របតាមគោលនយោបាយ " **អភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ** " ក្នុងគោលបំណងធ្វើឱ្យ " **វប្បធម៌ក្លាយជាសេដ្ឋកិច្ចជាតិ** " ដោយជម្រុញបន្ថែមនូវការប្រើប្រាស់សក្តានុពលវប្បធម៌ខ្មែរជាថាមពលអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការពង្រឹងការបង្កបង្កើនផលិតផលឧស្សាហកម្មវប្បធម៌សម្រាប់គោលដៅពាណិជ្ជកម្ម និងទេសចរណ៍ ដោយបង្កើតការងារពង្រឹងសីលធម៌ និងរបៀបរស់នៅថ្លៃថ្នូរ ធ្វើឱ្យខ្មែរមានគំនិតបង្កបង្កើត និងបង្កើនទិន្នាការស្នេហាវប្បធម៌ជាតិ រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ធ្វើឱ្យសង្គមទទួលបាននូវសុខដុមរមនា ដើម្បីឈានទៅសម្រេចគោលដៅ " **កម្ពុជា : ព្រះរាជាណាចក្រនៃវប្បធម៌** " ។

II.**រចនាសម្ព័ន្ធ និងក្របខណ្ឌ :**

**១.<u>រចនាសម្ព័ន្ធ</u> :**

**ក-ថ្នាក់ដឹកនាំក្រសួង ៖**

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដឹកនាំដោយ **រដ្ឋមន្ត្រី១រូប** អមដោយ**រដ្ឋលេខាធិការ៨រូប** និង**អនុរដ្ឋលេខាធិការ៩រូប។**

**ខ-ថ្នាក់រដ្ឋបាលកណ្តាល ៖**

ថ្នាក់រដ្ឋបាលកណ្តាល ក្រសួងមានអគ្គនាយកដ្ឋានចំនួន ០៣ ៖

**-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មាននាយកដ្ឋានចំនួន០៩** (នា.រដ្ឋបាល នា.ផែនការ ស្ថិតិ និងសរុប នា.បុគ្គលិក នា.គណនេយ្យ ហិរញ្ញវត្ថុ នា.សំភារៈ និងបរិក្ខារ នា.នីតិកម្ម នា.សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នា.សហប្រតិបត្តិការវប្បធម៌អន្តរជាតិ និងកិច្ចការអាស៊ាន សាលាបណ្តុះបណ្តាលក្របខណ្ឌវប្បធម៌)

**-អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌មាន នាយកដ្ឋានចំនួន០៥** (នា.អភិវឌ្ឍវប្បធម៌ នា.សៀវភៅការអាន នា.សិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ នា.សិល្បៈទស្សនីយភាព នា.សិល្បៈសូនរូប និងសិល្បៈសិប្បកម្ម)

**-អគ្គនាយកដ្ឋានបេតិកភណ្ឌ មាននាយកដ្ឋានចំនួន០៤** (នា.បុរាណវត្ថុ នា.សារមន្ទីរ នា.បុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា នា.គាំពារ និងអភិរក្សសំណង់បុរាណ) ។

ក្រៅពីនេះនៅមានអង្គភាពចំនួន ០៤ទៀត ដែលស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ឯកឧត្តមរដ្ឋមន្ត្រី ៖

**-សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈដែលជាគ្រឹះស្ថានសាធារណៈ ថ្នាក់ស្មើអគ្គនាយកដ្ឋាន** មានមហាវិទ្យាល័យចំនួន០៥ (មហា.បុរាណវិទ្យា មហា.ស្ថាបត្យកម្ម នគរូបនីយកម្ម និងសំណង់ មហា.សិល្បៈសូនរូប មហា.តូរ្យតន្ត្រី មហា.នាដសាស្ត្រ) និង មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ១ (ថ្នាក់ស្មើនាយកដ្ឋាន)

**-នាយកដ្ឋានសវនកម្មផ្ទៃក្នុង**

**-អធិការដ្ឋាន** ថ្នាក់ស្មើនាយកដ្ឋាន

**-សាលាមធ្យមវិចិត្រសិល្បៈ** ថ្នាក់ស្មើនាយកដ្ឋាន មានសាលាជំនាញចំនួន ០៥ ( សាលារបាំ សាលាសៀក សាលាសិល្បៈសូនរូប សាលាតូរ្យតន្ត្រី សាលាល្ខោន) ។

**គ-ថ្នាក់រាជធានី-ខេត្ត ៖**

ក្រសួងមានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ចំនួន២៤មន្ទីរ និងការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈក្រុង ខណ្ឌ ស្រុក ចំនួន១៦៦ការិយាល័យ ។

**២.ក្របខ័ណ្ឌមន្ត្រីរាជការ** សរុបទូទាំងក្រសួងមានចំនួន**២.៩៧៦នាក់** ក្នុងនោះស្រី**៨៨៧នាក់** ចែកចេញជា **៖-**

-ថ្នាក់រដ្ឋបាលកណ្តាល មានមន្ត្រីរាជការសរុប**១.៩០២នាក់** ក្នុងនោះស្រី**៩៤៦នាក់**

-ថ្នាក់មន្ទីរវប្បធម៌រាជធានី-ខេត្ត មានមន្ត្រីរាជការសរុប**១.០៧៤នាក់** ក្នុងនោះស្រី**៣៤១នាក់** ។

III.**សកម្មភាពការងារថ្នាក់ដឹកនាំក្រសួង ៖**

រយៈពេលមួយឆ្នាំនេះ ថ្នាក់ដឹកនាំក្រសួងបានទទួលជួបពិភាក្សាការងារក្នុងកិច្ចអភិរក្ស អភិវឌ្ឍវិស័យវប្បធម៌ និងអភិវឌ្ឍធនធានមនុស្ស ជាមួយតំណាងស្ថានទូត ភ្ញៀវជាតិ-អន្តរជាតិ អង្គការសមាគម និងចូលរួមសិក្ខាសាលា ប្រជុំនៅក្រៅក្រសួង

ចូលរួមអមដំណើរ**សម្តេចតេជោនាយករដ្ឋមន្ត្រី** និងចូលរួមជាកិត្តិយសក្នុងសកម្មភាពបំរើព្រឹត្តិការណ៍ជាតិ-អន្តរជាតិសរុបមានចំនួន៧៨លើក ។ ថ្នាក់ដឹកនាំក្រសួងក៏បានចេញបំពេញបេសកកម្មនៅក្រៅប្រទេសមានចំនួន១៣លើក ។

IV. **លទ្ធផលការងារ :**

**១. ការងារបំរើព្រឹត្តិការណ៍សំខាន់ៗ :**

នៅថ្ងៃទី២៥-២៦-២៧ ខែមករា ឆ្នាំ២០១១ នៅសបាសាល ក្រសួងបានរៀបចំសន្និបាតបូកសរុបការងារវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១០ និងលើកផែនការសកម្មភាពការងារឆ្នាំ២០១១ ក្រោមអធិបតីភាព **ឯកឧត្តមរដ្ឋមន្ត្រី**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអញ្ជើញចូលរួមបិទអង្គសន្និបាតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីប្រចាំការ** ។ អញ្ជើញចូលរួមក្នុងអង្គសន្និបាតមានឯកឧត្តមតំណាងក្រសួង ស្ថាប័ននានា អង្គការយូណេស្កូ អភិបាលរងរាជធានី-ខេត្ត ថ្នាក់ដឹកនាំក្រសួង មន្ត្រីវប្បធម៌ថ្នាក់រដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ការិយាល័យឡើង និងប្រធាន-អនុប្រធានមន្ទីរវប្បធម៌ថ្នាក់រាជធានី-ខេត្ត សរុបមានចំនួន **៣០០នាក់**។

នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១១ នៅសាលសន្និសីទចតុមុខ ក្រសួងបានរៀបចំបើកមហោស្រពសិល្បៈមហាជនក្រោមអធិបតីភាព **ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** ។ អញ្ជើញចូលរួមក្នុងអង្គពិធីមានឯកឧត្តមតំណាងក្រសួង ស្ថាប័ននានា ថ្នាក់ដឹកនាំក្រសួង មន្ត្រីវប្បធម៌ថ្នាក់រដ្ឋបាលកណ្តាល មន្ត្រីវប្បធម៌ថ្នាក់មន្ទីររាជធានី-ខេត្ត និងសិល្បករ សិល្បការិនី សរុបមានចំនួន **៧០០នាក់**។

ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១១ ឯកឧត្តមរដ្ឋមន្ត្រី ដឹកនាំប្រតិភូមួយក្រុមចុះសួរសុខទុក្ខកងកម្លាំងនគរបាលកងវរៈសេនាតូចលេខ៧៩៥ និងកងវរៈសេនាតូចលេខ៩០៥ ដោយបាននាំយកគ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួន ឧបត្ថម្ភដល់កងកម្លាំងដែលកំពុងឈរជើង នៅទល់ដែនតំបន់ប្រាសាទព្រះវិហារ ។

ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ៨ : ០០នាទី នៅសាលសន្និសីទចតុមុខ បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ៣មីនា លើកទី១៣ ឆ្នាំ២០១១ ក្រោមប្រធានបទ : " **អ្វីៗទាំងអស់ដើម្បីសុវត្ថិភាពវប្បធម៌** " និងពិធីបិទមហោស្រពសិល្បៈមហាជនទូទាំងប្រទេស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងលោកជំទាវ**។ អញ្ជើញចូលរួមក្នុងឱកាសនោះមានថ្នាក់ដឹកនាំជាន់ខ្ពស់បណ្តាក្រសួង ស្ថាប័ន ភ្ញៀវជាតិ-អន្តរជាតិ ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងសិល្បករ សិល្បការិនី សរុបចំនួន៨០០នាក់។ ការប្រារព្ធពិធីបានប្រព្រឹត្តទៅតាមកម្មវិធីដែលបានបានគ្រោងទុក និងបានលើកយកស្នាដៃរឿងដែលទទួលបានចំណាត់ថ្នាក់ពានមាស មកសម្តែងនូវឃ្លោតឆាកខ្លះនៃរឿងនីមួយៗជូនគណៈអធិបតី និងសមាជិក សមាជិកាអង្គពិធីទស្សនា។ បន្ទាប់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ថ្លែងសុន្ទរកថាបិទអង្គពិធីរួចមក ពិធីប្រគល់ពានរង្វាន់ជ័យលាភី ដល់ក្រុមសិល្បៈក៏បានទទួលពី **សម្តេចតេជោ និងលោកជំទាវ** មានដូចតទៅ :

១-ទទួលពានមាស ចំនួន៥ក្រុម ក្នុងនោះមានល្ខោនបាសាក់២រឿង-ល្ខោនយីកេ១រឿង-ល្ខោនបើកបទ១រឿង និងល្ខោនសៀក១រឿង ។

២-ទទួលពានប្រាក់ ចំនួន២៩ក្រុម ក្នុងនោះមានល្ខោនបាសាក់៧រឿង-ល្ខោនយីកេ២រឿង-ល្ខោនក្បាច់១រឿង-ល្ខោនខោល២រឿង-ឆាកកំប្លែង៤រឿង-ល្ខោននិយាយ១រឿង-របាំប្រពៃណី១១របាំ និងអាយ៉ៃរឿង១រឿង ។

៣-ទទួលពានសិរិទ្ធ ចំនួន១៤ក្រុម ក្នុងនោះមាន ល្ខោនបាសាក់៤រឿង-ល្ខោនបើកបទ១រឿង-ល្ខោននិយាយ២រឿង អាយ៉ៃរឿង៤រឿង-របាំប្រពៃណី១របាំ និងឆាកកំប្លែង២រឿង ។

ក្រសួងបានសហការរៀបចំបើកមហោស្រពចម្រៀងខ្មែរជាសកលលើកទី២ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ដែលមានសិល្បករឆ្លងកាត់ការជម្រុះ ចម្រាញ់ជម្រើសមកពីរាជធានី-ខេត្តទាំង២៤ និងសិល្បករអាណិកជនខ្មែរមកពីបរទេសចូលរួម ដោយមានកម្មវិធីប្រឡងដូចតទៅ :

-ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង១៥: ០០នាទី រៀបចំប្រឡងជម្រុះ ក្រោមអធិបតីភាព **ឯកឧត្តម រដ្ឋមន្ត្រី** ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង១៥:០០នាទី ប្រារព្ធពិធីបើកមហោស្រព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

-ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង១៥: ០០នាទី ប្រារព្ធពិធីបិទមហោស្រព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ។**
ជាលទ្ធផល មហោស្រពចម្រៀងយើងទទួលបានបេក្ខជនចម្រៀងសម័យ-បុរាណចូលរួមវគ្គជម្រុះមកពីរាជធានី-ខេត្ត សរុបចំនួន៩៣នាក់ក្នុងនោះមានចម្រៀងសម័យ៤៨នាក់( ស្រី២៤នាក់) ។ បេក្ខជនមកពីក្រៅប្រទេសចំនួន៦ប្រទេសមាន: សហរដ្ឋអាមេរិក ៥នាក់( ស្រី២នាក់) ចម្រៀងសម័យទាំងអស់-ប្រទេសបារាំង៤នាក់( ស្រី២នាក់) ក្នុងនោះចម្រៀងបុរាណ១នាក់-ប្រទេសកាណាដា ៣នាក់( ស្រី១នាក់) ចម្រៀងសម័យទាំងអស់-ប្រទេសជប៉ុន១នាក់ចម្រៀងសម័យ-ប្រទេសហូឡង់១នាក់ចម្រៀងសម័យ និងប្រទេសអូស្ត្រាលី០២នាក់( ស្រី១នាក់) ចម្រៀងសម័យទាំងអស់។ លទ្ធផលប្រឡងជាប់វគ្គផ្តាច់ព្រ័ត្រ ទទួលបានបេក្ខជនសរុប ២០នាក់ ក្នុងនោះស្រី១០នាក់មាន :

***ផ្នែកចម្រៀងបុរាណ** ប្រុស៥នាក់ ស្រី៥នាក់: បេក្ខជនលេខ១មកពីខេត្តសៀមរាប-លេខ២ខេត្តបាត់ដំបង លេខ៣ខេត្តកំពង់ស្ពឺ-លេខ៤ខេត្តកំពត និងលេខ៥ខេត្តកោះកុង។ បេក្ខនារីលេខ១មកពីខេត្តកណ្តាល-លេខ២រាជធានីភ្នំពេញ លេខ៣ខេត្តក្រចេះ-លេខ៤ខេត្តឧត្តរមានជ័យ និងលេខ៥ខេត្តកំពង់ឆ្នាំង ។

***ផ្នែកចម្រៀងសម័យ** ប្រុស៥នាក់ ស្រី៥នាក់: បេក្ខជនលេខ១មកពីខេត្តកំពង់ធំ-លេខ២ខេត្តកំពង់ស្ពឺ-លេខ៣ ខេត្តឧត្តរមានជ័យ-លេខ៤ប្រទេសកាណាដា និងលេខ៥ខេត្តសៀមរាប។ បេក្ខនារីលេខ១មកពីខេត្តតាកែវ-លេខ២ ខេត្តកំពង់ស្ពឺ-លេខ៣ខេត្តបាត់ដំបង-លេខ៤សហរដ្ឋអាមេរិក និងលេខ៥ប្រទេសអូស្ត្រាលី ។

ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង១៥ :៣០នាទី នៅទីស្តីការក្រសួង គណៈកម្មការអន្តរក្រសួងបង្ក្រាបបទល្មើសភាពយន្ត-វីដេអូ បានរៀបចំប្រារព្ធពិធីកិនកំទេចថាស និងម៉ាស៊ីនថតចម្លងខុសច្បាប់ ក្រោមអធិបតីភាព ឯកឧត្តម ហ៊ឹម ឆែម រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយមានការចូលរួមពី ឯកឧត្តម ឃឹម សារិទ្ធ រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានគណៈកម្មការអន្តរក្រសួង ឯកឧត្តមតំណាងអគ្គស្នងការនគរបាលជាតិ មន្ត្រីនគរបាលនាយកដ្ឋានសន្តិសុខ

ផ្ទៃក្នុង នៃក្រសួងមហាផ្ទៃ ឯកឧត្តមមេធាវីរាជរដ្ឋាភិបាល និងថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចូលរួមមានប្រមាណ១០០នាក់។ ថាសខុសច្បាស់ដែលធ្វើពិធីកិនកំទិចនេះ បានមកពីគណៈកម្មការអន្តរក្រសួង ចុះត្រួតពិនិត្យទីតាំងជួលលក់ថាសនៅតាមទីផ្សារនានា ព្រមទាំងចុះឆែកឆេរទីតាំងលួចចម្លងថាសខុសច្បាប់ក្នុងរាជធានី និងខេត្តមួយចំនួន ក្នុងនោះយើងប្រមូលបានមានៈ ថាសសរុបចំនួន**៥៦២.៤៧៧បន្ទះ**-រូបភាព និងវីដេអូអាសអាភាសចំនួន៣៥.៤៩៨ទិន្នន័យរឿង-កំព្យូទ័រចំនួន០៨គ្រឿង-ម៉ាស៊ីនថតចម្លងចំនួន០៩គ្រឿង-C-D ROOM ចំនួន១៣គ្រឿង ម៉ាស៊ីនព្រីនធើចំនួន០២គ្រឿង និងបានបញ្ជូនខ្លួនជនសង្ស័យចំនួន០៣នាក់ទៅតុលាការ។ ឆ្លងតាមលទ្ធផលការងារដែលសម្រេចបាន យើងអាចសន្និដ្ឋានបានថា ការដកហូតបរិមាណផលិតផលថាសថតចម្លងខុសច្បាប់មានការកើនឡើងជាង៥០ភាគរយ បើប្រៀបធៀបឆ្នាំ២០១០កន្លងទៅ។ សកម្មភាពបង្ក្រាបបទល្មើសភាពយន្ត-វីដេអូទាំងនៅក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តនានាក៏មានសកម្មភាពកើនឡើងជាងឆ្នាំកន្លងមក។ ដោយឡែកយើងសង្កេតឃើញថា សកម្មភាពបញ្ចាំងវីដេអូអាសអាភាស និងការជួលលក់ថាសអាសអាភាសវិញស្ទើរតែគ្មានសកម្មភាពនៅទូទាំងប្រទេស ក៏ប៉ុន្តែសកម្មភាពចែកចាយរូបភាពអាសអាភាស កំពុងរីកសាយតាមរយៈប្រព័ន្ធអ៊ិនធើណេតដែលគេអាច Download រឿងទាំងនោះបានយ៉ាងងាយស្រួល និងអាចចែកចាយបន្ត (Bluetooth) តាមប្រព័ន្ធទូរស័ព្ទ។

ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១១ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហការជាមួយស្ថានីយទូរទស្សន៍អាស៊ីអាគ្នេយ៍ ចាប់ផ្តើមបើកមហោស្រពរបាំប្រពៃណី និងរបាំសហសម័យខ្មែរ ដែលនឹងបិទនៅថ្ងៃទី០៤-០៦ ខែមេសា ឆ្នាំ២០១២ នៅស្ថានីយទូរទស្សន៍អាស៊ីអាគ្នេយ៍។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអង្គការ UNESCO បានរៀបចំសិក្ខាសាលា ស្តីពីការពិនិត្យ តាមដាន និងបន្តអនុវត្តការចុះបញ្ជីសារពើភណ្ឌសម្ភារៈសារមន្ទីរ នៅកម្ពុជា នៅសណ្ឋាគារភ្នំពេញ។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអង្គការ UNESCO បានបើកសិក្ខាសាលា ស្តីពីការពង្រឹងសមត្ថភាព ដើម្បីសមាហរណកម្មវប្បធម៌ទៅក្នុងនយោបាយអភិវឌ្ឍន៍ នៅសណ្ឋាគារ កាំបូឌីយ៉ាណា នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១។

ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ នៅនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ បានរៀបចំពិធីបើកការដ្ឋានសាងសង់រោងសៀក ជាអំណោយឥតសំណងរបស់ប្រទេសវៀតណាម។

បើកពិព័រណ៍សិប្បកម្មជនជាតិដើមភាគតិច រៀបចំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអង្គការUNDP តាមរយៈមូលនិធិ នៃរដ្ឋាភិបាលប្រទេសអេស្ប៉ាញ រៀបចំនៅសារមន្ទីរជាតិ នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអង្គការ UNESCO បានបើកកិច្ចប្រជុំអ្នកជំនាញថ្នាក់តំបន់នៃអនុសញ្ញា២០០៥ ស្តីពី "ការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ នៅសណ្ឋាគារកាំបូឌីយ៉ាណា ។

## ២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ :

### ២.១.ការងាររដ្ឋបាលទូទៅ :

-ទទួលលិខិតចូលចំនួន២.៦០៦ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣.០១២ច្បាប់។ សរសេរលិខិតឆ្លើយតបចំនួន៣២៧លិខិត និងតាក់តែងលិខិតបទដ្ឋានដូចជា សេចក្តីសម្រេច-សារាចរបាន៥៥លិខិត។ រៀបចំទុកដាក់ឯកសារចេញ ឯកសារចូលរបស់

ការិយាល័យបានល្អ និង ការងារជាវ ចែកចាយសៀវភៅរាជកិច្ចបានចំនួន១.៦១៧ក្បាល ស្មើ៤៩លេខ។ បានបង្ហោះក្នុងគេហទំព័រទាក់ទងសកម្មភាពវប្បធម៌២៣លើក និងបានផ្ទេរ Domain Name របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈឈ្មោះ mcfa.gov.kh ទៅបង្ហោះលើ DNS ដែលមានឈ្មោះ nsl_net.gov.kh.203.176.141.195 ns2_net.gov.kh.117.120.31.9 និងសហការជាមួយអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា ដើម្បីរៀបចំវេបសាយរបស់ក្រសួងឱ្យបានល្អប្រសើរ និងរៀបចំគម្រោងតបណ្តាញអ៊ីធើណេតតាមអាគារថ្មីក្នុងក្រសួង និងនាយកដ្ឋានឱ្យមានអ៊ីនធើណេតប្រើប្រាស់តាមតម្រូវការ ។

**២.២.ការងារបុគ្គលិក :**

នាយកដ្ឋានបានចុះផ្សព្វផ្សាយច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៅតាមមន្ទីរវប្បធម៌ខេត្តចំនួន០៩ខេត្តមាន : ខេត្តស្វាយរៀង-ព្រៃវែង-កំពង់ចាម-តាកែវ-កំពត-កែប-ព្រះវិហារ-ឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ។ ក្រសួងបានផ្សព្វផ្សាយការងារសម្រង់ព័ត៌មានសម្រាប់ធ្វើបច្ចុប្បន្នភាពទិន្នន័យមុខជំនាញ ឯកទេសមន្ត្រីរាជការ នៅថ្នាក់កណ្តាល និងមន្ទីររាជធានី-ខេត្តដើម្បីពង្រឹងការគ្រប់គ្រងមន្ត្រីរាជការឱ្យមានប្រសិទ្ធភាព។ ក្រសួងបានផ្សព្វផ្សាយណែនាំស្តីពីនីតិវិធីក្នុងការតម្លើងថ្នាក់-ឋានន្តរសក្តិ និងតម្លើងកម្រិតប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការ មានការចូលរួមពីអគ្គនាយករង សកលវិទ្យាធិការរង ប្រធាន-អនុប្រធាននាយកដ្ឋាន ប្រធាន-អនុប្រធានមន្ទីរ។ បានធ្វើប្រកាសតែងតាំងថ្នាក់អនុប្រធាននាយកដ្ឋាន និងថ្នាក់ការិយាល័យចំនួន៣០៤នាក់។ បានធ្វើសំណើ និងព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសតម្លើងឋានន្តរសក្តិតាមមុខតំណែងចំនួន៩៥នាក់។ បានបញ្ចប់ការងារធ្វើបច្ចុប្បន្នភាពស្ថិតិមន្ត្រីរាជការតាមមុខជំនាញមានចំនួន១.៣០១នាក់ ក្នុងនោះមាន: ថ្នាក់កណ្តាលចំនួន៩៣០នាក់ (មានសញ្ញាបត្រ: បណ្ឌិត៧នាក់-បរិញ្ញាបត្រជាន់ខ្ពស់១៤៧នាក់-បរិញ្ញាបត្រ៣២៣នាក់-បរិញ្ញាបត្ររង២៩នាក់ ស្នាតកបត្រសិល្បៈ៤២៤នាក់)។ ថ្នាក់រាជធានី-ខេត្តចំនួន៣៧១នាក់(មានសញ្ញាបត្រ: បរិញ្ញាបត្រជាន់ខ្ពស់១៥នាក់-បរិញ្ញាបត្រ៥៦នាក់-បរិញ្ញាបត្ររង៨នាក់-ស្នាតកបត្រសិល្បៈ២៩២នាក់)។ ធ្វើសំណើសុំតម្លើងថ្នាក់ជូនមន្ត្រីរាជការចំនួន១.៦០៣នាក់ក្នុងនោះថ្នាក់កណ្តាលចំនួន៩៤០នាក់។ បានធ្វើប្រកាសតម្លើងកម្រិតប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការសរុបចំនួន៤៥២នាក់ ក្នុងនោះថ្នាក់កណ្តាលចំនួន២៧៩នាក់។ ធ្វើសំណើសុំរបបឧបត្ថម្ភកូន និងប្រពន្ធចំនួន២៤នាក់។ ធ្វើប្រកាសជ្រើសរើសពលករអណ្តែតឆ្នាំ២០១១ចំនួន៥២៧នាក់ ក្នុងនោះថ្នាក់កណ្តាលចំនួន១៣៤នាក់។ ធ្វើប្រកាសជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាឆ្នាំ២០១១ចំនួន២៧៧នាក់ ក្នុងនោះថ្នាក់កណ្តាលចំនួន៨១នាក់។ ធ្វើប្រកាសជូនមន្ត្រីរាជការឱ្យចូលនិវត្តន៍ចំនួន៨៨នាក់ ក្នុងនោះថ្នាក់កណ្តាលចំនួន៣៤នាក់។ បានធ្វើប្រាក់ឧបត្ថម្ភមន្ត្រីទទួលមរណភាពចំនួន០៧នាក់ និងសុំលាឈប់ពីការងារចំនួន០១នាក់។ បានរៀបចំបែបបទសញ្ញាបត្រស្នាតកបត្រសិល្បៈជូនសិល្បករចាស់ៗចំនួន២៧០សន្លឹក។ ប្រឡងជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មីបានចំនួន៥៦នាក់ ក្នុងនោះស្រី២៦នាក់ (មន្ត្រីនៅថ្នាក់កណ្តាល២៣នាក់)។ ធ្វើលិខិតឧទ្ទេសនាមគ្រូសាស្ត្រាចារ្យឱ្យបង្រៀនរបបម៉ោងបន្ថែមកំរិតឧត្តមចំនួន៣០៩នាក់ យោងតាមការស្នើសុំរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ សកម្មភាពការងារដែលមន្ត្រីរាជការក្នុងនាយកដ្ឋានបុគ្គលិកទាំងអស់បានខិតខំអនុវត្តអស់រយៈពេលមួយឆ្នាំនេះ បើប្រៀបធៀបទៅនឹងផែនការឆ្នាំ អនុវត្តសម្រេចបាន

១០០ភាគរយហើយ ស្នាដៃទាំងអស់នេះគឺដោយសារប្ដេជ្ញាចិត្តខំប្រឹងប្រែង រួមសាមគ្គីគ្នាអនុវត្តឱ្យបានសម្រេចតាមផែនការឆ្នាំ ២០១១ ដែលមហាសន្និបាតក្រសួងដាក់ជូននាយកដ្ឋាន ។

**២.៣.ការងារសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល :**

ក្រសួងបានរៀបចំប្រជុំពិភាក្សាលើអត្ថបទព្រាងអនុក្រឹត្យ ស្ដីពីអង្គភាពគ្រប់គ្រងសិទ្ធិរួម។ បានរៀបចំសិក្ខាសាលាស្ដីពីអង្គភាពគ្រប់គ្រងសិទ្ធិរួមនៅទីស្ដីការក្រសួង។ មន្ត្រីនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានរៀបចំកិច្ចប្រជុំជាមួយតំណាងមកពីអង្គការ ECAP II ដើម្បីឱ្យអង្គការបន្តដំណើរការឡើងវិញ និងជួយឧបត្ថម្ភជាសម្ភារៈផ្សេងៗសម្រាប់ការងារបណ្ដុះបណ្ដាលធនធានមនុស្សលើការងារសិទ្ធិអ្នកនិពន្ធ។ មន្ត្រីនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ បានចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការកំណត់លេខកូដនៃម៉ាកជារូបភាព និងចំណាត់ថ្នាក់នៃទំនិញ ឬសេវានៅក្រសួងពាណិជ្ជកម្ម។ មន្ត្រីនាយកដ្ឋានបានចូលរួមវគ្គសិក្សាបន្តស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលក្នុងសេដ្ឋកិច្ចពិភពលោកនៅប្រទេសសឹង្ហបុរី។ មន្ត្រីនាយកដ្ឋានបានចូលរួមសិក្ខាសាលាស្ដីពី "Copyright and Effective Practices Against Digital and Internet Piracy" នៅទីក្រុងបាងកក ប្រទេសថៃ។ មន្ត្រីនាយកដ្ឋានបានទៅចូលរួមប្រជុំ ស្ដីពីការគ្រប់គ្រងច្បាប់សិទ្ធិអ្នកនិពន្ធតាមប្រព័ន្ធអ៊ិនធើណេត នៅទីក្រុងបាងកក ប្រទេសថៃ។ មន្ត្រីនាយកដ្ឋានបានចូលរួមវេទិកាតាមតំបន់ ស្ដីពីអង្គភាពគ្រប់គ្រងសិទ្ធិរួម នៅប្រទេសសឹង្ហបុរី។ ប្រធាននាយកដ្ឋាន និងមន្ត្រី០២រូបបានចូលរួមកិច្ចប្រជុំអំពី ការប្រមូលព័ត៌មានកម្មសិទ្ធិបញ្ញាបច្ចុប្បន្ន និងការចងក្រងកម្មវិធីកម្មសិទ្ធិបញ្ញា នៅក្រសួងពាណិជ្ជកម្ម ។

បានចេញលិខិតបញ្ជាក់ការពារស្នាដៃសរុបចំនួន៤៦ស្នាដៃ និង បានចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មលើស្នាដៃគ្មានមរតកសាសនី នូវចម្រៀងចំនួន១៨០បទ និងស្នាដៃអក្សរសាស្ត្រចំនួន០១ ។

**២.៤.ការងារផែនការ ស្ថិតិ និងសរុប ៈ**

បានចុះផ្ទៀងផ្ទាត់តួលេខ និងធ្វើរបាយការណ៍ការអនុវត្តកម្មវិធីវិនិយោគសាធារណៈឆ្នាំ២០១០ ដើម្បីផ្ញើជូនទីស្ដីការគណៈរដ្ឋមន្ត្រី និងបានចងក្រងជាសៀវភៅ។ រៀបចំឯកសារបូកសរុបការងារវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១១ និងទិសដៅការងារឆ្នាំ២០១២ដើម្បីបើកសន្និបាត។ រៀបចំឯកសារបូកសរុបការងារវប្បធម៌ និងវិចិត្រសិល្បៈប្រចាំខែ ត្រីមាស ឆមាស និងទិសដៅការងារត្រូវអនុវត្តបន្ត ផ្ញើជូនទីស្ដីការគណៈរដ្ឋមន្ត្រី និងស្ថាប័នពាក់ព័ន្ធបានទាន់ពេលកំណត់។ មន្ទីរវប្បធម៌ដែលបានទទួលការវិនិយោគទុនពីអង្គការ និងសង្គមស៊ីវិលមានៈ ខេត្តប៉ៃលិន ធ្វើការជួសជុលចេតីយភ្នំយ៉ាត បានទុនពីក្រុមហ៊ុន ស៊ីម៉ែកសប្បុរសជនប្រទេសមីយ៉ាន់ម៉ា និងខេត្តកំពង់ស្ពឺ បានអភិរក្ស-អភិវឌ្ឍរមណីយដ្ឋានភ្នំចាស់ បានទុនមកពីអង្គការអភិវឌ្ឍសេដ្ឋកិច្ចជនបទ-បានបង្ហាត់សិល្បៈឆៃយ៉ាំ និងរបាំបាន២ក្រុម បានទុនពីអង្គការទស្សនពិភពលោក និងបង្ហាត់របាំ៣ក្រុម បានទុនពីអង្គការ NHCC អង្គការ KANA និងអង្គការដើមត្នោត។ ប្រមូលឯកសារចងក្រងបោះពុម្ព សៀវភៅស្ថិតិឆ្នាំ២០១១ និងសៀវភៅស្ដីពីលទ្ធផលការងារវប្បធម៌ឆ្នាំ២០១១ (នៅដើមឆ្នាំ២០១២)។ ពិនិត្យជារួមការងារ ផែនការ ស្ថិតិ និងសរុប យើងសម្រេចបាន៨០ភាគរយ នៃផែនការឆ្នាំ។

**២.៥.ការងារសហប្រតិបត្តិការវប្បធម៌អន្តរជាតិ និងកិច្ចការអាស៊ាន ៈ**

នាយកដ្ឋានបានទទួលលិខិតចូលចំនួន៥៨៦ឯកសារ ដែលមកពីក្រៅប្រទេសផ្សេងៗ និងក្នុងប្រទេសរួមមានអង្គការនានាផងដែរ ដើម្បីទំនាក់ទំនងការងារវប្បធម៌ ដោយបានដាក់ឆ្លងថ្នាក់ដឹកនាំក្រសួងពិនិត្យសម្រេច។ បានរៀបចំទទួលគណៈប្រតិភូមកជួបពិភាក្សាការងារអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាមួយថ្នាក់ដឹកនាំក្រសួង និងថ្នាក់ដឹកនាំបានចូលរួមក្នុងអង្គពិធីផ្សេងៗមានចំនួន៥០លើក។ បានរៀបចំឯកសារជូនគណៈប្រតិភូរបស់ក្រសួងចេញធ្វើទស្សនកិច្ចក្រៅប្រទេសមានចំនួន៧៧លើករួមមានៈ ចេញទៅចូលរួមមហោស្រពខ្លែង-មហោស្រពសិល្បៈ-ប្រជុំ-សិក្ខាសាលា-បណ្ដុះបណ្ដាលខ្លី និងការតាំងពិព័រណ៍។ ក្នុងនោះដែរ

លោកអនុប្រធាននាយកដ្ឋាន បានដឹកនាំក្រុមសិល្បៈចំនួន១១នាក់ ទៅចូលរួមមហោស្រពសិល្បៈពុទ្ធសាសនានៅ New Delhie ប្រទេសឥណ្ឌា ប្រទេសចូលរួមមហោស្រពមាន៥ប្រទេសគឺ សិរីលង្កា-នេប៉ាល់-កូរ៉េ-ប៊ូតង់ និងកម្ពុជា ទទួលលទ្ធផលជោគជ័យ។ លោក គង់ សុទ្ធារិទ្ធិ អនុប្រធានការិយាល័យ(តារាចម្រៀង) បានចូលរួមការប្រគុំតន្ត្រីអបអរឆ្នាំ២០១២ និងបើកសម្ពោធស្ថានីយទូរទស្សន៍ Yunnan TV Channel នៅទីក្រុង Ruili ខេត្ត Yunnan ប្រទេសចិន ការប្រគុំតន្ត្រីមានការចូលរួមពីតារាចម្រៀងមកពីប្រទេសអាស៊ាន-ចិនដីគោក-ហុងកុង និងតៃវ៉ាន់។ នាយកដ្ឋានបានបន្តរៀបចំ និងកែសម្រួលលើកិច្ចព្រមព្រៀងថ្មីរវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគឺ :

-ធ្វើការចុះអនុស្សារណៈនៃកិច្ចសហប្រតិបត្តិការរវាងបណ្ណាល័យជាតិកម្ពុជា និងបណ្ណាល័យជាតិបារាំង រយៈពេល៣ឆ្នាំ

-ឯកឧត្តម សំរាំង កំសាន្ត ចុះហត្ថលេខាជាមួយវិទ្យាស្ថានសិល្បៈខ្មែរអមតៈ

-ឯកឧត្តម ឃឹម សារិទ្ធ ចុះកិច្ចព្រមព្រៀងគម្រោងការងាររវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា

-ឯកឧត្តម ឃឹម សារិទ្ធ ចុះកិច្ចព្រមព្រៀងលើគម្រោងថវិកាឧបត្ថម្ភការបង្កើតឯកសារភ្លេងប្រពៃណីខ្មែរ រវាងអង្គការសិល្បៈខ្មែរអមតៈ និងស្ថានទូតអាមេរិក ប្រចាំកម្ពុជា

-ឯកឧត្តម ហាប់ ទូច ចុះកិច្ចព្រមព្រៀងគម្រោងស្រាវជ្រាវបុរាណវិទ្យា រវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាមួយនឹងសាកលវិទ្យាល័យអូតាហ្គោ ប្រទេសញូហ្សេលេន ។

ឆ្នាំ២០១១នេះ ការងារមួយចំនួនដែលនាយកដ្ឋានបានគ្រោងនឹងធ្វើ ខ្លះបានអនុវត្តតាមផែនការដែលបានគ្រោងទុក តែការងារខ្លះទៀតក៏មិនបានអនុវត្តផែនការ ដោយសារពេលវេលាខ្លី និងថវិការដ្ឋមិនអាចធ្វើបានដូចជា គ្រោងរៀបចំខួបអាស៊ានលើកទី៤៥ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១នេះ មិនបានអនុវត្តដោយសារកង្វះថវិកា ហេតុដូចនេះត្រូវផ្អាកសិន ។

**២.៦.ការងារគណនេយ្យ និងហិរញ្ញវត្ថុ :**

រៀបចំគម្រោងផែនការថវិការបស់ក្រសួងប្រចាំឆ្នាំ២០១២។ បានធ្វើសំណុំឯកសារបង្វែរចំណូលចូលថវិការដ្ឋៈ ពីថ្លៃឈ្នួលរោងភាពយន្តលុច្ស០៧លើក-ពីថ្លៃឈ្នួលមណ្ឌលរូបភាព០៦លើក-ពីថ្លៃឈ្នួលរោងភាពយន្តខេមរិន្ទ-ពីថ្លៃឈ្នួលទីតាំងមួយផ្នែករបស់នាយកដ្ឋានអភិវឌ្ឍវប្បធម៌ប្រចាំត្រីមាស និងពីថ្លៃឈ្នួលទីតាំងរោងភាពយន្តខេត្តកំពង់ចាម។ ធ្វើលិខិតទារបំណុលដែលមិនទាន់បង់ថ្លៃឈ្នួលទីតាំងមានៈ រោងភាពយន្តភ្នំពេញ-រោងភាពយន្តវិមានទិព្វ និង អាគារត្រួតពិនិត្យកាស្សែតវីដេអូ។ បានបង់ចំណូលចូលថវិការដ្ឋពីការលក់សំបុត្រចូលទស្សនាសារមន្ទីរជាតិ-ការត្រួតពិនិត្យកាស្សែតវីដេអូ-ការត្រួតពិនិត្យវត្ថុសិល្បៈ នាំចេញ នាំចូល និងការសុំសិទ្ធិធ្វើអាជីវកម្មលើស្នាដៃគ្មានអ្នកទទួលមរតក និងជួលអចលនទ្រព្យ។ ធ្វើតារាងទ្វេភាគ (ទិន្នានុប្បវត្តិ-សៀវភៅធំ-តារាងតុល្យភាព) ប្រចាំឆ្នាំ២០១០-ធ្វើតារាងតុល្យភាពប្រចាំខែ ទាក់ទងបៀវត្ស និងជំនួយយូណេស្កូ និងធ្វើតារាងផ្ទៀងផ្ទាត់ការបង់ចំណូលចូលថវិការដ្ឋផ្នែក រដ្ឋបាលកណ្តាល រូបិយប័ណ្ណ រាជធានី-ខេត្ត ប្រចាំឆ្នាំ២០១០ ជូនអគ្គនាយកដ្ឋានរតនាគារជាតិពិនិត្យ។ ធ្វើរបាយការណ៍ចំណូលប្រចាំខែឱ្យនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ និងចំណូលថវិការដ្ឋទូទៅជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ប្រមូលបង្កាន់ដៃបង់ប្រាក់ពីការជួលអចលនវត្ថុ និង ជម្រុញឱ្យបង់ថ្លៃជួលអចលនវត្ថុឱ្យទាន់ពេលវេលា។ បានទូទាត់បំណុលលិខិតផ្លូវការជំពាក់ពន្ធរដ្ឋ ចាប់ពីត្រីមាសទី១ ដល់ទី២ និងពីត្រីមាសទី៣ ដល់ទី៤ ឆ្នាំ២០១១។

បង់វិភាគទានឆ្នាំ២០១១ ជូនមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការសិក្សាការពារ និងស្តារឡើងវិញនូវសម្បត្តិវប្បធម៌ (ICCROM)។ ស្នើសុំថវិកាចំណាយបេសកកម្មក្នុងប្រទេសជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្នុងក្រសួងបាន៣១០លើក និងក្រៅប្រទេស២៥លើក។ ធ្វើរបាយការណ៍ទូទាត់រជ្ជទេយ្យបុរេប្រទានបាន០៨ជុំ។ រៀបចំឯកសារដើម្បីសហការជាមួយប្រតិភូអធិការកិច្ចក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គសវនកម្មជាតិ ចុះត្រួតពិនិត្យ។ បានចូលរួមប្រជុំការពារគម្រោងថវិកាឆ្នាំ២០១២ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**២.៧.ការងារសម្ភារៈ និងបរិក្ខារ ៖**

បានធ្វើការជម្រះបញ្ជីនូវសម្ភារៈសង្ហារឹម និងឧបសម្ព័ន្ធមួយចំនួនចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់នាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ និងនាយកដ្ឋានអភិវឌ្ឍវប្បធម៌។ ចុះទៅផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះសីហនុ-កំពង់ចាម ពោធិសាត់ និងកំពង់ស្ពឺ។ ធ្វើលិខិតទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីស្នើសុំគោលការណ៍ជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ស្ពឺ។ លើកគម្រោងជួសជុលទីស្តីការក្រសួង-ប្រព័ន្ធម៉ាស៊ីនត្រជាក់សាលសន្និសីទចតុមុខ-សារមន្ទីរខេត្តស្វាយរៀង-សាលាមធ្យមវិចិត្រសិល្បៈ និងបណ្ណាល័យមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ចាម និងលើកគម្រោងសាងសង់របងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តក្រចេះ និងមន្ទីរខេត្តស្ទឹងត្រែង។ ការងារដេញថ្លៃក្នុងស្រុក០៣លើកៈ ថ្លៃប្រេងឥន្ធនៈឆមាសទី១ និង ថ្លៃសម្ភារៈការិយាល័យឆមាសទី១ និងប្រេងឥន្ធនៈឆមាសទី២។ ការងារប្រគល់-ទទួលមាន២០លើកៈ ប្រេងឥន្ធនៈ-បោះពុម្ពក្បាលលិខិតក្រសួង-សម្ភារៈការិយាល័យ-ការងាររៀបចំថែទាំជួសជុលសម្ភារៈ-ជួសជុលម៉ាស៊ីនត្រជាក់-ផ្គត់ផ្គង់សម្ភារៈរថយន្ត-ជួសជុលដំបូលពិដានអាគារសកលវិទ្យាល័យ-ជួសជុលអាគារសាលាមធ្យម-អាគារសន្តិសុខស្នាក់នៅ-អាងរូបសំណាកនាងគង្ហីង នៅទីស្តីការក្រសួង-គ្រឿងសង្ហារឹម-ជួសជុលរថយន្ត១៨គ្រឿង-បណ្ណាល័យខេត្តកំពង់ចាម-ចំណតរថយន្តក្រសួង-ឃ្លាំងសម្ភារៈនាយកដ្ឋានអភិវឌ្ឍវប្បធម៌-សៀវភៅភាសារជាតិ-ផ្ទាំងគំនូរផ្សាយកែលម្អសាលចតុមុខ និងជួសជុលរថយន្ត៨គ្រឿង។ ការងារបោះពុម្ពបដាពាក្យស្លោកសម្រាប់បំរើការងារ និងបុណ្យផ្សេងៗបានចំនួន១៤លើក។ សកម្មភាពសាលសន្និសីទចតុមុខ បំរើការងារក្នុងក្រសួង និងស្ថាប័នផ្សេងៗ បានរៀបចំកម្មវិធីចំនួន៣១លើក។ សកម្មភាពការងារសម្ភារៈ និងបរិក្ខារមានដំណើរការរលូនទៅតាមផែនការកំណត់ ពិសេសការងារសំណង់វប្បធម៌សម្រេចបាន១០០ភាគរយ លើការងារជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធតាមអង្គភាព ។

**២.៨.សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ ៖**

បើកវគ្គបណ្តុះបណ្តាលមន្ត្រីរាជការបានចំនួន០៣វគ្គ គឺ ៖ វគ្គបណ្តុះបណ្តាលមន្ត្រីរាជការ ស្តីពីការងារផ្តល់សេវាទៅលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈ មានសិក្ខាកាមចំនួន៨២នាក់ វគ្គបណ្តុះបណ្តាលមន្ត្រីរាជការ ស្តីពីការងារផ្តល់សេវាទៅលើការងារសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម មានសិក្ខាកាមចំនួន៤៣នាក់ មកពីនាយកដ្ឋាន អង្គភាពចំណុះក្រសួង និងមន្ទីរវប្បធម៌និងវិចិត្រសិល្បៈគ្រប់ខេត្ត និងរាជធានី និងវគ្គវិក្រិត្យការអ្នកគ្រប់គ្រង និងអ្នកបង្កើតស្នាដៃសិល្បៈមហាជនទូទាំងប្រទេស។

ចំពោះសកម្មភាពការងារដែលបានអនុវត្តនេះ ឃើញថាសម្រេចបាន៩០ភាគរយ បើប្រៀបធៀបទៅនឹងផែនការសកម្មភាពការងារប្រចាំឆ្នាំ២០១១ ។

**២.៩.ការងារនីតិកម្ម :**

ដើម្បីពង្រឹងពង្រីកសមត្ថភាពស្ថាប័ន បង្កើនប្រសិទ្ធភាពការងារ និងបម្រើសេវាកម្មសាធារណៈ ក្រសួងរៀបចំលិខិតបទដ្ឋានបានមួយចំនួនគឺៈ បានប្រជុំសម្រេចខ្លឹមសារអនុក្រឹត្យចំនួន២គឺ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម និង ស្តីពីគ្រប់គ្រងថ្មបាយក្រៀម និងថ្មភក់ ។ បានរៀបចំប្រកាសចំនួន៦គឺៈ

- ប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មសៀវភៅ
- ប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈសិល្បករ
- ប្រកាសស្តីពីក្រមសីលធម៌មតិកមនុស្សរស់
- ប្រកាសស្តីពីគ្រប់គ្រងអាជីវកម្ម សេវាកម្ម
- ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់តែមប្រ៍ និងត្រាទិដ្ឋាការ លើផលិតផលសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម
- ប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្ម សេវាកម្ម លក់ ស្នាដៃភាពយន្ត វីដេអូ ។

**៣.ការងារបេតិកភណ្ឌរូបី :**

**៣.១.ការងារគាំពារ និងអភិរក្សសំណង់បុរាណៈ**

៣.១.១.<u>ការងារអភិរក្សអង្គរ :</u>

បានទទួលក្រុមការងារបច្ចេកទេសពីសាលាបារាំងចុងបូព៌ា មកពិនិត្យសិលាចារឹក និងបំណែករូបចម្លាក់ខ្លះៗក្នុងឃ្លាំងរយៈពេល០២ថ្ងៃ និងមកស្រាវជ្រាវធ្វើបញ្ជីរូបចម្លាក់ និងបញ្ជីសិលាចារឹកដែលមាននៅក្នុងឃ្លាំងអភិរក្សអង្គរ ។ ទទួលក្រុមនិស្សិតបុរាណវិទ្យាចំនួន០២នាក់ មកពីសកលវិទ្យាល័យបុរាណវិទ្យា នៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ចូលផ្តិតសិលាចារឹកក្នុងឃ្លាំង០១ថ្ងៃ និង បានទទួលនិស្សិតមកពីសកលវិទ្យាល័យ ជា ស៊ីម កំចាយមារចំនួន២០៧នាក់ ចូលមកទស្សនាឃ្លាំងអភិរក្សអង្គរ០១ថ្ងៃ ។ បានសហការជាមួយក្រុមការងារបច្ចេកទេសរបស់អាជ្ញាធរអប្សរា ដើម្បីស្រាវជ្រាវរកគំរូក្បាលយក្ស និងទេវតា ដើម្បីឆ្លាក់ចម្លងយកទៅដាក់នៅទីតាំងចាស់ក្នុងប្រាសាទតំបន់អង្គរវិញ ដោយក្រុមការងារបានរកឃើញឯកសារ និងបានជ្រើសរើសរូបដូចជាៈ ព្រះកេសយក្ស មកពីខ្លោងទ្វារទន្លេអុំចំនួន០២ ព្រះកេសទេវតាមកពីខ្លោងទ្វារទន្លេអុំចំនួន០២ និង រូបតោមកពីទីលានស្តេចគម្លង់ ។ បានចាក់ជើងទម្ររូប និងធ្វើការតរូបព្រះពុទ្ធ នៅអភិរក្សដ្ឋានអង្គរ ។ ទទួលវត្ថុសិល្បៈចំនួន០៤មុខពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាបមានៈ បំណែកទេវរូបនៅសល់ដើមទ្រូង០១ដុំ-ចម្រឹងបង្អួចប្រាសាទ០១ដុំ-បំណែកដុំចម្លាក់០១ដុំ និងបំណែកទេវរូបភេទប្រុសផ្នែកខាងមុខ០១ដុំ ។

៣.១.២<u>ការងារស្រាវជ្រាវ និង ចងក្រងឯកសារប្រវត្តិសាស្ត្រ :</u>

បានចុះទៅពិនិត្យមើលទីតាំងស្ថានភាពប្រាសាទព្រះខ័ន្ត កំពង់ស្វាយ ខេត្តព្រះវិហារ ចំនួន០២ថ្ងៃ។ បានចុះទៅពិនិត្យមើលស្ថានភាពស្ពានហាល ប្រាសាទបន្ទាយឆ្មារ ដើម្បីលើកគម្រោងជួសជុល និង បានចុះទៅពិនិត្យមើលស្ថានភាពស្ពានហាលខាងត្បូង នៃប្រាសាទបន្ទាយឆ្មារ ដោយបានឧបត្ថម្ភពីអង្គការមិត្តសម្លាញ់ ទិញថ្មភក់ចំនួន០១ម៉ែត្រគូប ស្មើនិង១០ដុំ និងថ្មបាយ

ក្រៀម១០ម៉ែត្រគូប ស្មើ១២៣ដុំ។ មន្ត្រីជំនាញបានចុះទៅអនុវត្តគម្រោងជួសជុល និងអភិរក្សប្រាសាទកំពង់ព្រះ ស្ថិតនៅខេត្តកំពង់ឆ្នាំង បានបញ្ចប់ និងធ្វើរបាយការណ៍ជាសៀវភៅជូនក្រសួង។

៣.១.៣ការងារគ្រប់គ្រងរមណីយដ្ឋានវប្បធម៌ :

បន្តរៀបចំគម្រោងប្លង់មេប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំ និងបានរៀបចំឯកសារកសាងប្លង់មេរមណីយដ្ឋានកែច្នៃជាកន្លែងកំសាន្ត ទុកជាឯកសារ ។

៣.១.៤ការងារអភិរក្សជួសជុលប្រាសាទ-សំណង់បុរាណ :

បាននឹងកំពុងស្រាវជ្រាវឯកសារពិគ្រោះពិភាក្សាដើម្បីចងក្រងគម្រោងផែនការមេ នៃប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំ។ គូរប្លង់ផ្ទះរចនាបទខ្មែរជាគំរូចំនួន១៨ប្លង់ផ្សេងៗគ្នា ជូនអគ្គនាយកបេតិកភណ្ឌសំរាប់ឱ្យប្រជាជនសាងសង់សំណង់ នៅប្រាសាទបន្ទាយឆ្មារ និង បានរៀបចំគូរប្លង់ផ្ទះរចនាបទខ្មែរជាគំរូចំនួន១០ផ្ទះ ផ្ញើជូនឯកឧត្តមអគ្គនាយកបេតិកភណ្ឌ តាមការស្នើសុំរបស់សាធារណរដ្ឋកូរ៉េខាងត្បូង។ លើកគម្រោងថវិកាជួសជុលស្ពានអូរជីក ប្រវែង១៥១ម៉ែត្រ នៅខេត្តឧត្តរមានជ័យ រយៈពេល៥ឆ្នាំ លើកគម្រោងស្តារ និងជួសជុលឡើងវិញនូវប្រាសាទស្នឹង នៅខេត្តបាត់ដំបង រយៈពេល៣ឆ្នាំ-លើកគម្រោងថែទាំ ជួសជុលស្ពានហាលខាងត្បូង នៃប្រាសាទបន្ទាយឆ្មារ-លើកគម្រោងទល់ទ្រប្រាសាទ S2 នៃប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំ-លើកគម្រោងថែទាំប្រាសាទបាណន់ ខេត្តបាត់ដំបង និង គម្រោងថែទាំប្រាសាទនគរបាជ័យ ខេត្តកំពង់ចាម ។

៣.១.៥ការងារគ្រប់គ្រងសំណង់ប្រវត្តិសាស្ត្រ :

យើងបានពិនិត្យ តម្លើងឧបករណ៍សម្ភារៈ ដែលជាអំណោយរបស់មជ្ឈមណ្ឌលបេតិកភណ្ឌកូរ៉េ ដោយសាកល្បង និងបានពិនិត្យនិងតម្លើងឧបករណ៍ម៉ាស៊ីន TOPO ដើម្បីត្រៀមចុះទៅពិនិត្យទីតាំងធ្វើប្លង់មេប្រាសាទព្រះខ័នកំពង់ស្វាយ ខេត្តព្រះវិហារ និង ចុះទៅពិនិត្យទីតាំងវាស់ស្ទង់ការជួសជុលស្ពានហាលខាងត្បូង នៃប្រាសាទបន្ទាយឆ្មារ។ បានចងក្រងឯកសារ ស្តីពីប្រវត្តិ និងការអភិរក្សប្រាសាទមាន ប្រាសាទកោះកេរ និងប្រាសាទព្រះខ័នកំពង់ស្វាយ រៀបចំទុកជាឯកសារ ។

៣.១.៦.ការងារអភិរក្សតាមបណ្តាខេត្ត :

១.អភិរក្សដ្ឋានកំពង់ធំ និង ព្រះវិហារ :

បន្តសហការជាមួយអង្គការ Waseda ទាំងបច្ចេកទេសជួសជុល និងចងក្រងឯកសារ ស្តីពីការជួសជុលប្រាសាទសំបូរព្រៃគុក នៅខេត្តកំពង់ធំ។

២.អភិរក្សដ្ឋានបាត់ដំបង បន្ទាយមានជ័យ និងឧត្តរមានជ័យ :

ខេត្តបន្ទាយមានជ័យបានពិនិត្យ និងទប់ស្កាត់ការសាងសង់របស់ប្រជាពលរដ្ឋនៅតំបន់ប្រាសាទបន្ទាយឆ្មារ ដែលពុំបានសុំច្បាប់សាងសង់ឱ្យផ្អាកការសាងសង់ ដោយឱ្យសុំច្បាប់សាងសង់តាមផ្ទះគំរូចំនួន១០ទម្រង់ផ្សេងៗគ្នា ដែលបានផ្តល់ជូនឱ្យគាត់ជ្រើសរើស។ បានជួសជុលស្ពានហាល ដែលជាគម្រោងថវិការបស់លោកស្រី JOYCE CLARK និង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដូចខាងក្រោម :

ជួសជុលស្ពានហាល ផ្នែករូបយក្ស "ខាងក្បាលនាគ" ៈ បានរៀបចំគ្រឹះជញ្ជាំងអំពីថ្មបាយក្រៀមរួចរាល់-ជួសជុលកាំជណ្ដើរកសិណចំនួន០៤កាំ-បញ្ចូលថ្មភក់ថ្មីចំនួន០៣ដុំ និងបញ្ចូលថ្មភក់ចាស់ចំនួន០២ដុំ។ ខាងកន្ទុយនាគៈ បានរៀបបញ្ចូលថ្មភក់គ្រឹះជញ្ជាំងរួចជាស្ថាពរ-រើពង្រឹងគ្រឹះថ្មបាតចំនួន១០ដុំ-រៀបចំជើងទម្រខ្លួនយក្សចំនួន០៣រូប និងបានបញ្ចប់ការជួសជុលកន្ទុយនាគ (ខាងរូបយក្ស) ដោយបន្ថែមថ្មភក់ថ្មីចំនួន១៥ដុំ។ ផ្នែករូបទេវតាៈ បានជួសជុលលូបុរាណបានប្រហែល៩០ភាគរយ-រៀបចំបញ្ចូលថ្មបាយក្រៀមថ្មីចំនួន១២០ដុំ-ចាក់បន្ទះបេតុងចំនួន១២បន្ទះដើម្បីគ្របលូ-ធ្វើកំណាយជញ្ជាំងស្ពានហាលខាងក្បាលនាគផ្នែករូបយក្សដល់ថ្មបាតគ្រឹះមានបណ្ដោយ៨ម ទទឹង១ម-រៀបចំបញ្ចូលថ្មភក់ចាស់ចំនួន០៣ដុំ និងថ្មបាយក្រៀមថ្មីចំនួន១៨ដុំ។ នៅកន្ទុយនាគផ្នែករូបយក្សបានរើថ្មភក់ចំនួន៤០ដុំ និងរកឃើញក្បាលយក្ស០១រូប (បែកជាពីរ)-បានផ្គុំថ្មភក់ដងខ្លួនយក្សចំនួន០៣ដុំ-បានរើពង្រឹងគ្រឹះថ្មបាតចំនួន១០ដុំ-រកថ្មផ្គុំដងខ្លួនទេវតាបានចំនួន០៥រូប និងរកឃើញព្រះកេសនៅល្អមួយបានយកធ្វើនៅទីស្នាក់ការនគរបាលការពារបេតិកភណ្ឌប្រចាំប្រាសាទបន្ទាយឆ្មាររក្សាទុក។ បានធ្វើទំនប់ទប់ទឹកប្រវែង៣០ម៉ែត្រដើម្បីការពារទឹកជំនន់ហូរចូលក្នុងការដ្ឋានដែលកំពុងជួសជុលស្ពានហាលខាងត្បូងប្រាសាទបន្ទាយឆ្មារ និងបានកាយសំអាតលូបុរាណចំនួន០២កន្លែងដែលកប់បាត់ក្នុងជីវយៈពេលជាច្រើនឆ្នាំ។ រៀបចំក្បាលនាគខាងទេវតាបានបន្ថែមថ្មភក់ថ្មីចំនួន៧ដុំរួចជាស្ថាពរ។ បានយកព្រះកេសយក្សទៅដាក់លើដងខ្លួនទី២៨រួចជាស្ថាពរ។ យើងបានបញ្ចប់ការជួសជុលស្ពានហាលដែលជាគម្រោងថវិការបស់ក្រសួងដោយបានចំណាយលើការងារៈ ទិញថ្មភក់១ម៉ែត្រគីប ស្មើ៣ដុំ-ថ្មបាយក្រៀម៣ម៉ែត្រគីប ស្មើ១០ដុំ-បានដាក់ដងខ្លួនទេវតាចំនួន៧រូប និងបានចាក់ដីធ្វើផ្លូវចំនួន៨រថយន្ត។ បានទទួលអំណោយថវិកាពី ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានចំនួន១.០០០.០០០រៀល សម្រាប់ចំណាយៈ ទិញម៉ាស៊ីនកាត់ស្មៅ០១គ្រឿង និងធ្វើស្លាកសញ្ញាបង្ហាញផ្លូវចូលប្រាសាទបន្ទាយឆ្មារមួយផ្ទាំង ។

៣.១.៧.ការងារសហប្រតិបត្តិការជាមួយអន្តរជាតិ ៈ

ក.បានសហការជាមួយអង្គការ G.H.F ជួសជុលប្រាសាទបន្ទាយឆ្មារដូចខាងក្រោម ៈ

ការងារជួសជុលរោងទងទី៣ ដោយបានៈ បញ្ចូលថ្មភក់ថ្មីបាន៧៣ដុំ-ការពង្រឹងគ្រឹះជញ្ជាំងដោយប្រើថ្មភក់ថ្មីបានប្រវែង២៥ម៉ែត្រ និងបានកំពុងបញ្ចូលថ្មភក់ចាស់ទៅវិញបានចំនួន២៥ដុំ-រកថ្មផ្គុំដំបូលនៅចំណុចBបានចំនួន៣០ដុំ-គូរប្លង់សរសរចំនួន២៧ដើម-ប្តូរថ្មសរសរថ្មីបានចំនួន១០ដុំ-ជួសជុលថ្មភក់ចាស់បាន៤៧ដុំ-ផ្គុំថ្មឡើងវិញបាន៧៣ដុំ-រកថ្មភក់ចាស់ដាក់បញ្ចូលវិញបាន០៦ដុំ-រៀបចំកំរាលថ្មភក់ឡើងវិញបានចំនួន៤៦ដុំ និងរៀបសរសរលើកំរាលបានចំនួន០៤ដើម-បានរើ និងរៀបជញ្ជាំងរោងទងឡើងវិញបានចំនួន០៦ម៉ែត្រការ៉េ ដោយប្រើថ្មភក់ចាស់ថ្មីចំនួន២០ដុំ-បានរើជញ្ជាំងខាងត្បូងជ្រុងខាងកើតចំនួន១០០ដុំ-ជួសជុលបំណែកថ្មភក់ចាស់បាន២២ដុំ និងរៀបជញ្ជាំងរូតទី៥ ចំនួន២១ដុំ និងរូតទី១៨ ចំនួន៣០ដុំ ។

ការងារជួសជុលតួប៉មទី១៨ ដោយបាន ៈ បានរៀបចំសាកល្បងថ្មភក់ចាស់ ដែលបានរកឃើញចំនួន១៥ដុំ-រើថ្មភក់រាយប៉ាយជុំវិញតួប៉មទី១៨បានចំនួន១.៨៦១ដុំ-ការស្កេនថ្ម៣ជ្រុងពីរូតទី២០ ទៅរូតទី១៩បានចំនួន៤៨ដុំ-សកម្មភាពទល់ទ្រ២កន្លែងនៅគោបុរៈទី៣បានរួចរាល់-បានផ្គុំរូតទី២៤ ទី២៣ និងទី២២ ចំនួនថ្មភក់៦៧ដុំ-បានរៀបផ្គុំថ្មតួប៉មទី១៨ បានចំនួន៣៣៨ដុំ- រើថ្មតាន់បាន៧៣៩ដុំ-ជួសជុលធ្មឹមបញ្ចូលថ្មភក់ចាស់បាន៣ដុំ-ផ្គុំថ្មក្លោងទ្វារខាងជើងបាន១២ដុំ-ស្កេនថ្មបាន២១ដុំ។ សំអាតយកល្បៈព្រៃនៅជុំវិញការដ្ឋាន និងក្នុងបរិវេណប្រាសាទសរុបបានចំនួន៦០០០ម៉ែត្រការ៉េ ។

ខ.បានធ្វើកិច្ចសហការជាមួយអង្គការ Waseda ជួសជុលប្រាសាទសំបូរព្រៃគុកដូចខាងក្រោម ៖

បានកាប់កូនឈើ និងសំអាតស្មៅឡើងវិញនៃប្រាសាទ N10.w ដើម្បីពិនិត្យមើលរចនាសម្ព័ន្ធ និងបានតម្លើងរន្ទាសំអាតស្មៅ និងកូនឈើរួចស្រេច ដើម្បីគូរប្លង់មុនការរុះរើ។ បានកាប់កូនឈើ និងសំអាតស្មៅឡើងវិញ នៃតួប្រាសាទត្រពាំងល្ពាក់ ប្រាសាទគក់ទ្រូង និងតួប្រាសាទ N14.1 ដើម្បីពិនិត្យមើលរចនាសម្ព័ន្ធប្រាសាទ។ បានធ្វើការលាយបាយអរនៅប្រាសាទ N1 ដែលមានឥដ្ឋ ខ្សាច់ ស៊ីម៉ង់ត៍ កំបោរ ហើយធ្វើការពិសោធន៍ ដោយយកទៅបិតលើបំណែកថ្មបាយក្រៀម និងឥដ្ឋសាកល្បង និងកំពុងដំណើរការជួសជុលដោយប្រសិទ្ធភាពបានចំនួន៥៨ដុំ។ ជួសជុលបង្កាន់ដៃនាគនៅប្រាសាទ N1 ខាងលិចទី២២ រួចរាល់ដោយប្រើប្រាស់បាយអរ និងការបាន១៥យុតសម្រាប់បិទ និងបង្កាន់ដៃនាគនៅប្រាសាទN1-W ស្រទាប់ទី២៤ ដោយប្រើបាយអរ និងការបាន១៨យុត។ ជួសជុលជញ្ជាំងខឿនប្រាសាទN1 ជ្រុងខាងជើងបាន០៥ម៉ែត្រការ៉េមានចំនួន២១យុត ដោយបាញ់បាយអរបញ្ចូល៥៧យុត-ធ្វើកំណាយកំរាលខឿនប្រាសាទN1ខាងកើតបាន៨៦ម៉ែត្រការ៉េ និងចាក់សាច់ដីបាន៥២ម៉ែត្រគីប។ បន្តគូរប្លង់មុខខាងកើតនៃប្រាសាទN1លើខឿនជាន់ក្រោម និងបន្តចុះលេខលើថ្មរ៉ាត់រ៉ាយដែលបានរកឃើញនៅលើកំរាលខឿនប្រាសាទN1ដើម្បីផ្តុំទុកមួយកន្លែង។ បានជួសជុលប្រាសាទN14.1 ដោយប្រើបាយអរបិតមុខកន្លែងគ្រៀកប្រេះដើម្បីពង្រឹងឱ្យមានស្ថានភាពដូចដើមវិញ ដោយប្រើបាយអរបិតបាន៩៥មុខ បាញ់បញ្ចូលបាន១៨យុត។ បានធ្វើកំណាយខឿនប្រាសាទN1 ជ្រុងខាងកើតបាន០៤ម៉ែត្រការ៉េ ហើយរៀបឥដ្ឋឡើងវិញបាន០៣ម៉ែត្រការ៉េ។ បានជាន់ដីឥដ្ឋដើម្បីធ្វើបាយអរលាយជាមួយកំទេចឥដ្ឋបានចំនួន០៥ធុងស្តេត្រូ ដើម្បីទុកពង្រឹងជញ្ជាំង។ លើកបង្កាន់ដៃថ្មរបស់ប្រាសាទN1 ច្រកខាងជើងផ្នែកខាងកើត យកទៅដាក់កន្លែងដើមវិញ។ រៀបចំសំអាត និង ជួសជុលប្រាសាទ N7, N8, N9, N10 និង បានទទួលនិស្សិតមកពីមហាវិទ្យាល័យ ន័រតុនចំនួន១២នាក់ ស្ម័គ្រចិត្តមកជួយជួសជុលប្រាសាទ។ បានសាងសង់រោងដាក់សម្ភារៈនៅខាងជើងអាគារអភិរក្សដ្ឋានសំបូរមានទំហំ ១៥ម × ០៦ម ។

ដោយមានការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអគ្គនាយកដ្ឋានបេតិកភណ្ឌ ធ្វើឱ្យមន្ត្រីរាជការ របស់នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណខិតខំពុះពាររាល់ការលំបាក រួមចំណែកក្នុងការស្តារ និងអភិវឌ្ឍវិស័យវប្បធម៌ឡើងវិញនាពេលបច្ចុប្បន្នជាបណ្តើរៗ ហើយបញ្ហាលំបាកគឺ មន្ត្រីរាជការមួយចំនួនមិនសូវយកចិត្តទុកដាក់នឹងការងារដោយសារប្រាក់បៀវត្សមានកម្រិត។ សកម្មភាពការងាររយៈពេលមួយឆ្នាំនេះ ប្រៀបធៀបទៅនឹងផែនការរបស់នាយកដ្ឋានឃើញថាៈ ការចូលរួមសហការជាមួយអង្គការធ្វើការជួសជុលប្រាសាទបន្ទាយឆ្មារ និងប្រាសាទសំបូរព្រៃគុកបានសម្រេចលទ្ធផល ១០០ភាគរយ។ ចំពោះការជួសជុលប្រាសាទដែលជាគម្រោងផ្ទាល់របស់នាយកដ្ឋានយើងសម្រេចបាន១០០ភាគរយតាមលទ្ធភាពថវិការបស់ក្រសួងបានកំណត់ ។

**៣.២.ការងារសារមន្ទីរ** ៖

-មន្ត្រីជំនាញ១៩នាក់ បានចុះជួយរៀបចំបញ្ជីសារពើភណ្ឌ និងការដាក់រូបនៅសារមន្ទីរខេត្តបាត់ដំបង-បន្ទាយមានជ័យ កំពង់ធំ-កំពង់ស្ពឺ និង សារមន្ទីរអង្គរបុរី ខេត្តតាកែវ ។

ក.សារមន្ទីរជាតិភ្នំពេញ ៖

-បានទទួលវត្ថុសិល្បៈបុរាណចំនួន៤២មុខមាន : ធ្វើអំពីថ្មភក់ចំនួន១០គឺ (ព្រះវិស្ណុ១-ដងខ្លួនព្រះពុទ្ធរូបទ្រង់ឈរ១ បង្កាន់ដៃនាគ២-ស្ពានទ្វារនី១-សត្វអណ្តើក១-បំណែកក្បាលកាលា១-ព្រះកេសព្រះពុទ្ធ១-ប្រាសាទចម្លង១ និងព្រះវិស្ណុ១) ធ្វើអំពីស្ពាន់ចំនួន១គឺ (ព្រះពុទ្ធរូបទ្រង់គ្រឿងផ្ចាញ់មារ) ធ្វើអំពីលោហធាតុចំនួន៣គឺ (គ្រុឌលម្អក្បាលទូក១-កំពូលប្រាសាទ១ និងព្រះពុទ្ធរូបផ្ចាញ់មារ១) អំពីសូត្រចំនួន២៣គឺ (ហូលពិដានខ្មែរ) អំពីប្រាក់ស្រោបព្រមរចំនួន១គឺ (ព្រះពុទ្ធរូបផ្ចាញ់មារ) អំពីប្រាក់ចំនួន១គឺ (ចាន) និង អំពីលោហ និងសូត្រចំនួន៣ឈុតគឺ (សំលៀកបំពាក់របាំនិម្មុដ) ។

-ភ្ញៀវចូលទស្សនាសារមន្ទីរជាតិសរុបមានចំនួន **១៤០.០០០នាក់** (គណៈប្រតិភូជាន់ខ្ពស់ជាតិ-អន្តរជាតិ ភ្ញៀវជាតិ-អន្តរជាតិ សិក្ខាកាម សិស្ស និស្សិត ព្រះសង្ឃ) ក្នុងនោះមាន :

- ភ្ញៀវជាតិចំនួន **២៨.៦៨០ នាក់** បានថវិកាចំនួន **១៤.៣៤០.០០០រៀល**
- ភ្ញៀវអន្តរជាតិចំនួន **៨៩.៨៧៤ នាក់** បានថវិកា **២៦៩.៦២២ ដុល្លារអាមេរិក**
- ភ្ញៀវចូលឥតបង់ថ្លៃចំនួន **២១.៤៤៦ នាក់**

-បានធ្វើបញ្ជីសារពើភណ្ឌវត្ថុបុរាណចំនួន**៣៤៨រូប** និងជួសជុលរូបចម្លាក់បាន**២២៥រូប** ។

**ខ.សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង :**

-ភ្ញៀវជាតិ-អន្តរជាតិ ព្រះសង្ឃ សិស្ស និស្សិតចូលទស្សនាមានចំនួន**១២៨.១០៧នាក់** ក្នុងនោះភ្ញៀវអន្តរជាតិមានចំនួន **៥.៦៧៩នាក់** ។

**គ.មណ្ឌលវត្តភ្នំ :**

-ភ្ញៀវទេសចរណ៍បរទេសចូលទស្សនាមាន :**៩៦.៣៧០នាក់** ។

**ឃ.មណ្ឌលឧក្រិដ្ឋកម្មជើងឯក :**

-ភ្ញៀវទេសចរណ៍បរទេសចូលទស្សនាមាន :**១៩១.៧៩៨នាក់** ។

**៣.៣. ការងារបុរាណវត្ថុ :**

-ធ្វើការសិក្សា និងពិភាក្សាលំអិត ស្តីពីប័ណ្ណប្រកាសប្រភេទបុរាណវត្ថុដែលត្រូវហាមឃាត់ការនាំចេញ និងអំពីផ្ទាំងប៉ាណូបង្ហាញអំពីទោសបញ្ញត្តិចំពោះការជួញដូរបុរាណវត្ថុខុសច្បាប់។ លោកអគ្គនាយករង នៃអគ្គនាយកដ្ឋានបេតិកភណ្ឌបានដឹកនាំមន្ត្រីជំនាញមួយក្រុមចុះពិនិត្យការងារជួសជុលព្រះវិហារអដ្ឋរស្ស នៅភ្នំព្រះរាជទ្រព្យ ខេត្តកណ្តាល ដែលបានការឧបត្ថម្ភថវិកា និងអនុវត្តផ្ទាល់ដោយក្រុមហ៊ុន ផាន ភីម៉ិច តាមការពិនិត្យជាក់ស្តែងលើការងារដែលក្រុមហ៊ុនអនុវត្តកន្លងមកបានប្រហែល៦០ភាគរយហើយ។ បានចូលរួមប្រជុំការងាររៀបចំសារមន្ទីរសម្តេចតេជោ នៅស្រុកសាអែម ខេត្តព្រះវិហារ និងខេត្តសៀមរាប។ ចុះសិក្សាស្ថានភាពខូចខាតនៃប្រាសាទកំពង់ព្រះ ដែលបានទទួលរងការបំផ្លិចបំផ្លាញដោយក្រុមហ៊ុនទូរស័ព្ទខាំឈិន និងបានចូលរួមបើកការដ្ឋានលប់រណ្តៅប្រាសាទកំពង់ព្រះ នៅស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។ សកម្មភាពការងារប្រមូល និងទទួលវត្ថុបុរាណនៅតាមមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសរុបចំនួន២១រូប-ដុំ និង១ផ្ទាំង

+ខេត្តកោះកុង : បានដឹកជញ្ជូននូវវត្ថុស្រង់ចេញពីសំពៅលិច ដែលទុកនៅក្នុងឃ្លាំង របស់ក្រុមហ៊ុន យ៉ូធីហ្វ្រីសប យកមកទុកនៅខេត្តជាបណ្តោះអាសន្ន

+ខេត្តព្រះវិហារ : បានចុះទៅប្រាសាទក្តាក់ ស្ថិតនៅឃុំត្បែង ស្រុកគូលែន ដើម្បីប្រមូលវត្ថុបុរាណ ដែលនៅរាយប៉ាយក្នុងបរិវេណប្រាសាទក្តាក់ ដើម្បីយកមករក្សាទុកក្នុងមន្ទីរ វត្ថុទាំងនោះមានទម្រយោនី០១ដុំ និងសសរពេជ្រចំនួន០៧ដុំ

+ខេត្តកំពង់ធំ : ថ្នាក់ដឹកនាំមន្ទីរ បានចុះទៅអធិការដ្ឋាននគរបាល ស្រុកប្រាសាទ បល្ល័ង្គ ដើម្បីទទួលបដិមា (លោកេស្វរ) ចំនួន០១រូប ធ្វើពីថ្មភក់ មករក្សាទុកនៅសារមន្ទីរខេត្ត

*ខេត្តព្រៃវែង : ប្រធានមន្ទីរវប្បធម៌ សហការជាមួយអាជ្ញាធរដែនដី ចុះពិនិត្យវត្ថុបុរាណចំនួន១៣រូប នៅឃុំពោធិទី ស្រុកស៊ីធរកណ្តាល ដែលប្រជាជនកាប់ដីប្រទះឃើញ បច្ចុប្បន្នវត្ថុទាំង១៣រូបនោះ រក្សាទុកបណ្តោះអាសន្ននៅផ្ទះសាមីខ្លួន ដែលរកឃើញនោះ

*ខេត្តបន្ទាយមានជ័យ : ចៅអធិការវត្តគោកព្រិច បានប្រគល់សិលាចារឹក១ផ្ទាំង ឱ្យសាលាស្រុកថ្មពួក ហើយបានប្រគល់ឱ្យមន្ទីររក្សាទុកនៅសារមន្ទីរខេត្ត ។

*<u>ការត្រួតពិនិត្យវត្ថុសិល្បៈនាំចេញ-នាំចូលមាន :</u>

+រូបនាំចេញចំនួន**៩.៦៩២រូប** ទទួលថវិកាចំនួន**៣៧.៧០០.០០០រៀល**

+រូបនាំចូលចំនួន**១១៤រូប** ទទួលថវិកាចំនួន**៨៣៥.០០០រៀល**

-ការត្រួតពិនិត្យវត្ថុសិល្បៈនៅខេត្តសៀមរាបមានចំនួនរូប**២១១រូប** ទទួលថវិកាចំនួន**១.៤៧៦.០០០រៀល**

ជាទូទៅមន្ត្រីជំនាញក្រោមឱវាទនាយកដ្ឋាន មានការយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់ ចំពោះភារកិច្ចរបស់ខ្លួន ដោយលទ្ធផលទទួលបានគួរជាទីមោទនៈ ។ ទន្ទឹមនេះក៏មានបញ្ហាប្រឈមផ្សេងៗជាច្រើន ដូចជាករណីបច្ចេកវិទ្យាទំនើបៗជាមួយភាពពេញនិយមនៃបុរាណវត្ថុខ្មែរ ក្នុងទីផ្សារជាតិ និងអន្តរជាតិ បានធ្វើឱ្យជនឱកាសនិយមមួយចំនួនតូច លួចឆ្លៀតធ្វើចរាចរបុរាណវត្ថុខុសច្បាប់តាមគ្រប់រូបភាព ព្រមជាមួយនិងសមត្ថភាពជំនាញលើការគ្រប់គ្រងបុរាណវត្ថុ របស់មន្ត្រីទទួលបន្ទុកនៅមានកម្រិត និងមធ្យោបាយផ្សព្វផ្សាយពីការទប់ស្កាត់ការធ្វើចរាចរបុរាណវត្ថុខុសច្បាប់នៅមានការខ្វះខាត ។ ប៉ុន្តែទោះបីមានការប្រឈមដូចបានរៀបរាប់ខាងលើយ៉ាងណាក៏ដោយ ជារួមសភាពការណ៍ចរាចរបុរាណវត្ថុខុសច្បាប់ ក្នុងឆ្នាំនេះ ពុំមានចំណុចគួរឱ្យបារម្ភទេ ។

### ៣.៤.ការងារបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា :

ចូលរួមសហការស្រាវជ្រាវបុរាណវិទ្យា ជាមួយសកលវិទ្យាល័យអូតាហ្គូនៅស្ថានីយ៍អូរតី ស្រុកថ្មបាំង ខេត្តកោះកុង ។ បន្តធ្វើកំណាយស្រាវជ្រាវជាមួយវិទ្យាស្ថានស្រាវជ្រាវសម្បត្តិវប្បធម៌ណារ៉ា នៅស្ថានីយ៍បុរេប្រវត្តិក្រាំងគរ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ ចូលរួមសហការស្រាវជ្រាវជាតិពន្ធុវិទ្យា ជាមួយសកលវិទ្យាល័យណានសាន (ជប៉ុន) ដែលស្ថិតក្នុងឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ។ បានចុះសហការស្រាវជ្រាវបុរាណវិទ្យាបន្តជាមួយសកលវិទ្យាល័យស៊ីដនី (អូស្ត្រាលី) ដែលស្ថិតនៅឃុំរណសិរ្ស ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ដោយមានការចូលរួមពីមន្ត្រីមកពីរាជបណ្ឌិតសភាកម្ពុជាផងដែរ ។ បានធ្វើការ

វិភាគលើបំណែកវត្ថុបុរាណដូចជា : បំណែកឈើ-សំណល់ធ្យូង-អាចម៍ដែក-បំណែករ៉ែដែកតូចៗ និងល្បាប់ភក់ ដែលបានពីការធ្វើកំណាយនៅស្ថានីយ៍ព្រះខ័ន្ធកំពង់ស្វាយ ខេត្តព្រះវិហារ និងបំណែកកុលាលភាជន៍-បំណែកឆ្អឹងសត្វ-អាចម៍ដី និងធ្មេញសត្វមានចំនួន០៦ប្រភេទ ស្មើនឹង៦៧កញ្ចប់ ដែលប្រភពបានមកពីស្ថានីយភូមិស្នាយ ខេត្តបន្ទាយមានជ័យ និងបានផ្តល់អាជ្ញាប័ណ្ណនាំចេញវត្ថុសិល្បៈគំរូទៅធ្វើការសិក្សាវិភាគនៅប្រទេសអូស្ត្រាលី។ បានធ្វើការវិភាគលើបំណែកវត្ថុបុរាណ បំណែកថ្មមានចំនួន៦៨ដុំ ដែលប្រភពបានមកពីការធ្វើកំណាយនៅស្ថានីយ៍ព្រះខ័នកំពង់ស្វាយ ខេត្តព្រះវិហារ និងបានផ្តល់អាជ្ញាប័ណ្ណនាំចេញវត្ថុសិល្បៈគំរូទៅធ្វើការសិក្សាវិភាគនៅប្រទេសអាមេរិក។ បានធ្វើការវិភាគលើបំណែកវត្ថុបុរាណដូចជា : បំណែកកុលាលភាជន៍មានចំនួន៥៦បំណែក ដែលបានមកពីស្ថានីយ៍ភូមិ១០.៨. ស្ថានីយ៍ភូមិស្នាយ. ស្ថានីយ៍ភូមិក្រសាំងថ្មី. ស្ថានីយ៍គោកវត្តចាស់ និងស្ថានីយ៍ចំការចេក-គំរូធ្មេញមានចំនួន០៦ប្រអប់ ដែលប្រភពបានមកពីស្ថានីយ៍ភ្នំបោះដំបង ស្រុកទឹកឈូ ខេត្តកំពត-ដែកហ្គ្រាមប៉ុងមានចំនួន១៧ដុំដែលរកឃើញពីព្រះបរមរាជវាំងបុរាណ ហើយបានផ្តល់អាជ្ញាប័ណ្ណឱ្យនាំចេញវត្ថុសិល្បៈគំរូ ទៅធ្វើការសិក្សាវិភាគនៅប្រទេសបារាំង។

ការងារបុរាណវិទ្យា សម្រេចបានលទ្ធផលសំខាន់ៗមានដូចខាងក្រោម :

-ធ្វើការវាស់វែង និងកំណត់ទីតាំងធ្វើកំណាយសង្គ្រោះ នៅស្ថានីយ៍ទួលសំពៅ ខេត្តស្វាយរៀង

-ចុះពិនិត្យ និងផ្ទៀងផ្ទាត់ស្ថានីយ៍បុរាណនៅខេត្តក្រចេះ-កំពង់ចាម-បន្ទាយមានជ័យ-ព្រះវិហារ-ស្វាយរៀង-កណ្តាលកោះកុង និងព្រៃវែង

-ចុះពិនិត្យ និងទប់ស្កាត់ការឈូសឆាយបំផ្លាញទួលបុរាណ និងសំណង់ផ្សេងៗក្នុងតំបន់ហាមឃាត់

-បោះបង្គោលកំណត់ដែនការពារ និងស្លាកសញ្ញាបំរាមក្នុងតំបន់ដែលមានគ្រឹះប្រាសាទបុរាណ ស្រះបុរាណ និងរមណីយដ្ឋានប្រវត្តិសាស្ត្រ ក្នុងខេត្តស្វាយរៀង-ព្រៃវែង និងខេត្តកណ្តាល

-សហការជាមួយស្ថាប័នអន្តរជាតិលើការងារស្រាវជ្រាវ និងធ្វើកំណាយបុរាណវិទ្យា នៅកម្ពុជា

-ចុះផ្សព្វផ្សាយ និងទប់ស្កាត់ការជីកកាយបំផ្លាញក្នុងតំបន់ដែនដីស្ថានីយ៍បុរាណតាមបណ្តាខេត្តមួយចំនួន។

**លទ្ធផលអវិជ្ជមាន**គឺ នាយកដ្ឋានបុរាណវិទ្យាមិនទាន់សម្រេចបានការសុំបញ្ចូលស្ថានីយ៍បុរាណ និងរមណីយដ្ឋានប្រវត្តិសាស្ត្រចូលជាសម្បត្តិបេតិកភណ្ឌវប្បធម៌ជាតិឱ្យបានទាន់ពេលវេលានៅឡើយ ។

ឆ្នាំនេះការងារសម្រេចបានលទ្ធផលល្អប្រសើរលើការគ្រប់គ្រងដែនដីបុរាណវិទ្យា និងកិច្ចសហការស្រាវជ្រាវជាមួយស្ថាប័នបរទេស។ យើងបន្តការគ្រប់គ្រង និងផ្សព្វផ្សាយ ដល់ប្រជាពលរដ្ឋឱ្យចូលរួមទាំងអស់គ្នា ដើម្បីការពារ ថែរក្សាសម្បត្តិបេតិកភណ្ឌវប្បធម៌ជាតិ។

### ៣.៥.ការងារបេតិកភណ្ឌរូបីរាជធានី-ខេត្ត :

**មន្ទីររាជធានីភ្នំពេញ** រៀបចំថែរក្សាការពារសណ្តាប់ធ្នាប់ សោភ័ណភាព អនាម័យមណ្ឌលវត្តភ្នំបានល្អជាប្រចាំ។ បានធ្វើការស្តារប្រឡាយ លូ ជុំវិញមណ្ឌលវត្តភ្នំ និងបានសហការជាមួយមន្ទីរសាធារណៈការរាជធានីភ្នំពេញ កាត់ដើមឈើខ្ពស់ៗ ដើម្បីការពារកុំឱ្យរលំត្រូវភ្ញៀវ និងបាក់ជណ្តើរ។ បានធ្វើការជួសជុលកែលម្អព្រះវិហារវត្តភ្នំរយៈពេល០៦ខែ ចាប់ពីថ្ងៃទី០១.០២

២០១១ ដល់ថ្ងៃទី១៥.០៧.២០១១ ក្នុងទ្រង់ទ្រាយធំ ដោយបានសម្រេចជាស្ថាពរ ហើយសាលារាជធានីភ្នំពេញបានសហការរៀបចំធ្វើពិធីបុណ្យឆ្លងព្រះវិហារវត្តភ្នំ ក្រោមអធិបតីភាពឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋ មន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី។ បានចុះបញ្ជីព្រះពុទ្ធរូបទាំងអស់ក្នុងព្រះវិហារវត្តភ្នំដើម្បីចងក្រងជាឯកសារមុនពេលធ្វើការជួសជុល។ បានរៀបចំកៅអីវែងអង្គុយចំនួន១០០ដាក់លម្អ និងសម្រាប់ទទួលភ្ញៀវទេសចរណ៍ក្នុងតំបន់រមណីយដ្ឋានដែលជាការឧបត្ថម្ភពីសាលារាជធានី និងធនាគារ សាខេម។ បានសហការជាមួយមន្ត្រីអាជ្ញាធរមូលដ្ឋាន, មន្ត្រីមន្ទីរធម្មការ, គណៈកម្មការវត្ត, អង្គការ UNESCO ដើម្បីចុះពិនិត្យៈ នៅវត្តព្រះធាតុ ខ័ណ្ឌដង្កោ ដោយធ្វើការត្រួតពិនិត្យក្នុងវត្តឃើញថាមានវត្ថុបុរាណ(ជាថ្ម) ចំនួន១០៦ដុំ ដែលទទួលរងការខូចខាត-នៅសង្កាត់ជើងឯកមានផលប៉ះពាល់ចំពោះភូមិមូល និងឡបូរាណត្រូវធ្វើកំណាយសង្គ្រោះបន្ទាន់ដែលតំណាងអង្គការយូណេស្កូនឹងត្រូវស្នើទៅក្រសួង ដើម្បីរៀបចំឯកសារ-នៅវត្តព្រៃវែង សង្កាត់ព្រៃវែង ខ័ណ្ឌដង្កោបានចូលរួមប្រគល់ និងទទួលសិលាចារឹកដែលមានអាយុជាង១០០០ឆ្នាំ ឱ្យទៅសារមន្ទីរជាតិធ្វើការជួសជុល ដោយមានការចូលរួមពីលោកស្រីប្រធាននាយកដ្ឋានសារមន្ទីរជាតិ និងលោកជំទាវ ក្រូច សំអាន សមាជិកសភាមណ្ឌលភ្នំពេញ ។

**មន្ទីរខេត្តកណ្តាល** ធ្វើសំណើទៅក្រសួងសុំចុះបញ្ជីរសារពើភណ្ឌនូវស្ថានីយ៍បុរាណចំនួន៤២២កន្លែង ក្នុងភូមិសាស្ត្រខេត្តកណ្តាល។ ពុទ្ធបរិស័ទ ព្រះសង្ឃបន្តសាងសង់ព្រះបដិមាអង្គធំដែលមានព្រះភ្នែនប្រវែង៥៦ម៉ែត្រ និងកម្ពស់៥៦ម៉ែត្រនៅវត្តទួលរាជា ស្រុកកោះធំ។ នៅស្រុកកណ្តាលស្ទឹងបានស្រាវជ្រាវរកឃើញទួលបុរាណចំនួន០២ទួលមាន ទួលអង្គតូចមានផ្ទៃដី៥៨៧ម៉ែត្រការ៉េ លេខក្បាលដី៣.៩២ និងទួលអង្គធំមានផ្ទៃដី១.១៨៧ម៉ែត្រការ៉េ លេខក្បាលដី១.១៨៤ ដែលស្ថិតនៅភូមិព្រែករកា ឃុំព្រែករកា។ បានទទួលព្រះពុទ្ធបដិមាចំនួន១៦១ព្រះអង្គ ពីពុទ្ធបរិស័ទមកតម្កល់ទុកក្នុងព្រះសត្យមុនីចេតីយ៍ ដែលមកដល់បច្ចុប្បន្ន សរុបព្រះពុទ្ធបដិមាអង្គតូច-ធំមានចំនួន៤.០២៧អង្គ។ បានទទួលយកវត្ថុបុរាណចំនួន០៣គឺ : កំណាត់ខ្លួននាគ០២ និងស្ពានទ្រោនី០១ កសាងពីថ្មភក់សម័យអង្គរ រកឃើញនៅទួលព្រៃក្តី ឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង ពីអធិការដ្ឋាននគរបាលស្រុកកណ្តាលស្ទឹង ដើម្បីយកទៅរក្សាទុកនៅសារមន្ទីរជាតិ។ លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស បានឧបត្ថម្ភថវិកាថ្លៃភ្លើងដែលគិតពីដើមឆ្នាំមកដល់ពេលនេះសរុបថវិកាចំនួន១៣.៣៤៦.៧០០រៀល និងឧបត្ថម្ភថវិកាចំនួន២.០០០.០០០រៀលដល់ក្រុមឆ្មាំភ្នំព្រះរាជទ្រព្យ។ បានរៀបចំពិធីបុណ្យវិសាខបូជានៅភ្នំព្រះរាជទ្រព្យ ស្រុកពញាឮ ក្រោមអធិបតីភាពសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា និងលោកជំទាវ និងមានពិធីរាប់បាតព្រះសង្ឃចំនួន៣០០អង្គ។ ការជួសជុលព្រះវិហារធំលើភ្នំព្រះរាជទ្រព្យ ស្រុកពញាឮ កំពុងបន្តសកម្មភាព ដោយប្រក់ដំបូលរួចរាល់១០០ភាគរយ ហើយបូកជញ្ជាំងខាងក្នុងហើយជាស្ថាពរ។ ស្រុកខ្សាច់កណ្តាល បានសហការជាមួយអាជ្ញាធរឃុំសន្លុង ចុះវាស់ និងកំណត់ព្រំប្រទល់ទួលបុរាណមួយកន្លែងឈ្មោះទួលកំផ្លុង មានបណ្តោយខាងកើត៨០០ម៉ែត្រ បណ្តោយខាងលិច៦៥០ម៉ែត្រ ទទឹងខាងជើង១០០ម៉ែត្រ ទទឹងខាងត្បូង២០០ម៉ែត្រ មានផ្លូវកាត់ទទឹងប្រវែង៣០០ម៉ែត្រ លើទួលមានដើមត្នោតជាច្រើន មានផ្នូរ និងម៉ុងចំនួន៣២ មានចំការឪឡឹក សណ្តែកដែលប្រជាពលរដ្ឋចំនួន១១គ្រួសារកំពុងបង្កបង្កើនផលនៅលើទួលនោះ។ បានបោះបង្គោលកំណត់ព្រំប្រទល់ស្ថានីយ៍បុរាណបាន០៥ទួលគឺៈ នៅស្រុកពញាឮ៣ទួល-ស្រុកកណ្តាលស្ទឹង១ទួល និងស្រុកអង្គស្នួល១ទួល។ នៅស្រុកកោះធំ លើទួលគុហារកំពុង

កសាងសាលាធម្មសភាបានចំនួន៤០ភាគរយហើយ និងដាំកូនឈើគ្រប់ប្រភេទបានចំនួន១៨.០០០កូនហើយនៅមណ្ឌលឧក្រិដ្ឋកម្មពោធិទន្លេ សប្បុរសជនឈ្មោះ ឆាយ ឈនគួង បានចេញថវិកាផ្ទាល់ខ្លួនជួសជុលសាលាឆទានអស់ថវិកាចំនួន១.២០០ដុល្លា និងទិញតុថ្មចំនួន០៤សម្រាប់ អស់ថវិកាចំនួន៧៤៤ដុល្លាសម្រាប់ដាក់នៅទីនោះ។ បានប្រគល់វត្ថុបុរាណ៣ដុំ/ផ្ទាំង ទៅរក្សាទុកនៅសារមន្ទីរជាតិ វត្ថុនេះបានរកឃើញនៅស្រុកកណ្ដាលស្ទឹង ។

**មន្ទីរខេត្តតាកែវ** បានចុះផ្សព្វផ្សាយច្បាប់ ស្ដីពីកិច្ចការពារបេតិកភណ្ឌជាតិ ដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានស្រុក ជាពិសេសប្រជាពលរដ្ឋនៅតាមមូលដ្ឋានស្រុកដែលមានប្រាសាទបុរាណ ដោយណែនាំឱ្យយល់ដឹងអំពីតម្លៃវប្បធម៌បេតិកភណ្ឌជាតិ ឱ្យគាត់មានស្មារតីភ្ញាក់រលឹកចូលរួមរក្សាការពារផ្ទាល់ក្នុងមូលដ្ឋានរបស់គាត់។ បានចុះស្រាវជ្រាវទួលអង្គបុរាណនៅតាមមូលដ្ឋានស្រុកបានចំនួន៦៤២ទួលអង្គ និង ចុះពិនិត្យទួលអង្គ នៅឃុំលាយបូរ ព្រមទាំងធ្វើការហាមឃាត់ការជីកយកដីចាក់ធ្វើសំណង់នៅជិតទួលអង្គនោះបាន០១លើក និងបានធ្វើសាលាកប័ត្រទទួលស្គាល់ទួលអង្គបានចំនួន៥៣៨ទួលអង្គ និង ចុះកាប់ឆ្ការព្រៃតាមប្រាសាទបាន០៥លើក។ សហការជាមួយមន្ត្រីជំនាញសារមន្ទីរជាតិ ដើម្បីរៀបចំកែលម្អសារមន្ទីរស្រុកអង្គរបុរី និងរៀបចំដាក់តាំងវត្ថុសិល្បៈនៅក្នុងសារមន្ទីរ ដើម្បីជូនភ្ញៀវទេសចរណ៍ទស្សនា។ ភ្ញៀវចូលទស្សនាសារមន្ទីរខេត្តមានចំនួន៣៥០នាក់ អន្តរជាតិ១៤នាក់ និងសារមន្ទីរស្រុកអង្គរបុរីមានចំនួន៨២៥នាក់ ក្នុងនោះអន្តរជាតិ២០៥នាក់ ។

**មន្ទីរខេត្តកំពត** ជូនដំណឹងដល់ការិយាល័យវប្បធម៌ក្រុង-ស្រុកដើម្បីចូលរួមពិធីវិនិច្ឆ័យជាសាធារណៈឯកសារដីធ្លីពិសេសមូលដ្ឋានមានប្រាសាទ ទួលបុរាណ។ ធ្វើសំណើចំណាត់ថ្នាក់ប្រាសាទ ទួលអង្គ ស្រះបុរាណ ផ្ទះបុរាណ ស្ពានបុរាណ និងវត្ថុបុរាណទៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ សហការជាមួយក្រុមប្រឹក្សាស្រុកឈូក ក្នុងការផ្សព្វផ្សាយ និងប្រមូលបច្ច័យបុណ្យផ្កាសាមគ្គី សម្រាប់កសាងជណ្ដើរឡើងប្រាសាទភ្នំថ្មពូក។ សម្របសម្រួលការងារបន្តគម្រោងស្រាវជ្រាវរកសំណល់ផ្លូស៊ីល និងសិក្សាភូមិសាស្ត្ររបស់សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នៅភ្នំឈ្វោក ស្រុកទឹកឈូ និងភ្នំល្អាង ស្រុក ដងទង់។ លើកស្លាកស្ដីពីការការពារសម្បត្តិបេតិកភណ្ឌបានចំនួន៣ផ្ទាំង នៅរមណីយដ្ឋានភ្នំក្បាលរមាស និងប្រាសាទភ្នំថ្មពូក និងបានបោះបង្គោលកំណត់តំបន់ការពារប្រាសាទ។ សហការជាមួយអាជ្ញាធរដែនដី ចុះរុះរើរបងដែលធ្វើបំពានលើតំបន់ការពារស្ថានីយ៍ភ្នំក្បាលរមាស និងរមណីយដ្ឋានប្រាសាទភ្នំឈ្វោក។

**មន្ទីរខេត្តកែប** បានចុះសហការជាមួយអាជ្ញាធរក្រុងកែប ត្រួតពិនិត្យការដាក់តាំងរូបសំណាកព្រះបាទជ័យវរ្ម័នទី៧ នៅមុខហាងលក់អង្កាំយីហោLiLi perles ក្រុមការងារបានណែនាំដល់ម្ចាស់ហាងឱ្យយកចេញ ព្រោះជារូបសំណាកសម្រាប់គោរពត្រូវយកចេញទៅដាក់នៅកន្លែងសមរម្យណាមួយ ក្រោយពីមានការណែនាំមកម្ចាស់ហាងបានរើយកចេញរួចរាល់ហើយ។ ទួលអង្គបុរាណមានចំនួន០៨កន្លែង និងបានចុះស្រង់ស្ថិតិទួលអង្គបុរាណបានចំនួន០២លើក។ បានសហការជាមួយគណៈកម្មការវត្តបោសសំអាត និងកាប់ឆ្ការព្រៃផ្លូវចូលរូង និងជុំវិញបរិវេណរមណីយដ្ឋានភ្នំសសៀរបានជាប្រចាំ និង បានចូលរួមបើកឯកសារដេញថ្លៃសាងសង់សារមន្ទីរជំហានទី២ ឆ្នាំ២០១១ ។

**មន្ទីរខេត្តព្រះសីហនុ** ចុះទៅសហការជាមួយអភិបាលស្រុកព្រៃនប់ ដើម្បីផ្សព្វផ្សាយនូវប្រធានបទ ស្ដីពី "រួមគ្នាទប់ស្កាត់ និងអំពើចោរកម្ម ចរាចរ និងជួញដូរវត្ថុបុរាណដោយខុសច្បាប់ ក្នុងការពង្រឹងកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្នុងព្រះរាជាណាចក្រ

កម្ពុជា" ដែលជាទិសដៅរបស់ក្រសួង មានការចូលរួមឃុំទាំង១៤ និងការិយាល័យដែលចំណុះឱ្យស្រុកព្រៃនប់ទាំងអស់។ បានទទួលវត្ថុបុរាណពីសាលាស្រុកព្រៃនប់ (ដែលប្រជាជនជីកបាន) មានដូចជា : ផ្លែដែកជីងភ្លុកចំនួន០៨-ផ្លែដែកជីងដង ចំនួន ០៤-ផ្លែដែកពន្លាកចំនួន០៦-ផ្លែកាំបិតដែកចំនួន០៧-ប្រអប់ស្លាម្លូ(ស្ពាន់)ចំនួន០៨-ស្នៀតដែកចំនួន២៣-ក្រឡត្រចៀកបួន (ដី) ចំនួន០១ ប្រអប់តូច (ប្រាក់)ចំនួន០១ និងកងដែកចំនួន០៦ ។

**មន្ទីរខេត្តកោះកុង** បានធ្វើការសំអាតថែរក្សាចេតិយ ឃុន ឆាង និងបុស្បុក តម្កល់ព្រះអង្គគោកធ្លោកជាប្រចាំ-មន្ទីរបានចាត់តាំងឱ្យឆ្មាំចំនួន០២នាក់ ថែរក្សាការពារម្លូស នៅភ្នំប៉ៃល ឃុំជីផាត ស្រុកថ្មបាំង និងឆ្មាំ០១រូបថែរក្សាការពារអណ្តូងថ្ម នៅឃុំអណ្តូងទឹក ស្រុកបុទុមសាគរ។ បានចុះទៅស្រុកមណ្ឌលសីមា ដើម្បីទំនាក់ទំនងអំពីព្រំប្រទល់ដី ឃុន ឆាង។ បានអនុញ្ញាតឱ្យលោកស្រី Dr. Nancy Bravan ក្រុមស្រាវជ្រាវ នៃសកលវិទ្យាល័យអូតាហ្គូ ចុះស្រាវជ្រាវបុរាណវិទ្យាបន្តនៅស្ថានីយ៍ភ្នំពើង និងអូរកី ស្រុកថ្មបាំង។ មន្ទីរបានស្នើសុំឯកឧត្តមអភិបាលខេត្តបង្កើតនូវគណៈកម្មការរៀបចំកំណត់ទំហំរមណីយដ្ឋានប្រវត្តិសាស្រ្ត នៅទូទាំងខេត្តកោះកុង។

**មន្ទីរខេត្តកំពង់ស្ពឺ** បានទទួលរូបសំណាកចំនួន២រូប ពីសប្បុរសជនមកតម្កល់ទុកសម្រាប់ប្រជាពលរដ្ឋគោរពបូជានៅរមណីយដ្ឋានបុរាណវិទ្យាភ្នំចាស់គឺ: រូបមេកន្រ្ទាញបាភ្នំចាស់ និងរូបលោកតាមាន់ប្រាំបី។ ប្រជាពលរដ្ឋបានប្រទះឃើញខ្មោចដំរីមួយ ដែលមានឆ្អឹងដំរីមួយយ៉ាងធំនៅក្នុងរណ្តៅ ដែលស្ថិតនៅឃុំប្រាំបីមុម ស្រុកថ្ពង ហើយក៏បានធ្វើការគាស់យកឆ្អឹងដំរីមករក្សាទុកនៅមូលដ្ឋានភ្នំបាត ស្ថិតនៅឃុំប្រាំបីមុម ស្រុកថ្ពង។ បានចុះពង្រឹងសហគមន៍សែនមនោរម្យ នៅរមណីយដ្ឋានបុរាណវិទ្យាភ្នំចាស់ ដើម្បីរក្សាការពារសមិទ្ធផលជាប់ជាប្រចាំ និងបានទទួលការចូលរួមពីសប្បុរសជនកសាងខឿនតំកល់ពុទ្ធរូបកំពស់០១ម៉ែត្រ ទំហំ៩ម×៩ម និងឆ័ត្រប្រាំថ្នាក់ បាំងលើព្រះពុទ្ធរូប។ បានរៀបចំបំពេញសំណុំឯកសារគ្រឹះប្រាសាទគុហារមានឫទ្ធិ ស្ថិតនៅភូមិទំនប់បាក់ ឃុំដំណាក់រាំង ស្រុកឧដុង្គ មានផ្ទៃដី៤៨.០០០ម៉ែត្រការ៉េ ដើម្បីសុំបញ្ចូលជាសម្បត្តិបេតិកភណ្ឌជាតិ និងធ្វើការអភិរក្ស អភិវឌ្ឍគ្រឹះប្រាសាទឱ្យទៅជារមណីយដ្ឋានវប្បធម៌។ មន្ទីរបានសហការជាមួយនឹងអាជ្ញាធរក្រុងច្បារមន ចុះត្រួតពិនិត្យកែតម្រូវស្តូបទេវរូបដៃប្រាំមួយ នៅស្ថានីយ៍សាំងផ្លូវបំបែកច្បារមន ឱ្យមានលក្ខណៈក្បាច់បុរាណខ្មែរ។ បានចុះពិនិត្យមើលវត្ថុបុរាណនៅវត្តបង់បត់ ឃុំព្នាយ ស្រុកសំរោងទងមានយោនីចំនួន០២ ធ្វើអំពីថ្មថ្លើមអណ្តើក (សម័យក្រោយអង្គរ) និងបង្គោលឬសសីម៉ាចំនួន៤ ធ្វើអំពីថ្មភ្នំ(សម័យក្រោយអង្គរ) ត្រូវបានព្រះគ្រូចៅអធិការ លោកអាចារ្យរក្សាទុកក្នុងវត្ត។ ភ្ញៀវចូលទស្សនាសារមន្ទីរនរបូរីមានចំនួន៥.៥៦៤នាក់ អន្តរជាតិ០៨នាក់ ។

**មន្ទីរខេត្តកំពង់ឆ្នាំង** ធ្វើពិធីក្រុងពាលីបើកការដ្ឋានស្តារ និងជួសជុលឡើងវិញប្រាសាទកំពង់ព្រះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្រ្តីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឯកឧត្តម លោកជំទាវអមដំណើរ និងឯកឧត្តម ម៉ែន ធឿន ប្រធានក្រុមប្រឹក្សាខេត្ត និងប្រតិភូអមដំណើរ។ ឯកឧត្តម ជុច ភឿន រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងឯកឧត្តម លោកជំទាវប្រតិភូអមដំណើរចុះពិនិត្យអ្នកបច្ចេកទេសដែលកំពុងជួសជុល និងស្តារឡើងវិញប្រាសាទកំពង់ព្រះ។ ក្រុមអ្នកជំនាញស្តារ និងជួសជុលប្រាសាទកំពង់ព្រះទាំងពីរជំហ៊ានអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយជោគជ័យ។ មន្ត្រីជំនាញការិយាល័យបេតិកភណ្ឌ ជាមួយមន្ត្រីវប្បធម៌ស្រុក អាជ្ញាធរមូលដ្ឋានបានចុះកំណត់ព្រំប្រទល់ទួលបុរាណបានចំនួន៤៣កន្លែង ក្នុងនោះស្រុក

កំពង់លែង២៩កន្លែង និងស្រុកកំពង់ត្រឡាចចំនួន១០កន្លែង។ សហការជាមួយប្រតិភូវិទ្យាស្ថានស្រាវជ្រាវជាតិណារ៉ា ចុះធ្វើកំណាយលើកទី២ នៅភូមិក្រាំងគរ ឃុំថ្មឥដ្ឋ ស្រុកកំពង់ត្រឡាច ។

**មន្ទីរខេត្តពោធិសាត់** បានទទួលព្រះបដិមា០១ព្រះអង្គ ពីអធិការដ្ឋានស្រុកក្រគរ។ បានចូលរួមសហការជាមួយសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ជនជាតិអូស្ត្រាលី និងជនជាតិបារាំង ចុះទៅភូមិកានម ស្រុកភ្នំក្រវាញ បានរកឃើញក្អាមឈូសបុរាណ០១-ឆ្អឹងមួយចំនួន និងពិនិត្យឃើញរូបគំនូរនៅលើផ្ទាំងថ្ម ហើយបានយកកំទេចថ្មទៅធ្វើការពិសោធន៍។ ចុះផ្សព្វផ្សាយទប់ស្កាត់ការគាស់កាយនៅទួលវត្តចាស់ ភូមិត្រពាំងឃ្លៃ ឃុំបឹងកន្ទួត ស្រុកក្រគរ និងទប់ស្កាត់ការសាងសង់សំណង់នៅក្បែរទីទួលបុរាណវត្តចាស់ ឃុំបឹងកន្ទួត ស្រុកក្រគរ មិនឱ្យធ្វើបន្តទៀត ។ ចុះស្រាវជ្រាវទីទួលបុរាណ នៅភូមិតាំណៃ ឃុំអូតាប៉ោង ស្រុកបាកាន និងបានទទួលរូបសំណាកទេវរូបចំនួន០១ ពីអភិបាលស្រុកបាកាន។ ជួសជុលរបងសារមន្ទីរ ជួសជុលរៀបចំសួនក្នុងបរិវេណសារមន្ទីរ-ជួសជុលជើងពានបង្កាន់ដៃនៃអាគារសារមន្ទីរ និងបានទទួលវត្ថុបុរាណពីប្រជាជនជីកស្រះនៅស្រុកបាកាន (បាក់ជាបីចំណែក)។ ទទួលព្រះពុទ្ធរូបបុរាណ១អង្គ ពីអធិការដ្ឋានស្រុកក្រគរ ។

**មន្ទីរខេត្តបាត់ដំបង** បានចុះទៅពិនិត្យទួលបុរាណនៅស្រុកសង្កែ ដើម្បីគូរប្លង់កន្លែងជីឡូត៍ និង ការដ្ឋានសាងសង់ដោយកន្លែងជីករណ្តៅបានប្រទះឃើញបំណែកក្រឡ និងឆ្អឹងខ្មោច។ ចុះទទួលវត្ថុបុរាណពីប្រជាជនក្នុងស្រុករតនៈមណ្ឌលចំនួន០១ដុំ (ព្រះវិណ្ណុដៃប្រាំបី អំពីលោហធាតុ)-ពីប៉ុស្តិ៍នគរបាលឃុំនរា ស្រុកសង្កែចំនួន០២ព្រះកេស-ប៉ុស្តិ៍នគរបាលស្រុកឯកភ្នំចំនួន០២ព្រះកេស-ពីធនាគារជាតិខេត្តបាត់ដំបងចំនួន០២ព្រះកេស-បានទទួលវត្ថុបុរាណពីអធិការដ្ឋាននគរបាលស្រុកថ្មគោលយកមករក្សាទុកក្នុងសារមន្ទីរមានជាគ្រឿងស្ពាន់ចំនួន៧គ្រឿង គំរបផ្ទាំងដីដុត០១បែកជាពីរបំណែក ថ្មកិនថ្នាំមួយកំណាត់ និងបានទទួលដាវបុរាណមួយពីលោកតា ឆេង ទ្រី នៅសង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង។ បានចុះទៅវត្តស្លាកែត ដើម្បីពិនិត្យវត្ថុសិល្បៈជាមួយមន្ត្រីនគរបាលក្រុងបាត់ដំបងដែលកំពុងធ្វើបញ្ជីសារពើភណ្ឌ និង បានចុះទៅសាលាដំបូងខេត្តបាត់ដំបងដើម្បីទទួលជួងធ្វើអំពីស្ពាន់មានអាយុ៦៥ឆ្នាំ ទំងន់៦៧គ.ក្រ។ បានចូលរួមជាមួយមន្ត្រីមកពីនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ បានចុះទៅកំណត់ព្រំប្រទល់ដែនការពារប្រាសាទបាណន់ ប្រាសាទស្នឹង និងប្រាសាទឯកភ្នំទុកជាសម្បត្តិបេតិកភណ្ឌជាតិ។ បានចូលរួមដោះស្រាយទួលបុរាណចំនួន០៨កន្លែង ទួលទាំង០៨នោះ លោក ឡាយ សៃ មេឃុំ តាពូង បានប្រគល់មកឱ្យមន្ទីរវប្បធម៌ខេត្តគ្រប់គ្រងវិញសរុបចំនួនទួល និងបឹងបុរាណ ក្នុងភូមិប៉ោយសំរោង ដែលទទួលបានជាកម្មសិទ្ធិរបស់រដ្ឋ ជាសម្បត្តិបេតិកភណ្ឌគឺចំនួន១០ទួល និងបឹង០១។ មន្ត្រីនគរបាលក្រុងបាត់ដំបង ដោយមានការជួយសហការពីខាងមន្ទីរធម្មការ និងសាសនាបានចុះធ្វើបញ្ជីសារពើភណ្ឌបានចំនួន២២វត្ត និងអាស្រម០១ សរុបលទ្ធផលការធ្វើបញ្ជីសារពើភណ្ឌបានៈ ថ្មចំនួន៤៦២ដុំ-លោហៈចំនួន៨១៤ដុំ-ឈើចំនួន៤២០ដុំ និងកុលាលភាជន៍ចំនួន១៨៦ដុំ។ សារមន្ទីរខេត្តបានធ្វើបញ្ជីសារពើភណ្ឌបានចំនួន២០៦ដុំថែមទៀត ហើយប្រមូលវត្ថុបុរាណចូលសារមន្ទីរសរុបបានចំនួន២៦វត្ថុ និងអង្កាំ០១កញ្ចប់។ បានទទួលវត្ថុបុរាណចំនួន០២ប្រភេទគឺ : អង្កាំ និង ចានអំពីដីដុតចំនួន០១ពីប្រជាជនក្រុងបាត់ដំបង។ នៅសារមន្ទីរខេត្តមានវត្ថុបុរាណសរុបចំនួន១.៣៨២ដុំ ក្នុងនោះមានថ្មចំនួន៨០៨ដុំ-លោហៈចំនួន៣៤៩ដុំ កុលាភាជន៍ចំនួន១៨៤ដុំ និងឈើចំនួន៤១ដុំ និងនៅសារមន្ទីរវត្តពោធិវាលមាន២៨៣ដុំ បានធ្វើបញ្ជីសារពើភណ្ឌរួចហើយ ក្នុងនោះមានថ្មចំនួន២១៨ដុំ និងឈើចំនួន៦៥ដុំ។ ភ្ញៀវចូលទស្សនាសារមន្ទីរខេត្តចំនួន៨៧៨នាក់ ក្នុងនោះភ្ញៀវ

បរទេសមានចំនួន១១៣នាក់ ។ ជារួម រយៈពេលមួយឆ្នាំនេះ មន្ទីរបាត់ដំបងសម្រេចលើការងារបេតិកភណ្ឌគឺ ៖ បានចុះកំណត់ទួលបុរាណចំនួន៦៧ទួល-ផ្ដិតមេដៃលើសំណុំឯកសារបាន២៣ទួល-ទទួលកម្មសិទ្ធិជាសម្បត្តិរដ្ឋបាន២៨ទួល-ទទួលបានប័ណ្ណកម្មសិទ្ធិចំនួន២០ទួល-ទទួលប្រាក់បានមកពីមូលនិធិប្រាសាទមានចំនួន៦៥៥.០០០រៀល និងបានអនុញ្ញាតដឹករូបវត្ថុសិល្បៈផលិតផលថ្មីនាំចេញក្រៅខេត្តមានចំនួន៦១៧ច្បាប់ ។

**មន្ទីរខេត្តប៉ៃលិន** បានចុះទៅពិនិត្យមើលជាងកសាងព្រះពុទ្ធរូបមួយអង្គ នៅលើភ្នំយ៉ាត និងមើលជាងកសាងអាសនៈឱ្យលោកយាយយ៉ាត ។ បានចុះទៅពិនិត្យមើលជាងជួសជុលចេតិយនៅលើភ្នំយ៉ាតជាបន្តបន្ទាប់ ហើយចេតិយជួសជុលបានចំនួន៨០ភាគរយហើយ ។ បានទទួលខោអាវឆ្នាំប្រាសាទចំនួន១០កំផ្លេរពីក្រសួង និង បានចុះទៅពិនិត្យមើលជាងកសាងសារមន្ទីរនៅវត្តអូរច្រា ក្រោមម្ចាស់ជំនួយអង្គការយុវសន្តិភាព ។

**មន្ទីរខេត្តបន្ទាយមានជ័យ** បានសហការជាមួយ CMAC ដើម្បីបោសសំអាតយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នៅតាមបរិវេណកំពែងដី ជុំវិញប្រាសាទបន្ទាយឆ្មារ ។ បានចូលរួមក្នុងពិធីប្រកាសកំណត់តំបន់វិនិច្ឆ័យលើការចុះបញ្ជីដីធ្លី មានលក្ខណៈជាប្រព័ន្ធនៅឃុំបត់ត្រង់ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ។ ភ្ញៀវជាតិ-អន្តរជាតិចូលទស្សនាប្រាសាទបន្ទាយឆ្មារមានចំនួន៧៣៥នាក់ ស្រី១៥០នាក់ ។ បាននិងកំពុងរៀបចំជួសជុលសារមន្ទីរខេត្ត ធ្វើជើងទម្រវត្ថុបុរាណចំនួន១២៦ជើងទម្រ សម្រាប់ដាក់តាំងវត្ថុបុរាណ និងបានធ្វើរបងដែកមុខសារមន្ទីរប្រវែង៦១,៧០ម៉ែត្រ និងទ្វារដែកកំពស់២,៧០ម៉ែត្ររួចជាស្រេច ។ បានចុះពិនិត្យនិងវាយតម្លៃវត្ថុសិល្បៈ០១រូបនៅច្រកបឹងត្រកួនដែលមានច្បាប់នាំចេញទៅថៃ តែត្រូវសមត្ថកិច្ចឃាត់ទុក ហើយបានប្រគល់ជូនម្ចាស់ដើមវិញ ។ បានទទួលគណៈប្រតិភូវៀតណាមខេត្តដុងថាប់ចំនួន៤២នាក់ ចូលទស្សនាសារមន្ទីរទេពកោសាស្ទាយ ។ ភ្ញៀវជាតិអន្តរជាតិ ចូលទស្សនាសារមន្ទីរទេពកោសាស្ទាយសរុបចំនួន៦៧៦នាក់ ស្រី១៣០នាក់ ។

**មន្ទីរខេត្តឧត្តរមានជ័យ** បានចូលរួមស្រាវជ្រាវ និងពិនិត្យទួលប្រាសាទចំនួន១០កន្លែង និងទួលផ្នូរបុរាណ១កន្លែង និងពិនិត្យទួលប្រាសាទនាងពួនយំដែលមានកសិណពីរជាន់ ស្ថិតនៅភូមិស្លែង សង្កាត់កូនក្រៀល ក្រុងសំរោង ។ បានចុះស្រាវជ្រាវពិនិត្យទួលឆ្អឹងខ្មោចបុរាណ នៅសង្កាត់កូនក្រៀល ក្រុងសំរោង និងបានចុះពិនិត្យស្រាវជ្រាវនៅៈ ទួលប្រាសាទទេពប្រណម-ទួលប្រាសាទអារក្សបាក់ក នៅភូមិឈើក្រំ-ទួលថ្នល់ត្រយឹង ដែលជាកន្លែងសិប្បកម្មឡបុរាណនៅភូមិស្លែង ស្រុកចុងកាល់-ទួលប្រាសាទ នៅភូមិគោកប្រាសាទ និងទួលបុរាណចោងហោង នៅភូមិកូនក្រៀល ។ ចុះត្រួតពិនិត្យផ្ទៃដីសាងសង់អភិរក្សដ្ឋានស្ថិតនៅស្រុកបន្ទាយអំពិល-ពិនិត្យស្ថានភាពប្រាសាទបុរាណខ្នារចានៅស្រុកត្រពាំងប្រាសាទ និងកាប់ឆ្ការសំអាតព្រៃឈើក្នុងបរិវេណស្ពានអូរជីក ស្រុកចុងកាល់ ។ បានចុះសិក្សាលើតំបន់ប្រាសាទបុរាណក្នុងគម្រោងបោះបង្គោលកំណត់ដែនប្រាសាទ និងបានរៀបចំឯកសារលើគម្រោងសាងសង់សារមន្ទីរខេត្ត ។

**មន្ទីរខេត្តព្រះវិហារ** បានចុះទៅទទួលវត្ថុបុរាណពីឆ្នាំប្រាសាទក្តក់មាន ៖ សសរពេជ្រ០៧ដុំ និងទម្រយោនី០១ដុំ និងចុះប្រមូលដឹកវត្ថុបុរាណតាមបណ្ដាស្រុកបានចំនួន១៤ដុំ ។ សកម្មភាពឆ្នាំត្រួសត្រាយព្រៃតាមប្រាសាទបានចំនួន២២៤.១២៧ម៉ែត្រការ៉េ ។ ភ្ញៀវចូលទស្សនាប្រាសាទព្រះខ័នមានចំនួន៥៧៥នាក់ អន្តរជាតិ២៧៨នាក់-ប្រាសាទក្រពុំឈូកចំនួន៦៦នាក់ អន្តរជាតិ០៦នាក់ និងប្រាសាទព្រះលានចំនួន១៧នាក់ អន្តរជាតិ០៧នាក់ ។ បានផ្សព្វផ្សាយ និងធ្វើការហាមឃាត់ដល់ប្រជាពលរដ្ឋកុំឱ្យ

កាប់គាស់យកដីនៅក្នុងតំបន់ប្រាសាទដើម្បីធ្វើស្រែចំការ នៅប្រាសាទខ្នាសែនកែវ ស្ថិតក្នុងភូមិស្របាល ឃុំភ្នំពេញ ស្រុកគូលែន ចំនួន០២លើក និងបានហាមប្រជាពលរដ្ឋមិនឱ្យធ្វើស្រែក្នុងកំពែង ប្រាសាទព្រះខ័ន្ត ក្នុងឃុំរណសិរ្សចំនួន០១លើក។ បានចុះវាស់វែងកំណត់ព្រំប្រទល់តំបន់ប្រាសាទ នៅឃុំភ្នំពេញ ស្រុកគូលែន ០១លើក។ បានណែនាំឱ្យក្រុមអភិរក្សចុះត្រួតពិនិត្យ ស្រាវជ្រាវរកឃើញថ្មីមានៈ ស្រះចំនួន០៥កន្លែង និងបឹង០១កន្លែង។ បានចុះបញ្ជីសារពើភណ្ឌវត្ថុបុរាណរួចរាល់ហើយចំនួន១៤២ដុំ។ ចុះកំណត់ព្រំដីជាមួយក្រុមហ៊ុន ឡាន ហ្វេ នៅស្រុកត្បែងមានជ័យចំនួន០១លើក ។

**មន្ទីរខេត្តសៀមរាប** ចុះស្រង់ទិន្នន័យប្រាសាទ ទួល ស្រះ ត្រពាំងបុរាណនៅស្រុកទាំង១១ និងក្រុង១ សម្រេចបាន១០០ភាគរយ ដើម្បីធ្វើការផ្ទៀងផ្ទាត់ជាមួយផែនទីអង្គការយូណេស្កូ។ បានចូលរួមពិនិត្យវត្ថុបុរាណ នៅសណ្ឋាគារឡារ៉ស៊ីដង់ដឺអង្គរ ចំនួន០៣ដុំ និងធ្វើកំណត់ហេតុប្រគល់-ទទួល ដើម្បីបញ្ជូនយកមករក្សាទុកនៅនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ។ សហការប្រមូលវត្ថុបុរាណ (ក្បាលនាគចំនួន០១) ដែលជនល្មើសមិនស្គាល់មុខលបលួចកាត់ផ្តាច់នៅស្ពានក្មេង (ស្ពានបុរាណ) ក្នុងឃុំខ្វាវ ស្រុកជីក្រែង យកមករក្សាទុកនៅទីស្នាក់ការអាជ្ញាធរអប្សរា និង សហការជាមួយអាជ្ញាធរអប្សរា ត្រួតពិនិត្យប្រាសាទបែកបាក់ និងដាក់ស្លាកឈ្មោះស្ពានបុរាណ បានចំនួន០៧លើក ស្លាកសញ្ញាស្ពានបាន០២ផ្ទាំង នៅស្រុកជីក្រែង សរុបបានចំនួន១១លើក។ បំផុសប្រជាពលរដ្ឋឱ្យចូលរួមត្រួសត្រាយសំអាតប្រាសាទបន្ទាយអំពិល នៅភូមិសំរោង ឃុំខ្នាពោធិចំនួន១លើក និង ចុះត្រួតពិនិត្យការស្តារត្រពាំងខ្នាកទ្រាំង លទ្ធផលសម្រេចបានទំហំ២.៥០០ម៉ែត្រការ៉េ និងជម្រៅ១.៥០ម នៅឃុំខ្វាស់ ស្រុកសូទ្រនិគម។ ទប់ស្កាត់ដល់ប្រជាពលរដ្ឋចំនួន៥គ្រួសារឱ្យធ្វើកិច្ចសន្យាបញ្ឈប់ការភ្ជួររាស់ដីធ្វើស្រែ លើដីបរិវេណប្រាសាទភ្នាសគោល នៅភូមិគោល ឃុំគោល ស្រុកអង្គរជុំ។ បានចុះទប់ស្កាត់ការលួចឈូសឆាយបរិវេណប្រាសាទក្បាលបី នៅស្រុកស្រីស្នំ។ ចុះស្រាវជ្រាវរកឃើញគោក ទួលប្រាសាទ និងត្រពាំងបុរាណថ្មី ស្ថិតនៅក្នុងឃុំតាយ៉ែម ស្រុកសូទ្រនិគមមានៈ គោក២កន្លែង ទួលប្រាសាទ១កន្លែង និងត្រពាំងបុរាណ១។ បានចុះស្រង់ទិន្នន័យអំពីតំបន់ដែលមានធនធានថ្មភក់ និងថ្មបាយក្រៀមនៅតំបន់អណ្តូងរយ ស្រុកជីក្រែង-តំបន់ត្រពាំងព ស្រុកស្វាយលើ និងនៅតំបន់ភ្នំព្រះច្បារ ស្រុកស្រីស្នំ ទទួលលទ្ធផលវិជ្ជមាន។ សហការជាមួយព្រះសង្ឃ អាចារ្យវត្តជីក្រែង លើកគម្រោងសង់សារមន្ទីរសហគមន៍ នៅវត្តជីក្រែងទុកជូនសប្បុរសជន។ សហការជាមួយសមត្ថកិច្ចគយនៅច្រកព្រលានយន្តហោះអន្តរជាតិសៀមរាប ធ្វើការហាមឃាត់ចាប់វត្ថុសិល្បៈភ្ញៀវនាំចេញគ្មានលិខិតអនុញ្ញាតមានចំនួន៣រូប បច្ចុប្បន្នរូបចំនួន២រក្សាទុកនៅស្នាក់ការគយ និងរូប១ទៀតក្រុមចម្រុះសិប្បករអង្គរសុំដោះស្រាយ ដោយយកមកទុកនៅក្រុមហ៊ុនវិញ ។

**មន្ទីរខេត្តកំពង់ធំ** បានយកល្បះសំអាតប្រាសាទសំបូរបាន៤៥.១៩៥ម៉ែត្រការ៉េ-បានត្រួសត្រាយសំអាតផ្លូវពីប្រាសាទមួយទៅប្រាសាទមួយ (តំបន់ប្រាសាទសំបូរព្រៃគុក) បាន៧០០ម៉ែត្រ។ បានធ្វើជើងទម្រ និងលើកតាំងវត្ថុបុរាណបាន៩១ដុំ នៅក្នុងសារមន្ទីរ និងសម្ពោធរួចជាស្ថាពរ។ បានបណ្តុះកូនឈើដែលមាននៅក្នុងថ្នាលសរុប៩.៧៤០ដើម ក្នុងនោះកូនឈើហូបផ្លែចំនួន៣.៦២៥ដើមកូនឈើកែលម្អចំនួន៣.២០៧ដើម កូនឈើដាំក្នុងតំបន់ចំនួន២.៩០៥ដើម។ បានចុះទៅស្រុកស្ទោង ដើម្បីពិនិត្យស្ថានភាពប្រាសាទបន្ទាយស្ទោង ស្ថិតនៅភូមិបន្ទាយស្ទោង ព្រោះនៅទីនោះប្រជាពលរដ្ឋបានចាក់ស៊ីម៉ង់ត៍តាំងព្រះពុទ្ធរូបសម្រាប់គោរពបូជា និងចុះពិនិត្យវត្តចាស់ ដែលនៅទីនោះមានសន្លឹកសីមាមួយចំនួន។ ព្រះចៅអធិការ ភូ គី ព្រមទាំងគណៈកម្មការ

អាចារ្យវត្ត រស្មីសាមគ្គី (វត្តស្រះសំបូរ) បានសហការគ្នាដឹកជញ្ជូនថ្មបុរាណពីតំបន់ប្រាសាទពោធិនិព្វាន មករក្សាទុកកុំឱ្យបាត់បង់ចំនួន២៥ដុំ និង បានទទួលរូបលោកេស្វរៈ ពីស្រុកប្រាសាទបល្ល័ង្កចំនួន០១។ ភ្ញៀវជាតិ និងអន្តរជាតិចូលទស្សនានៅតំបន់ប្រាសាទសំបូរព្រៃគុកមានចំនួន៤.៤២១នាក់-ប្រាសាទអណ្តែតមានចំនួន៤៦០នាក់ អន្តរជាតិ២៩៨នាក់-ប្រាសាទគុហ៍នគរចំនួន៨៦៥នាក់ អន្តរជាតិ២០៥នាក់-រមណីយដ្ឋានភ្នំសន្ទុកមានចំនួន៦៨.២៨១នាក់ និង ភ្ញៀវជាតិ-អន្តរជាតិចូលទស្សនាសារមន្ទីរបានចំនួន២៨៩នាក់ ក្នុងនោះព្រះសង្ឃចំនួន៦០អង្គ និងប្រជាពលរដ្ឋចំនួន២១នាក់។ សហការជាមួយអង្គការ WASEDA ធ្វើកំណាយនៅលើខឿនប្រាសាទN1បានពាក់កណ្តាល ដែលសល់ពីឆ្នាំមុនស្មើនឹង៨០០ម៉ែត្រការ៉េ-ធ្វើកំណាយ៣/៤ នៃខឿនប្រាសាទ N1 បាន៥២,៤ម៉ែត្រគីប-បានជួសជុលបង្កាន់ដៃនៃជណ្តើរប្រាសាទN1ខាងលិចបានរួចរាល់-ជួសជុលខឿនប្រាសាទN1ខាងជើងបាន១០ម៉ែត្រការ៉េ-ស្ទួចថ្មបង្កាន់ដៃជណ្តើរអាក់នៅជណ្តើរខាងជើង និងខាងលិចបាន២បង្កាន់ដៃ។ គូរប្លង់ប្រាសាទN1បាន២៤០ម៉ែត្រការ៉េ-ជួសជុលបង្កាន់ដៃខាងលិចប្រាសាទN1បាន១៦ស្រទាប់-ធ្វើកំណាយខឿនប្រាសាទN1ជ្រុងខាងជើងឈាងខាងកើតបាន០៥ម៉ែត្រគីប។ ធ្វើដំបូលរោងប្រក់ និងធ្វើរន្ទានៅប្រាសាទN14-ជួសជុលបង្កាន់ដៃប្រាសាទN1ខាងលិច នៅខាងស្តាំ។ គូរប្លង់កំរាលប្រាសាទN14,1បាន១៤០ម៉ែត្រការ៉េ-បានតម្រង់ស៊ុមទ្វារ-រៀបរន្ទា ដើម្បីជួសជុលប្រាសាទN14,1-បានបិទមុខពង្រឹងជញ្ជាំងប្រាសាទ N14,1 បាន៥០ភាគរយ។ បានកាត់ស្មៅកូនឈើដែលដុះ នៅលើប្រាសាទបានចំនួន១៦ប្រាសាទ។

**មន្ទីរខេត្តកំពង់ចាម** បានចុះទៅធ្វើអនាម័យតាមបណ្តាប្រាសាទ០៣កន្លែង ស្មើនឹង១០លើក និងចុះត្រួតពិនិត្យស្ថានភាពប្រាសាទ០៣កន្លែង ស្មើនឹង០៨លើក។ បានទទួលវត្ថុបុរាណ ប្រភេទស្គរបុរាណ (ធ្វើពីដែក និងស្ពាន់) ទំងន់២៤ គ.ក្រ ពីស្នងការនគរបាលខេត្ត និងបានចុះទៅទទួលវត្ថុបុរាណ០១រូប នៅការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈស្រុកព្រៃឈរ០១លើក។ បានចុះកំណត់ព្រំដីរវាងបេតិកភណ្ឌជាតិ និងដីប្រជាពលរដ្ឋ០៣កន្លែង ស្មើនឹង០៤លើក។ បានបញ្ជូនឯកសារមួយច្បាប់ទៅមន្ទីរនគរូបនីយកម្ម ដែនដី និងសំណង់ ស្តីពីការកំណត់ព្រំដីដប់មួយម៉ែត្រពីកំពែងប្រាសាទនគរបាជ័យ។ ឯកឧត្តម ឃឹម សារិទ្ធ និងប្រតិភូមន្ទីរវប្បធម៌ខេត្តកំពង់ចាម០២រូប បានចុះស្រាវជ្រាវពិនិត្យទួលលើ ឬទួលត្រាច្រឹង ក្នុងភូមិពាមក្នុង ឃុំព្រែកក្របៅ ស្រុកកងមាស។ គណៈប្រតិភូក៏បានផ្សព្វផ្សាយ ស្តីពីច្បាប់ការពារបេតិកភណ្ឌជាតិ ដោយមានការចូលរួមពីអភិបាលស្រុក មន្ត្រីនគរបាលឃុំ ព្រមទាំងមេឃុំ ក្រុមប្រឹក្សាឃុំប្រមាណ២៥រូប និងប្រជាជនប្រមាណ១៨០នាក់។ លោកគ្រូចៅអធិការ អាចារ្យ និងគណៈកម្មាធិការវត្តអំពិលទ្វារ បាននាំរូបព្រះពុទ្ធ ដែលបាក់បែកជាបីកំណាត់មកប្រគល់ជូនប៉ុស្តិ៍រដ្ឋបាលឃុំសំពងជ័យ និងប្រធានវប្បធម៌ស្រុកជើងព្រៃ យើងបានពិនិត្យវត្ថុបុរាណនោះគឺជាព្រះពុទ្ធបដិមា មានកំពស់៨តឹក ទទឹង២តឹក ទម្ងន់២៤គ.ក្រ រចនាបថក្រោយសម័យអង្គរ រូបសំណាកបុរាណនេះប្រគល់ឱ្យលោកគ្រូ ថៅ ស៊ើន ជាគ្រូសូត្រស្តាំ ជាចៅអធិការវត្តសិរីអម្ពវ័ន្ត ហៅវត្ត (ត្នោតកើត) ឃុំព្រៃចារ ស្រុកជើងព្រៃរក្សាទុក ។

**មន្ទីរខេត្តក្រចេះ** បានចុះត្រួតពិនិត្យនៅទីតាំងប្រាសាទដងរែក និងប្រាសាទអូប្រក់ដែលមានសភាពបាក់បែក និងមានសល់បំណែកថ្មភក់មួយចំនួន។ បានចុះត្រួតពិនិត្យទួលបុរាណឈ្មោះ ទួលតាស្នាន់ "ទើបរកឃើញថ្មី" ស្ថិតនៅភូមិបឹងលាច ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ហើយនៅទីនោះមានរណ្តៅ៤កន្លែង ដែលមានការជីកកកាយយូរមកហើយ និងសល់ផ្ទាំងថ្មយោនី០១នៅល្អ និងបែកបាក់មួយចំនួន ព្រមទាំងឥដ្ឋបុរាណផងដែរ។ បានចុះត្រួតពិនិត្យទួលបុរាណឈ្មោះ "ទួលទ្រុង" ហៅភ្នំទ្រុង ក្នុង

ភូមិបឹងលាច ដែលមានព្រះវិហារមួយសាងសង់ក្នុងឆ្នាំ១៩៥៦ ហើយបច្ចុប្បន្នមានព្រះសង្ឃមួយអង្គកំពុងគង់នៅចាំវស្សានៅទីនោះ។ បានសហការជាមួយសហគមន៍ប្រាសាទត្រពាំងបន្ទាយ និងអាជ្ញាធរឃុំចង្រ្កង់ ចុះត្រួតពិនិត្យមើលបង្គោលព្រំប្រទល់នៅលើទីតាំងប្រាសាទត្រពាំងបន្ទាយដែលស្ថិតនៅភូមិល្អ "ភូមិឧបសម្ព័ន្ធ" ឃុំចង្រ្កង់ដើម្បីទប់ស្កាត់ការលួចកាប់ព្រៃទន្រ្ទានយកដីពីប្រជាជនខ្មែរឥស្លាមចំនួន៥០គ្រួសារ ដោយសម្រេចបណ្តេញចេញបាន៣៨គ្រួសារ និងនៅសល់១២គ្រួសារទៀត កំពុងមានវិធានការជាបន្ទាន់ និងកំពុងចុះធ្វើការស្រាវជ្រាវពីផលប៉ះពាល់ និងធ្វើកំណត់ហេតុដើម្បីរាយការណ៍ជូនអាជ្ញាធរស្រុក និងខេត្ត។ បានទទួលវត្ថុបុរាណចំនួន០១ "ពាងជនជាតិ" ធ្វើពីដីដុត អំណោយពីប្រជាពលរដ្ឋនៅសង្កាត់ក្រចេះ ក្រុងក្រចេះ និង បានចុះបញ្ជីសារពើភណ្ឌវត្ថុបុរាណតាមទម្រង់របស់សារមន្ទីរជាតិចប់ជាស្ថាពរ។ បានថែរក្សាបោសសំអាតកាប់ព្រៃធ្វើផ្លូវក្នុងបរិវេណទីតាំងអាគារបុរាណរកាកណ្តាលបានជាប្រចាំ និង ទទួលភ្ញៀវចូលទស្សនាសរុបចំនួន៣៨៧នាក់ ក្នុងនោះអន្តរជាតិចំនួន ២៣៨នាក់ ។

**មន្ទីរខេត្តស្ទឹងត្រែង** បានចុះស្រាវជ្រាវរកឃើញវត្ថុបុរាណចំនួន២ដុំ នៅវត្តធម្មរង្សី ក្នុងនោះមាន : រូបទរបង្ហូរទឹកវត្ថុធាតុថ្មភក់ និង មេទ្វារក្រោម វត្ថុទាំងនេះរក្សាទុកនៅក្នុងវត្តធម្មរង្សី សង្កាត់ព្រះបាទ។ ចុះត្រួតពិនិត្យវត្ថុបុរាណនៅស្រុកសៀមប៉ាង ពិនិត្យឃើញរូបចម្លាក់យោនីព្រះនាងឧមាវតី១ដុំ បច្ចុប្បន្នរក្សាទុកនៅលើខ្ទមអ្នកតាកាឡុប នៅភូមិផាបាំង ឃុំផាបាំង ស្រុកសៀមប៉ាង។ បានសហការជាមួយប៉ូលីសបេតិកភណ្ឌ និងការិយាល័យវប្បធម៌ស្រុកថាឡាបរិវ៉ាត់ ចុះត្រួតពិនិត្យវត្ថុបុរាណចំនួន០១ដុំ ប្រភេទថ្មាំងយោនីជាប់លឹង្គដែលទើបរកឃើញថ្មី បច្ចុប្បន្នរក្សាទុកនៅការិយាល័យវប្បធម៌ស្រុកថាឡាបរិវ៉ាត់។ បានសហការជាមួយក្រុមស្រាវជ្រាវបុរាណវិទ្យាចំនួន៥នាក់ មកពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈចុះត្រួតពិនិត្យ និងស្រាវជ្រាវវត្ថុបុរាណចំនួន២ស្រុកគឺ ស្រុកសេសាន គឺនៅទួលប្រាសាទណងខក (ប្រាសាទប្រណាំងពង្រ) និង ទួលកំណាប់ ពិនិត្យឃើញកំទិចឥដ្ឋ និងបំណែកថ្ម ដែលគេកកាយ ស្ថិតនៅភូមិហាងសាវ៉ាត់។ ស្រះបុរាណដែលគេរកឃើញថ្មីចំនួន០៨ស្រះ ស្ថិតនៅឃុំសាមឃួយ និងស្រុកថាឡាបរិវ៉ាត់ និងមានទីទួលប្រាសាទបុរាណចំនួន១១ទួល ទួលប្រាសាទបុរាណទាំងនោះសល់តែកំទិចឥដ្ឋ ដែលប្រជាជនជីកកកាយរកកំណប់។ មានស្រះបុរាណចំនួន០២ស្រះ និងវត្ថុបុរាណ០១ដុំជាប្រភេទយោនី នៅភូមិអូត្រែល ដែលប្រជាជនជីកស្រះឃើញ ឥឡូវបានរក្សាទុកនៅការិយាល័យវប្បធម៌ស្រុកថាឡាបរិវ៉ាត់។

**មន្ទីរខេត្តរតនគិរី** ចុះសិក្សាស្រាវជ្រាវតំបន់គ្រឹះប្រាសាទ ស្រុកកូនមុំ និងដាក់ស្លាកបន្ថែមគឺ ស្លាកសញ្ញាហាមកាប់រានដីព្រៃ និងហាមជីកកកាយនៅតំបន់គ្រឹះប្រាសាទ ស្រុកកូនមុំ និងស្រុកបរកែវ។ បានចុះត្រួតពិនិត្យកំណត់ព្រំប្រទល់ទីតាំងគ្រឹះប្រាសាទព្រះពុទ្ធជាមួយក្រុមហ៊ុន ម៉ាង យ៉ាង។ បានចុះសហការជាមួយស្ថាប័ន មន្ទីរ អង្គភាព ពាក់ព័ន្ធ និងអាជ្ញាធរស្រុក វឺនសៃ ដើម្បីទៅផ្ទៀងផ្ទាត់បង្គោលព្រំ និងព្រំដីរវាងតំបន់អភិរក្សគ្រឹះប្រាសាទព្រះពុទ្ធ និងក្រុមហ៊ុន ឆេង ឡុក គីរីអភិវឌ្ឍ។ ចុះសិក្សាស្រាវជ្រាវតំបន់បុរាណវិទ្យាប្រាសាទណាក់ណាំង ដែលមាននៅក្នុងស្រុកអូរយ៉ាដាវ ជាមួយមន្ត្រីជំនាញមកពីនាយកដ្ឋានបុរាណវិទ្យា នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ បានទទួលវត្ថុបុរាណ គឺប្រដាប់កិនថ្នាំបុរាណមួយដុំ និងកុលាលភាជន៍ចំនួន០២ ពីប្រជាជននៅស្រុកលំផាត់ យកមករក្សាទុកនៅមន្ទីរខេត្ត ។

**មន្ទីរខេត្តមណ្ឌលគិរី** បានរៀបចំកែលម្អ និងថែរក្សានូវមជ្ឈមណ្ឌលវប្បធម៌ជនជាតិភ្នំដោះក្រមុំជាប្រចាំ។ បានដាំកូនស្រល់លើភ្នំចំនួន១៥០ដើម នៅមុខអាស្រមលោកយាយផ្លី-ចាក់ដីនៅអាស្រមលោកតាផ្លូបាន២៥ឡាន ដើម្បីពង្រីកកន្លែងចត

រថយន្តសម្រាប់ភ្ញៀវទេសចរណ៍ និង រៀបចំឈ្នួសឆាយនៅជើងជណ្តើរក្រោមនៅមជ្ឈមណ្ឌលវប្បធម៌ជនជាតិភ្នំដោះក្រមុំបាន ប្រវែង ៣០ម×៧០ម សម្រេចបាន១០០ភាគរយ។ បានចុះត្រួតពិនិត្យនៅជុំវិញបរិវេណដីមជ្ឈមណ្ឌលជនជាតិភ្នំដោះក្រមុំ ឃើញមានជនបំពានយកដីភ្នំ០១កន្លែង និងសាងសង់ផ្ទះ០១ខ្នងប៉ែកខាងជើងភ្នំ ប្រវែង៩០ម×៣០ម និងបានធ្វើការហាមឃាត់ជនខាងលើកុំឱ្យឈ្លូសឆាយ ឬសង់ផ្ទះបន្ត និង បានរៀបចំឯកសារកំណត់ហេតុជនល្មើសជូនសាលាខេត្តជួយដោះស្រាយ។ បានកំពុងរៀបចំបែបបទចុះបញ្ជីសារពើភណ្ឌទួលបុរាណចំនួន០២មានៈ មជ្ឈមណ្ឌលវប្បធម៌ជនជាតិភាគតិចភ្នំដោះក្រមុំ ស្ថិតនៅក្រុងសែនមនោរម្យ និង រមណីយដ្ឋានទេសចរណ៍វប្បធម៌ភ្នំក្រោល ស្ថិតនៅស្រុកកោះញែក ។

**មន្ទីរខេត្តព្រៃវែង** ចុះពិនិត្យវត្ថុបុរាណ (រូបព្រះវិស្ណុ) ដែលប្រជាជនកាប់ដីប្រទះឃើញនៅស្រុកមេសាង បច្ចុប្បន្នយកមករក្សាទុកនៅសារមន្ទីរជាតិ។ សហការធ្វើកំណាយបន្តនៅស្ថានីយ៍ព្រហា ស្រុកស្វាយអន្ទរជាមួយមជ្ឈមណ្ឌលមេមត់ និងក្រុមបុរាណវិទ្យាចំនួន០៤លើក។ ចាក់ដីបំពេញនៅបរិវេណទីទួលបារាយណ៍អណ្តែតចំនួន១០០ឡាន អស់ថវិកាសរុបចំនួន ២.០០០.០០០រៀល ថវិការបស់រដ្ឋ និង ថវិកាសប្បុរសជន។ ធ្វើខ្លោងទ្វារនៅទួលបារាយណ៍អណ្តែត ថវិកាឯកឧត្តម យុទ្ធ ភូថង រដ្ឋលេខាធិការក្រសួងកសិកម្ម និង ចុះពិនិត្យទួលបុរាណនៅតាមបណ្តាស្រុកទូទាំងខេត្ត ដើម្បីរៀបចំធ្វើប្លង់ជាសម្បត្តិវប្បធម៌ជាតិ។ លាបថ្នាំកែលម្អសារមន្ទីរខេត្ត-ធ្វើជើងទម្រតម្កល់រូបបដិមាក្នុងសារមន្ទីរខេត្ត-ធ្វើទូតាំងវត្ថុបុរាណនៅក្នុងសារមន្ទីរចំនួន០៣គ្រឿង និងធ្វើខ្លោងទ្វារសារមន្ទីរថ្មី ជាថវិកាជំនួយរបស់មជ្ឈមណ្ឌលអាឡឺម៉ង់។ មជ្ឈមណ្ឌលអាឡឺម៉ង់ប្រគល់វត្ថុបុរាណដែលធ្វើកំណាយពីភូមិព្រហា ឃុំជ្រៃ និងទួលបិទមាស ឃុំដីវិញ្ចន ស្រុកស្វាយអន្ទរ មកដាក់តាំងក្នុងសារមន្ទីរខេត្ត និងធ្វើរបងបេតុងជុំវិញសារមន្ទីរ។ សរុបភ្ញៀវចូលទស្សនាសារមន្ទីរចំនួន៧២នាក់។

**មន្ទីរខេត្តស្វាយរៀង** ទួលបុរាណសរុបនៅទូទាំងខេត្តមានចំនួន៦៧៣ទួល ហើយទួលទាំងអស់នេះបានធ្វើការស្រង់ចូលក្នុងបញ្ជី និងចុះហត្ថលេខាទទួលស្គាល់ពីលោកមេភូមិ មេឃុំ អភិបាលស្រុក និងមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងសុរិយោដីខេត្តហើយដើម្បីថែរក្សាការពារឱ្យបានគង់វង្ស និងបានចុះស្រាវជ្រាវបន្តចំនួន៤៥ទួលបន្ថែមទៀត។ បានចុះសហការជាមួយអគ្គនាយកដ្ឋានបេតិកភណ្ឌចុះបោះបង្គោលខ័ណ្ឌសីមា នៅប្រាសាទព្រៃបាសាក់ ឃុំបាសាក់ ស្រុកស្វាយជ្រំចំនួន០៤បង្គោល និងនៅប្រាសាទជាហោ ឃុំគគី ស្រុករមាសហែកបានចំនួន០៤បង្គោល និង សហការជាមួយក្រសួង បានសិក្សាអំពីការធ្វើកំណាយទួលប្រាសាទសំពៅ ក្នុងតំបន់ប្រាសាទព្រៃបាសាក់។ សហការជាមួយគណៈកម្មាធិការវាស់វែងដីធ្លីជាលក្ខណៈប្រព័ន្ធ ដើម្បីចុះបញ្ជីទួលបុរាណបានចំនួន៣ប្លង់/ទួល នៅស្រុកស្វាយជ្រំ។ ចុះប្រមូលវត្ថុបុរាណ នៅតាមវត្ត និងទីសាធារណៈបានចំនួន១ផ្ទាំង។ វត្ថុបុរាណថែរក្សាក្នុងសារមន្ទីរមានចំនួន១៦៣ផ្ទាំង/រូប ។

## ៤.ការងារបេតិកភណ្ឌអរូបី :

### ៤.១.ការងារសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ :

បានសហការរៀបចំបើកមហោស្រពភាពយន្តអន្តរជាតិ-កម្ពុជា លើកទី២ នៅរាជធានីភ្នំពេញ (១៤-១៨.ធ្នូ.២០១១) រយៈពេល៥ថ្ងៃ មានស្នាដៃចូលរួម៩០រឿង មកពី១៧ប្រទេស។ ការថតសកម្មភាពការងារក្រសួងបាន៥២លើក និងថតវីដេអូឯកសារ១៣ចំណងជើង។ បានផ្សព្វផ្សាយវីដេអូបទយកការណ៍ ស្តីពីការសិក្សាស្រាវជ្រាវចុះបញ្ជីប្រាសាទអូរស្វាយ នៅខេត្តឧត្តរ

មានជ័យ និង ផ្សព្វផ្សាយស្តីពីស្ថានីយ៍បុរាណវិទ្យាប្រាសាទក្តាក់ ព្រមទាំងចម្លងឯកសារវីដេអូស្តីពីប្រាសាទតាមាន់ ជូនទីស្តីការគណៈរដ្ឋមន្ត្រី។

-ចុះបញ្ជីសុំផលិតខារ៉ាអូខេខ្មែរបាន៩១លេខ និងសុំផលិតវីដេអូរឿង១ដុំចប់បាន២១ចំណងជើង-រឿងភាគខ្មែរ០៤ចំណងជើង និងស្ពតបាន១១ចំណងជើង

-ផ្តល់ទិដ្ឋាការខារ៉ាអូខេខ្មែរបាន១២២លេខ និងវីដេអូរឿងខ្មែរ១ដុំចប់បាន១២ចំណងជើង រឿងភាគខ្មែរ០៤ចំណងជើង និងស្ពតផ្សាយពាណិជ្ជកម្មបាន០៩ចំណងជើង

-ផ្តល់ទិដ្ឋាការវីដេអូរឿងបរទេសបាន៨៣ចំណងជើង និងទទួលចុះបញ្ជីកាសែ្សតនាំចូលពីបរទេសបាន១៤៥ចំណងជើង។

ការផ្តល់អាជ្ញាប័ណ្ណថ្មីសម្រាប់ធ្វើអាជីវកម្មភាពយន្ត-វីដេអូមាន : បើកផលិតកម្មភាពយន្ត-វីដេអូចំនួន១៤ច្បាប់ បើកក្រុមហ៊ុននាំចេញ-នាំចូលចំនួន០៥ច្បាប់-បើកស្ទូឌីយូបញ្ចូលសម្លេងភាពយន្ត-វីដេអូចំនួន០២ច្បាប់ និងបើកស្ទូឌីយូកាត់តរូបភាពចំនួន០២ច្បាប់។

ការបង្រ្កាបបទល្មើសភាពយន្តវីដេអូ នៅរាជធានី-ខេត្ត ដកហូតថាសខុសច្បាប់សរុបចំនួន៥១៦.៥២៥បន្ទះ និងថាសមិនទាន់ថតចម្លង០៥កេស ម៉ាស៊ីនថតចម្លង០៩គ្រឿង-Power supply០២គ្រឿង-CD-ROM១៨គ្រឿង-ម៉ាស៊ីនព្រីន០៣គ្រឿង-ម៉ូនីទ័រ០១គ្រឿង និងកំព្យូទ័រ១១គ្រឿង ។

៤.១.១.ការងារតម្កល់ឯកសារខ្សែភាពយន្ត-វីដេអូ :

-បានបោសសំអាតឃ្លាំងហ្វីល រកឃើញឯកសារខ្មែរចំនួន៥ដុំ មានចំណងជើងថា " ទស្សនកិច្ចលោកប្រធាននៅម៉ូស្គូ " និងរីហ្វីលចាស់ៗ ខូចគុណភាពមានចំនួន៩៥០ដុំ

-រកឃើញហ្វីលភាពយន្តខ្នាត១៦ម.ម ជំនាន់សម័យប៉ុលពត មានចំនួន២៤ចំណងជើង ប្រគល់ទៅមជ្ឈមណ្ឌលបុប្ផាណាដើម្បីរក្សាទុក ។

៤.១.២.ការងារបណ្តុះបណ្តាលជំនាញភាពយន្ត-វីដេអូ :

-បើកវគ្គបច្ចេកទេសឧបករណ៍ពន្លឺសម្រាប់ថតភាពយន្ត រយៈពេល១សប្តាហ៍មានសិក្ខាកាមចំនួន១៣នាក់

-បើកវគ្គគ្រប់គ្រងការផលិតភាពយន្ត រយៈពេល១សប្តាហ៍ មានសិក្ខាកាមចំនួន០៨នាក់

-បើកវគ្គលេខាធិការផលិតភាពយន្ត រយៈពេល១សប្តាហ៍ មានសិក្ខាកាមចំនួន០៩នាក់

-បើកសិក្ខាសាលាជំនាញទូទៅ រយៈពេល៣ថ្ងៃ មានសិក្ខាកាមចំនួន៤៥នាក់

-បើកវគ្គគណនេយ្យសម្រាប់ការផលិតភាពយន្ត រយៈពេល២សប្តាហ៍ មានសិក្ខាកាមចំនួន០៦នាក់

-ផលិតវីដេអូខ្នាតខ្លីរឿង " ជំនោរមូសុង " ។

៤.១.៣.ទទួលក្រុមថតភាពយន្តបរទេសមកថតក្នុងស្រុក :

-បានទទួលក្រុមថតភាពយន្តបរទេសចំនួន២៦ផលិតកម្ម-ថតភាពយន្តឯកសារ១៦ចំណងជើង-ថតវីដេអូ០៣ចំណងជើង ថតស្ប៉តពាណិជ្ជកម្ម០៣ចំណងជើង-ថតចម្រៀងកាយវិការ០២លេខ និងថតឈុតកំសាន្តផ្សេងៗ០២ចំណងជើង។

៤.១.៤.<u>ការងារគ្រប់គ្រងចំណូល :</u>

អង្គភាពសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ បានបម្រើការផ្ដល់សេវាកម្មលើវិស័យភាពយន្ត-វីដេអូទទួលបានថវិកាមាន :

-ចំណូលផ្ទាល់សរុបចំនួន**៦០.៦៣០.០០០រៀល**

-ចំណូលប្រយោលពីការថតភាពយន្តរបស់ផលិតកម្មមកពីក្រៅប្រទេសសរុបចំនួន**១.៩៧៥.០០០ដុល្លារអាមេរិក** ។

**៤.២.ការងារសិល្បៈទស្សនីយភាព :**

ក្រុមសិល្បៈមហាជនមកពីរាជធានី-ខេត្ត ចូលរួមមហោស្រពទូទាំងប្រទេសមានចំនួន១២ទម្រង់ មានស្នាដៃ៤៨ស្នាដៃ ក្នុងនោះមាន : ល្ខោននិយាយ៤ស្នាដៃ-ឆាកកំប្លែង៥ស្នាដៃ-របាំប្រពៃណី៧ស្នាដៃ-របាំរឿង៤ស្នាដៃ-ល្ខោនបាសាក់១៤ស្នាដៃ-អាយ៉ៃរឿង៤ស្នាដៃ-ល្ខោនយីកេ៣ស្នាដៃ-ល្ខោនខោល២ស្នាដៃ-ល្ខោនបើកបទ២ស្នាដៃ-ល្ខោនស្បែក១ស្នាដៃ-របាំសហគមន៍១ស្នាដៃ និង របាំក្បាច់១ស្នាដៃ។ ក្រុមសិល្បៈនាយកដ្ឋានសិល្បៈទស្សនីយភាពចំនួន៣០នាក់ បានទៅចូលរួមសម្ដែងមហោស្រពសិល្បៈឥណ្ឌូចិន (២២-២៦.កក្កដា ឆ្នាំ២០១១) នៅប្រទេសវៀតណាម ដោយបានយកសិល្បៈជាច្រើនទម្រង់មានរបាំបុរាណ-ប្រពៃណី និង ចម្រៀងសម័យ ។ ជាលទ្ធផលយើងទទួលបានមេដាយមាសចំនួន០២ និងមេដាយប្រាក់០២ ។

បានប្រគុំតន្ត្រី និងសម្ដែងសិល្បៈ (មហាជន និងអាជីព) សរុបចំនួន**១.៥៥២លើក** ក្នុងនោះនាយកដ្ឋានសិល្បៈសម្ដែងបាន១៣៥លើក (ដោយបានចេញសម្ដែងនៅក្រៅប្រទេសចំនួន០៦ប្រទេសគឺ : ប្រទេសឥណ្ឌូនេស៊ី វៀតណាម០៤លើក-កូរ៉េ បារាំង ចិន០២លើក-ឥណ្ឌូនេស៊ី ថៃ សម្ដែងបាន១១លើក) ។ បានរៀបចំកម្មវិធីសម្ដែងសិល្បៈជូនទស្សនិកជនជាតិ-អន្តរជាតិចូលទស្សនានៅបរិវេណសាលសន្និសីទចតុមុខ ។

លោកគ្រូ អ្នកគ្រូនៅនាយកដ្ឋានសិល្បៈ បានចុះជួយបណ្ដុះបណ្ដាល និងពង្រឹងជំនាញសិល្បៈទស្សនីយភាព នៅតាមបណ្ដាគ្រឹះស្ថានអប់រំ អង្គការ និង សមាគមន៍សិល្បៈនានាមាន :

-លោកគ្រូរបាំបុរាណ០១រូប បានចុះពង្រឹងបច្ចេកទេសសិល្បៈ នៅមជ្ឈមណ្ឌលកុមារកំព្រា កំបូល រាជធានីភ្នំពេញ

-អ្នកគ្រូរបាំបុរាណ០១រូប និងប្រពៃណី០៥រូប ចុះពង្រឹងបច្ចេកទេសសិល្បៈ នៅមន្ទីរខេត្តសៀមរាប

-អ្នកគ្រូរបាំបុរាណ០១រូប ចុះជួយបង្ហាត់របាំបុរាណ នៅសមាគម APECA សៀមរាប

-អ្នកគ្រូរបាំ និងចម្រៀងបុរាណ០៤រូប ចុះជួយបង្ហាត់ នៅមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ (សភវស)

-សិល្បកររបាំប្រពៃណី០២រូប ចុះបង្ហាត់បច្ចេកទេសល្ខោនខោល នៅមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ (សភវស)

-លោកគ្រូ អ្នកគ្រូរបាំបុរាណ០២រូប ចុះជួយបង្ហាត់របាំបុរាណ នៅមជ្ឈមណ្ឌលសិល្បៈវត្តថាន់ រាជធានីភ្នំពេញ

-តន្ត្រីករបុរាណ០១រូប ចុះបង្ហាត់សិល្បៈ ដល់កុមារកំព្រា ខេត្តកំពត

-លោកគ្រូ អ្នកគ្រូរបាំ០២រូប ចុះជួយបង្ហាត់របាំ សាលាបណ្ដុះបណ្ដាលរបាំ នៅខេត្តសៀមរាប ។

ការងារជំនាញនៅតាមផ្នែកនីមួយៗនៅនាយកដ្ឋានបានបន្តហាត់សម និងតម្លើងរឿងមាន ៖ តម្លើងល្ខោនស្រមោលស្បែកតូចរឿង "មិនអស់ពីដី ជីវិតថ្មីរុងរឿង" តម្លើងរបាំចម្រុះសម្រាប់សម្តែងក្នុងកិច្ចប្រជុំអន្តរសភាអាស៊ាន (របាំ-ចម្រៀងសួនអាស៊ាន) តម្លើងល្ខោននិយាយរឿង "វង់ត្រកូលកំសត់"។

ការអនុវត្តការងាររយៈពេលមួយឆ្នាំនេះ ការសម្តែងសិល្បៈជូនសាធារណជនជាតិ-អន្តរជាតិ ក្នុងពិធីផ្សេងៗ បើប្រៀបធៀបឆ្នាំកន្លងមកគឺមានការកើនឡើង៣៦,៣៦ភាគរយ និងសកម្មភាពក្រៅប្រទេសក៏មានការថយចុះ៨,៣៣ភាគរយ ។

**៤.៣.ការងារសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ៖**

បានស្រាវជ្រាវចងក្រងសៀវភៅក្បាច់ចម្លាក់ខ្មែររួចរាល់ និងបានបន្តស្រាវជ្រាវចងក្រងសៀវភៅក្បាច់ភាគ២ និងឯកសារសម្ភារៈប្រើប្រាស់របស់ប្រជាពលរដ្ឋខ្មែរ ដើម្បីត្រៀមបោះពុម្ពផ្សព្វផ្សាយ។ ចុះស្រង់ស្ថិតិកន្លែងលក់គ្រឿងវត្ថុសិល្បៈនៅខណ្ឌដូនពេញ-ខណ្ឌចំការមន-ខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និងបានចុះស្រង់ស្ថិតិសិប្បកម្មខ្នាតតូច និងខ្នាតមធ្យមនៅខេត្តប៉ៃលិន-សៀមរាប-ស្ទឹងត្រែង-ឧត្តរមានជ័យ និងកំពង់ស្ពឺ។ បានចុះបំប៉នក្បាច់ចម្លាក់ជូនគ្រូបង្គោល សិប្បករ ប្រជាពលរដ្ឋខេត្តព្រះវិហារ-កំពង់ធំ-រតនគីរី-ប៉ៃលិន និងខេត្តបន្ទាយមានជ័យ។ បានស្រាវជ្រាវសម្ភារៈប្រើប្រាស់ក្នុងផ្ទះខ្មែររបស់ប្រជាពលរដ្ឋ និងសម្ភារៈកសិកម្ម។ បានសហការជាមួយUNDP និងអង្គការUNESCOចុះផ្សព្វផ្សាយអំពីសិប្បកម្មជនជាតិ នៅខេត្តរតនគីរី។ បានចូលរួមរៀបចំពិព័ណ៌នៅមន្ទីរបក្ស ទីក្រុងហូជីមិញ (វៀតណាម)។ បានសហការជាមួយ Van’s Referent រៀបចំតាំងស្នាដៃសិល្បៈគំនូរបុរាណ និងសម័យ។ បានសហការជាមួយ TANA RIND រៀបចំតាំងស្នាដៃសិល្បៈគំនូរ និងបានសហការជាមួយLOST ROOM ( Australia) រៀបចំបង្ហាញស្នាដៃគំនូរបុរាណ។ ចំពោះការរៀបចំមហោស្រព ស្តីពីអប្សរា នឹងត្រៀមបើកនៅដើមឆ្នាំ២០១២ ( មូលហេតុថវិកាឆ្នាំ២០១១មានការយឺត)។

ការងារសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម បើប្រៀបធៀបនឹងផែនការឆ្នាំ នាយកដ្ឋានបំពេញបាន៩៩ភាគរយ។

**៤.៤.ការងារអភិវឌ្ឍវប្បធម៌ ៖**

សិក្សាស្រាវជ្រាវអំពីខ្លឹមសារ ស្តីពីក្រុមវប្បធម៌-ភូមិវប្បធម៌-មណ្ឌលវប្បធម៌ និងមជ្ឈមណ្ឌលវប្បធម៌ ដើម្បីចងក្រងទុកជាឯកសារផ្សព្វផ្សាយ។ ចងក្រង និងសិក្សាស្រាវជ្រាវប្រភេទមុខម្ហូបអាហារខ្មែរ និងវិធីផ្សំគ្រឿង ដើម្បីរៀបចំបោះពុម្ពជាសៀវភៅឯកសារមុខម្ហូបខ្មែរ។ កែសម្រួលឡើងវិញនូវឯកសារល្បែងប្រជាប្រិយខ្មែរដែលមានស្រាប់ និងបន្តស្រាវជ្រាវបន្ថែម។ បន្តរៀបចំរូបភាពសម្រាប់បោះពុម្ពសៀវភៅអាពាហ៍ពិពាហ៍ខ្មែរ។ បន្តសិក្សាស្រាវជ្រាវឯកសារប្រពៃណីទំនៀមទម្លាប់ខ្មែរ និងសិក្សាស្រាវជ្រាវពីប្រវត្តិពូនភ្នំខ្សាច់នៅក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ។ បន្តស្រាវជ្រាវពីផ្ទះកូនកម្លោះ-ក្រមុំជនជាតិគ្រឹង នៅខេត្តរតនគីរី បន្តស្រាវជ្រាវពីពិធីសែនព្រេនមុនពេលធ្វើស្រែចំការ និងមុនពេលប្រមូលផលស្រូវរបស់ជនជាតិ។ សិក្សាស្រាវជ្រាវអំពីសម្លៀកបំពាក់ជនជាតិគ្រឹង បន្តសិក្សាស្រាវជ្រាវពីទំនៀមទម្លាប់ជនជាតិព្នង និងសិក្សាស្រាវជ្រាវអំពីពិធីសែនភូមិ-ភ្លេងគងនិងភ្លេងមិររបស់ជនជាតិ។ សិក្សាស្រាវជ្រាវរៀបចំឯកសារ ស្តីពីសិល្បៈក្បាច់គុនបុរាណខ្មែរ ដើម្បីជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និង កែសម្រួល។

មន្ត្រី១រូប បានអមដំណើរជាមួយឯកឧត្តមអគ្គនាយកបច្ចេកទេសវប្បធម៌ ចុះសិក្សាស្រាវជ្រាវក្បាច់គុនល្បុកតោ និងប្រពៃណីទំនៀមទម្លាប់ជនជាតិដើមភាគតិច នៅខេត្តមណ្ឌលគិរី និងខេត្តស្ទឹងត្រែង។ មន្ត្រី១រូបអមដំណើរឯកឧត្តម សាយ មង្គល អនុរដ្ឋលេខាធិការ ចុះស្រាវជ្រាវជនជាតិភាគតិចទំពួន នៅខេត្តរតនគិរី។ បានរៀបចំមហោស្រពបង្ហោះខ្លែងខ្មែរលើកទី១៥ បង្ហាញម្ហូបអាហារខ្មែរ និងមហោស្រពបង្ហាញទម្រង់សំលៀកបំពាក់ខ្មែរ នៅមជ្ឈមណ្ឌលកោះពេជ្រ (១០.ធ្នូ.២០១១)។

សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងសហព័ន្ធក្បាច់គុន នៅប្រទេសបារាំង រៀបចំពិធីប្រជុំពិភាក្សា និងបង្ហាញក្បាច់គុនបុរាណខ្មែរ ដែលមានព្រឹទ្ធាចារ្យក្បាច់គុនបុរាណចូលរួមចំនួន១៧នាក់ មកពីខេត្តចំនួន៦គឺ ខេត្តកំពត-កំពង់ស្ពឺ កំពង់ឆ្នាំង-ពោធិសាត់-បន្ទាយមានជ័យ និងតាកែវ។ ការប្រារព្ធពិធីធ្វើឡើងនៅពហុកីឡាដ្ឋានជាតិអូឡាំពិក ក្រោមអធិបតីភាព ឯកឧត្តម អគ្គនាយកបច្ចេកទេសវប្បធម៌។ មន្ត្រីជំនាញ បានចុះរៀបចំសហគមន៍វប្បធម៌មួយកន្លែង នៅខេត្តពោធិសាត់ និងបានចុះជួយរៀបចំមណ្ឌលវប្បធម៌ សាលពិព័ណ៌អចិន្ត្រៃយ៍ នៅខេត្តព្រះវិហារ។

ការងាររបស់នាយកដ្ឋានរយៈពេលមួយឆ្នាំនេះ បានអនុវត្ត១00ភាគរយ លើការសិក្សាស្រាវជ្រាវ និងធ្វើសកម្មភាពក្នុងការលើកតម្លៃវប្បធម៌ជាតិឱ្យរឹតតែមានឥទ្ធិពលខ្លាំងក្លាបន្ថែមទៀត។

### ៤.៥.ការងារសៀវភៅ ការអាន:

នាយកដ្ឋានបានផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការប្រឡងជ្រើសរើសស្នាដៃតែងនិពន្ធប្រលោមលោក-កំណាព្យ ពានរង្វាន់ព្រះមុនីកោសល្យ សូរ ហាយ និងបានរៀបចំពិធីប្រកាសលទ្ធផលថ្ងៃទី៣0 ខែមិថុនា ឆ្នាំ២០១១ នៅបណ្ណាល័យជាតិ។ បានបោះពុម្ពទស្សនាវដ្តីលេខ១៧ រួចជាស្ថាពរ និងចែកផ្សព្វផ្សាយ និង បានបន្តនិពន្ធអត្ថបទទស្សនាវដ្តីលេខ១៨។ រៀបចំចុះហត្ថលេខាលើអនុស្សារណៈ ស្តីពីការស្តេនសៀវភៅចាស់ៗ រវាងបណ្ណាល័យជាតិកម្ពុជា និងបណ្ណាល័យជាតិបារាំង។ រៀបចំតាំងពិព័ណ៌សៀវភៅថ្នាក់ជាតិ និងរូបថត នៅបណ្ណាល័យជាតិ ការរៀបចំសហការឧបត្ថម្ភដោយស្ថានទូតបារាំង-វិទ្យាស្ថានបារាំង និងអង្គការស៊ីប៉ា។

**✳បណ្ណាល័យជាតិ :**

បានទទួលកំព្យូទ័រចំនួន១0គ្រឿង (គុណភាពប្រើប្រាស់រួចហើយ) ពីធនាគារ ANZ Royal សម្រាប់បម្រើភ្ញៀវចូលសិក្សានៅបណ្ណាល័យជាតិ។ ភ្ញៀវជាតិ-អន្តរជាតិចូលអាន និងស្រាវជ្រាវមានចំនួន១៨.៣៩៧នាក់ និងផ្តល់សៀវភៅឱ្យអ្នកខ្ចីចំនួន១.៤៥៦ក្បាល។ ទទួលសៀវភៅពីស្ថាប័ននានា និងអង្គការក្រៅរដ្ឋាភិបាល (សៀវភៅគ្រប់ភាសារ) ចំនួន២.៧៧0ក្បាល ទទួលកាសែត ទស្សនាវដ្តីផ្សេងៗ និងព្រឹត្តិប័ត្រសរុបចំនួន៤.២២៦ក្បាល បានចែកលេខ ISBN ឱ្យអ្នកបោះពុម្ពផ្សាយបានចំនួន ១.១៦0លេខ។ ធ្វើកាតាឡុកទស្សនាវដ្តីចាស់ៗ(ខ្មែរ-បរទេស)ចំនួន៣៧0ក្បាល បញ្ចូលចំណងជើងសៀវភៅក្នុងប្រព័ន្ធកំព្យូទ័របានចំនួន៥.៥0៧ចំណងជើង ធ្វើកាតាឡុកសៀវភៅគ្រប់ប្រភេទបញ្ចូលក្នុងប្រព័ន្ធកំព្យូទ័រចំនួន៣.២៨៥ចំណងជើង និងធ្វើបញ្ជីកាតាឡុកសៀវភៅចាស់ៗចំនួន៨២៥ចំណងជើង។ តម្កល់សៀវភៅចំនួន២៩២ចំណងជើង-ដាក់ក្របសៀវភៅចំនួន៨២៥ក្បាល និងដេរកាសែតCambodia Daily ចំនួន៧៥ដុំ។ បណ្ណាល័យចល័តមិនបានចុះផ្សព្វផ្សាយវិស័យការអានតាមមូលដ្ឋានទេ ដោយសាររថយន្តខូចទើបតែបានជួសជុលរថយន្តឡើងវិញនៅខែវិច្ឆិកា ហើយបានចុះធ្វើសកម្មភាពក្នុងការតាំងពិព័ណ៌សៀវភៅនៅបណ្ណាល័យជាតិ និងបន្តចុះបម្រើការអាននៅតាមមូលដ្ឋានចំនួន០៨កន្លែង នៅជាយរាជធានីភ្នំពេញ។ នាយកដ្ឋានសៀវភៅ

និងការអានមានការងារមួយចំនួនមិនរលូន ដូចជាការបោះពុម្ពទស្សនាវដ្តី ពុំទាន់បានគ្រប់ផែនការ ដោយសារថវិកាមានកំណត់។ បណ្ណាល័យជាតិបច្ចុប្បន្នកំពុងអភិវឌ្ឍវិស័យការអានតាមបែបបច្ចេកវិទ្យាទំនើបតាមប្រព័ន្ធអេឡិចត្រូនិច។ ការផ្តល់លេខ ISBN ដល់អ្នកបោះពុម្ពផ្សាយមានការកើនឡើងជាងមុន។

### ៤.៦.ការងារបេតិកភណ្ឌអរូបីដែលបានទទួលស្គាល់ដោយអង្គការយូណេស្កូរួចហើយ

ក- ការអភិរក្សរបាំក្បាច់បុរាណ "ព្រះរាជទ្រព្យ" / ស្បែកធំ

- ក្រុមដែលកំពុងធ្វើសកម្មភាព :

+ របាំក្បាច់បុរាណ "ព្រះរាជទ្រព្យ"

| អង្គភាព/ខេត្ត-រាជធានី | មុនពេលចុះបញ្ជីដោយយូណេស្កូ | | | | បច្ចុប្បន្ន | | | |
|---|---|---|---|---|---|---|---|---|
| | ជាក្របខណ្ឌរាជការ | | ពុំមែនជារាជការ | | ជាក្របខណ្ឌរាជការ | | ពុំមែនជារាជការ | |
| | ក្រុម | នាក់ | ក្រុម | នាក់ | ក្រុម | នាក់ | ក្រុម | នាក់ |
| ១.នាយកដ្ឋានសិល្បៈ | ០១ | ៦០ | | | ០១ | ៦៥ | | |
| ២.សាលាមធ្យមវវស | | | | ៨២ | | | | ២៥០ |
| ៣.រាជធានីភ្នំពេញ | | | | | ០១ | ១៧ | ១២ | ៨៤ |
| ៤.សៀមរាប | | ០៣ | ១៦ | ៤៤៨ | | | ២១ | ៧៩៧ |
| ៥.បាត់ដំបង | ០១ | ១០៦ | ០៧ | ១២០ | ០១ | ១៣ | ០៨ | ១៧០ |
| ៦.កណ្តាល | ០១ | ២០ | ០៨ | ៥០ | ០១ | ២០ | ០៥ | ៥០ |
| ៧.ព្រះសីហនុ | | | ០៣ | ៤០ | | | ០៣ | ៦០ |
| ៨.កែប | | | | | | | ០១ | ២០ |
| ៩.កំពង់ស្ពឺ | ០១ | ១២ | | | ០១ | ០៣ | ០៣ | ២៤ |
| ១០.បន្ទាយមានជ័យ | | | | | | | ០១ | ៤០ |
| ១១.ប៉ៃលិន | | | | | ០១ | ២១ | ០១ | ២៥ |
| ១២.តាកែវ | ០១ | ១២ | | | ០១ | ០៥ | ០៦ | ៣០ |
| ១៣.កំពត | | | | | | | ០២ | ១៦ |
| ១៤.ពោធិសាត់ | ០១ | ០២ | ០១ | ០៧ | ០១ | ០៣ | ០១ | ១២ |
| ១៥.កំពង់ឆ្នាំង | | | | | ០១ | ១២ | | |
| ១៦.ព្រះវិហារ | | | | | | | ០១ | ១២ |
| ១៧.កំពង់ធំ | | | | | ០១ | ១៥ | | |
| ១៨.កំពង់ចាម | ០១ | ២០ | ៣ | ៩០ | ០១ | ១៤ | ១៤ | ៤២០ |
| ១៩. ក្រចេះ | | | | | ០១ | ០៧ | ០៣ | ២១ |
| ២០.ស្ទឹងត្រែង | ០១ | ០៦ | | | ០១ | ០២ | | |
| ២១.រតនគីរី | ០១ | ៣៥ | | | ០១ | ០៥ | ០១ | ០៧ |
| ២២.កោះកុង | ០១ | ១០ | | | | | ០១ | ១០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២៣.ព្រៃវែង | ០១ | ១២ | | | ១ | ១២ | ០៤ | ៥៦ |
| ២៤.ស្វាយរៀង | ០១ | ២០ | | | ០១ | ២០ | | |

+- **ល្ខោនស្រមោលស្បែកធំ**

| **អង្គភាព/ខេត្ត-រាជធានី** | **មុនពេលចុះបញ្ជីដោយយូណេស្កូ** | | | | **បច្ចុប្បន្ន** | | | |
|---|---|---|---|---|---|---|---|---|
| | ជាក្រុបខណ្ឌរាជការ | | ពុំមែនជារាជការ | | ជាក្រុបខណ្ឌរាជការ | | ពុំមែនជារាជការ | |
| | ក្រុម | នាក់ | ក្រុម | នាក់ | ក្រុម | នាក់ | ក្រុម | នាក់ |
| ១.នាយកដ្ឋានសិល្បៈ | ០១ | ២៨ | | | | | ០១ | ២៨ |
| ២.សាលាមធ្យមវរសេ | | | | | | | | |
| ៣.រាជធានីភ្នំពេញ | | | | | | | ០១ | ០៣ |
| ៤.ខេត្តសៀមរាប | | | | | | | ០៤ | ១១១ |
| ៥.ខេត្តកំពង់ធំ | | | | | ០១ | ៣០ | ០១ | ៤០ |
| ៦.ខេត្តបន្ទាយមានជ័យ | ០១ | ២០ | ០១ | ២០ | | | ០១ | ២០ |
| ៧.ខេត្តបាត់ដំបង | | | | | | | | |

- <u>ការពង្រឹងគុណភាព និងកិច្ចការអភិរក្ស</u> : - បានពង្រឹងតាមរូបភាពសម្តែង ណែនាំផ្ទាល់ និងផ្តល់ប័ណ្ណសម្គាល់

- បានរៀបចំមហោស្រពចម្រៀងខ្មែរជាសកលលើកទី ២ នៅមជ្ឈមណ្ឌលកោះពេជ្រពីថ្ងៃទី១១-២១ ធ្នូ ឆ្នាំ ២០១១

- រៀបចំព្រឹត្តិការណ៍អបអររំលឹកខួបអនុស្សាវរីយ៍នៃការបញ្ចូលបេតិកភណ្ឌរូបី និងអរូបី ចូលជាបេតិកភណ្ឌរូបីពិភពលោក និងចូលជាបេតិកភណ្ឌអរូបីនៃមនុស្សជាតិ បានប្រារព្ធពិធីនៅភូមិវប្បធម៌ខេត្តសៀមរាប នៅថ្ងៃទី ៣០ - ៣១ ខែធ្នូ ឆ្នាំ២០១១ ដល់ ថ្ងៃទី ០១ ខែ មករា ឆ្នាំ២០១២ និងផ្តល់វិញ្ញាបនបត្រ ដល់ក្រុមសិល្បៈ ក្រុមសិប្បកម្ម និងអ្នកជំនាញធ្វើម្ហូប បង្អែមខ្មែរ ចំនួន៣៥ក្រុមដែលបានចូលរួមក្នុងពិធីនោះ ។

**ខ- <u>ទំនាក់ទំនងជាមួយ UNESCO Paris</u> :**

- ស្នើសុំជំនួយអភិរក្ស ស្បែកធំបានលើកគម្រោងសុំជាមួយអន្តរជាតិទៅ យូណេស្កូ នូវគម្រោងអភិរក្សស្បែកធំ១គម្រោង។
- ស្នើសុំចុះបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីរបស់មនុស្សជាតិ ចាប៉ីដងវែង តម្បាញសូត្រល្ខោនខោល
- សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី "ការលើកស្ទួយ វប្បធម៌ និង ស្ថានភាពសេដ្ឋកិច្ចរបស់បងប្អូនជនជាតិដើមភាគតិច តាមរយៈ ការអនុវត្តន៍កម្មវិធីថ្នាក់ក្រោមជាតិសំរាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ" ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ៨ -៩ ខែ កញ្ញា ឆ្នាំ ២០១១ នៅខេត្តមណ្ឌលគិរី ដោយមាន អ្នកចូលរួមសរុបចំនួន ១០០ នាក់។

**គ- <u>ការចុះបញ្ជីគំរូ ICH.IN 01, 02, 03 រួចរាល់ជាស្ថាពរ</u> :**

- បានបញ្ជូនឯកសារគំរូ សម្រាប់ចុះបញ្ជីទៅគ្រប់មន្ទីរ

- បានទទួលមកវិញ ៖
    - ខេត្ត កំពង់ចាម បានចំនួន ១០០ %
    - ខេត្ត កំពង់ធំ បានចំនួន ១០០ %
    - ខេត្ត កំពង់ស្ពឺ បានចំនួន ១០០ %
    - ខេត្ត កំពត បានចំនួន ១០០ %
    - ខេត្ត បាត់ដំបង បានចំនួន ១០០ %
    - ខេត្ត ប៉ៃលិន បានចំនួន ១០០ %
    - ខេត្ត រតនៈគីរី បានចំនួន ១០០ %

៤.៧. <u>ការងារមត៌កមនុស្សរស់</u>

- បានផ្សព្វផ្សាយព្រះរាជក្រឹត្យស្តីពីប្រព័ន្ធមរតកមនុស្សរស់នៅកម្ពុជានៅ៖

ក -ខេត្តមណ្ឌលគីរី

- សិក្ខាសាលាផ្សព្វផ្សាយព្រះរាជក្រឹត្យស្តីពីប្រព័ន្ធមរតកមនុស្សរស់នៅកម្ពុជា នៅក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី ប្រព្រឹត្តទៅនៅក្នុងខែមីនា ឆ្នាំ២០១១

ខ - ខេត្តរតនគីរី

មានការចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និង សាលាខេត្ត ក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីព្រះរាជក្រឹត្យនៃប្រព័ន្ធ មរតកមនុស្សរស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា -

- សិក្ខាសាលាផ្សព្វផ្សាយព្រះរាជក្រឹត្យស្តីពីប្រព័ន្ធមរតកមនុស្សរស់នៅកម្ពុជានៅក្រុងបានលុង (បានប្រព្រឹត្តទៅនៅក្នុងខែ មីនា ២០១១) ។

គ -ខេត្តកំពង់ធំ

- មានការចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងសាលាខេត្ត នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីព្រះរាជក្រឹត្យ នៃប្រព័ន្ធមរតកមនុស្សរស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា (បានប្រព្រឹត្តទៅនៅក្នុងខែសីហា ឆ្នាំ ២០០៩)
- សិក្ខាសាលាផ្សព្វផ្សាយព្រះរាជក្រឹត្យស្តីពីប្រព័ន្ធមរតកមនុស្សរស់នៅកម្ពុជានៅខេត្តកំពង់ធំ (បានប្រព្រឹត្តទៅនៅក្នុងខែធ្នូ ឆ្នាំ២០១០) ។

ឃ - ខេត្តព្រះវិហារ

- មានការចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និង សាលាខេត្ត នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីព្រះរាជក្រឹត្យនៃប្រព័ន្ធមរតកមនុស្សរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សិក្ខាសាលាផ្សព្វផ្សាយព្រះរាជក្រឹត្យ ស្តីពីប្រព័ន្ធមរតកមនុស្សរស់នៅកម្ពុជានៅក្រុងបានលុង(បានប្រព្រឹត្តទៅនៅក្នុងខែមីនា ឆ្នាំ២០១១)
- ប្រជុំគណៈកម្មការ ០៥ លើក ៖ ជ្រើសបានបេក្ខភាព ១៣ រូប
- បានព្រាងគោរមងារ និងសញ្ញាសម្គាល់មត៌កមនុស្សរស់ កំពុងដាក់ស្នើទៅរាជរដ្ឋាភិបាលសុំការសម្រេច
- បានព្រាងឯកសាររួមខ្លឹមសារប្រកាសអន្តរក្រសួងស្តីពីប្របភពធនធាននិងលាភការរបស់មត៌កមនុស្សរស់ កំពុងដាក់ស្នើទៅរាជរដ្ឋាភិបាលសុំសម្រេច ។

**៤.៨. ការងារ MDG/F UNDP**

- ចងក្រងក្រុមសិប្បកម្ម (ប្រពៃណី, សិល្បកម្ម)

ក. ខេត្តរតនគីរី :

- ជួយគាំទ្រដល់សិប្បកម្មតំបាញ (ដោយមានអ្នកទទួលផលសរុបចំនួន ៣០៧នាក់ ជាជនជាតិដើមភាគតិច និងក្រុមគ្រួសាររបស់ពួកគាត់)
- ចងក្រងក្រុមអ្នកផលិតនៅ ស្រុកអូរជុំ និង កូនមុំ ( ដែលជាក្រុមសិប្បកម្មតំបាញប្រពៃណីជនជាតិទំពួន) និង នៅស្រុក វ៉ឺនសៃ ( ជាក្រុមផលិត ពាង នឹង ក្អម តាមបែបប្រពៃណីបុរាណ របស់ជនជាតិឡាវ)

បណ្តុះបណ្តាលដល់ក្រុមផលិត ( ផ្នែកហិរញ្ញវត្ថុ ផ្នែកគ្រប់គ្រងទីផ្សារជនបទ ផ្នែករៀបចំគម្រោងពាណិជ្ជកម្ម។ល។)

- ពង្រឹងបណ្តាញទីផ្សារ (ថ្នាក់ស្រុក ថ្នាក់ខេត្ត នឹងថ្នាក់ជាតិ)
- ជួយគាំទ្រដល់ដៃគូរថ្នាក់ខេត្ត (មានដូចជា អង្គការ CANDO អង្គការ CEDAC ដែលអង្គការទាំងពីរនេះបាន ជួយគាំទ្របន្តដល់ក្រុមផលិតរបស់យើង)
- សហការជាមួយនឹងគណៈកម្មាធិការជាតិជំរុញភូមិ១ផលិតផល១ ដើម្បីផ្តល់នូវលិខិតបញ្ជាក់ទទួលស្គាល់ ផលិតផល

-ជួយគាំទ្រដល់ក្រុមសម្តែងសិល្បៈ (មានចំនួនសរុប ២៥នាក់)

- សហការជាមួយនឹង សិល្បៈខ្មែរអមតៈ ដើម្បីថតចំលងចំរៀងប្រពៃណីរបស់ជនជាតិទំពួននឹងរៀបចំជាថាស CD ដែលមានចំណងជើងថា "សូរ្យសៀងចម្រៀងពីបឹង" ជាមួយនឹងក្រុមសិល្បៈយក្សឡោម។
- ជួយគាំទ្រដល់ផ្នែកសំដែងរបាំទស្សនីយភាពនៅទីក្រុងភ្នំពេញ (មាននៅ Living Room Gazolina, មជ្ឈមណ្ឌល Bophana
- ដំណើរការសាងសង់មជ្ឈមណ្ឌលវប្បធម៌សំរាប់ជនជាតិដើមភាគតិច បង្កើតនូវគោលគំនិត និងផែនការ គ្រប់គ្រង
- សាងសង់មជ្ឈមណ្ឌលវប្បធម៌សម្រាប់ជនជាតិដើមភាគតិចនៅ មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តរតនគីរី ។

ខ.ខេត្តមណ្ឌលគីរី :

- ចងក្រងក្រុមអ្នកផលិតនៅ ស្រុកសែននោរម្យ និង នៅស្រុកអូររាំង ( ដែលជាក្រុមសិប្បកម្មតម្បាញប្រពៃណី និង ជ័រទឹក) និងនៅស្រុក ពេជ្រដា ( ជាក្រុមតំបាញសិប្បកម្ម តាមបែបប្រពៃណីបុរាណ )។ ក្រុមអ្នកទទួលផល ទាំងអស់ជាជនជាតិព្នង។
- បណ្តុះបណ្តាលដល់ក្រុមផលិត ( ផ្នែកហិរញ្ញវត្ថុ ផ្នែកគ្រប់គ្រងទីផ្សារជនបទ ផ្នែករៀបចំគម្រោង ពាណិជ្ជកម្ម។ល។)

ពង្រឹងបណ្តាញទីផ្សារ (ថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ)

- ជួយគាំទ្រដល់ដៃគូរថ្នាក់ខេត្ត (មានដូចជា អង្គការ MVI និងអង្គការVFC ដែលអង្គការទាំងពីរនេះបានជួយ គាំទ្របន្តដល់ក្រុមផលិតរបស់យើង)
- សហការជាមួយនឹងគណៈកម្មាធិការជាតិជំរុញភូមិ១ ផលិតផល ១ ដើម្បីផ្តល់នូវលិខិតបញ្ជាក់ទទួលស្គាល់ ផលិតផល
- ជួយគាំទ្រដល់ក្រុមសម្តែងសិល្បៈ
- ឧបត្ថម្ភសំលៀកបំពាក់សិល្បៈ ជូនទៅមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ខេត្តមណ្ឌលគិរី
- បង្កើតនូវមជ្ឈមណ្ឌលឯកសារនិងស្រាវជ្រាវ ជាមួយអង្គការ (NOMAD-RSI)-
- បង្កើតនូវបណ្ណាល័យ ការតាំងពិពណ៌ បញ្ចាំងកុន ព្រឹត្តិប័ត្រ សកម្មភាពផ្នែកវប្បធម៌នៅក្នុងភូមិ

- ជួយគាំទ្រដល់ការចងក្រងក្រុម ជួយខ្លួនឯង
- ការស្រាវជ្រាវ និង ការបោះពុម្ពផ្សាយ ( សៀវភៅពីរក្បាល និពន្ធដោយលោក Sylvain Vogel នឹងត្រូវបានបោះពុម្ពក្នុងចន្លោះខែកញ្ញា និងតុលា) ទិដ្ឋភាពវប្បធម៌និងប្រពៃណីរបស់ជនជាតិព្នងនៅខេត្តមណ្ឌលគីរី ។

គ.ខេត្តកំពង់ធំ :

- ជួយគាំទ្រដល់សិប្បកម្មតម្បាញ (ដោយមានអ្នកទទួលផលសរុបចំនួន ១៤១នាក់ ជាជនជាតិខ្មែរ និងបងប្អូនជនជាតិដើម ភាគតិចកួយ និងក្រុមគ្រួសាររបស់ពួកគាត់)
- ចងក្រងក្រុមអ្នកផលិតនៅ ស្រុកប្រាសាទបល្ល័ង ស្រុកសណ្ដាន់ និងស្រុកប្រាសាទសំបូរ ( ដែលជាក្រុមសិប្បកម្មតម្បាញប្រពៃណីកន្ត្រក ជនជាតិកួយ និងខ្មែរ
- បណ្ដុះបណ្ដាលដល់ក្រុមផលិត ( ផ្នែកហិរញ្ញវត្ថុ ផ្នែកគ្រប់គ្រងទីផ្សារជនបទ ផ្នែករៀបចំគម្រោងពាណិជ្ជកម្ម ។ល។) ពង្រឹងបណ្ដាញទីផ្សារ (ថ្នាក់ស្រុក ថ្នាក់ខេត្ត នឹងថ្នាក់ជាតិ)
- ជួយគាំទ្រដល់ដៃគូរថ្នាក់ខេត្ត (មានដូចជា អង្គការ MODE អង្គការ COWs ដែលអង្គការទាំងពីរនេះបានជួយគាំទ្របន្តដល់ក្រុមផលិតរបស់យើង)
- សហការជាមួយនឹងគណៈកម្មាធិការជាតិជំរុញភូមិ១ ផលិតផល ១ ដើម្បីផ្ដល់នូវលិខិតបញ្ជាក់ទទួលស្គាល់ផលិតផល
- ជួយគាំទ្រដល់ក្រុមសម្ដែងសិល្បៈ(មានចំនួនសរុប៤៥នាក់ ជាសិស្ស និង ២នាក់ទៀតជាគ្រូបង្រៀន នៅស្រុកប្រាសាទសំបូរ)
- ជួយគាំទ្រដល់សាលាកំពង់ឈើទាល ក្នុងការបង្ហាត់បង្រៀនសំដែងសិល្បៈ តាមរយៈការចាប់ដៃគូរជាមួយនឹងអង្គការសិល្បៈខ្មែរអមតៈ និងមន្ទីរវប្បធម៌វិចិត្រសិល្បៈ ខេត្តកំពង់ធំ
- ការបោះពុម្ពផ្សាយ (សៀវភៅមួយត្រូវបានបោះពុម្ពផ្សាយដោយលោក Bruno Bruguier, ដែលជាសមាជិករបស់សាលបារាំងចុងបូព៌ា
- មគ្គុទេសក៍បុរាណវិទ្យានៃប្រទេសកម្ពុជា ភាគ ២ : សំបូរព្រៃគុក និង បឹងទន្លេសាប ។

ឃ- ខេត្តព្រះវិហារ

- ជួយគាំទ្រដល់ក្រុមផលិជ័រទឹក (ដោយមានអ្នកទទួលផលសរុបចំនួន ៩២ នាក់ ជាជនជាតិដើមភាគតិចនិងក្រុមគ្រួសាររបស់ពួកគាត់)
- ចងក្រងក្រុមអ្នកផលិតនៅ ស្រុកត្បែងមានជ័យ ស្រុករវៀង ស្រុកឆែប និង នៅស្រុក ជាំក្សាន្ត ( ដែលជាក្រុមសិប្បកម្ម ប្រពៃណី ជ័រទឹក ហើយក្រុមអ្នកទទួលផលទាំងអស់ជាជនជាតិកួយ)។
- បណ្ដុះបណ្ដាលដល់ក្រុមផលិត ( ផ្នែកហិរញ្ញវត្ថុ ផ្នែកគ្រប់គ្រងទីផ្សារជនបទ ផ្នែករៀបចំគម្រោងពាណិជ្ជកម្ម។ល។)
- ពង្រឹងបណ្ដាញទីផ្សារ (ថ្នាក់ស្រុក ថ្នាក់ខេត្ត នឹងថ្នាក់ជាតិ)
- ជួយគាំទ្រដល់ដៃគូរថ្នាក់ខេត្ត (មានដូចជា អង្គការ Ponlok Khmer និង អង្គការ NTFP-EP ដែលអង្គការទាំងពីរនេះ បានជួយគាំទ្របន្តដល់ក្រុមផលិតរបស់យើងក្នុងផ្នែកពាណិជ្ជកម្មជ័រទឹក)
- សហការជាមួយនឹងគណៈកម្មាធិការជាតិជំរុញភូមិ១ ផលិតផល ១ ដើម្បីផ្ដល់នូវលិខិតបញ្ជាក់ទទួលស្គាល់ផលិតផល
- ជួយគាំទ្រដល់ក្រុមតំបាញប្រពៃណី (អ្នកទទួលផលមានចំនួនសរុប ៧៤ នាក់ ដែលជាជនជាតិដើមភាគតិចនិងក្រុមគ្រួសាររបស់ពួកគាត់)

- ចងក្រងក្រុមអ្នកផលិតនៅ ស្រុក ស្រុករៀង ( ដែលជាក្រុមសិប្បកម្មតំបាញប្រពៃណីហើយក្រុមអ្នកទទួលផលទាំងអស់ជាជនជាតិកួយ)។
- បណ្តុះបណ្តាលដល់ក្រុមផលិត ( ផ្នែកហិរញ្ញវត្ថុ ផ្នែកគ្រប់គ្រងទីផ្សារជនបទ ផ្នែករៀបចំគម្រោងពាណិជ្ជកម្ម។ល។)
- ពង្រឹងបណ្តាញទីផ្សារ (ថ្នាក់ស្រុក ថ្នាក់ខេត្ត នឹងថ្នាក់ជាតិ)
- ជួយគាំទ្រដល់ដៃគូរថ្នាក់ខេត្ត (មានដូចជា អង្គការ FLD ដែលអង្គការនេះបានជួយគាំទ្របន្តដល់ក្រុមផលិតរបស់យើង
- សហការជាមួយនឹងគណៈកម្មាធិការជាតិជំរុញភូមិ១ ផលិតផល ១ ដើម្បីផ្តល់នូវលិខិតបញ្ជាក់ទទួលស្គាល់ផលិតផល
- ជួយគាំទ្រដល់ផ្នែកសំដែងរបាំទស្សនីយភាព (មានអ្នកទទួលផលសរុបចំនួន ២២ នាក់ដែលជាក្រុមសម្តែងជនជាតិភាគតិចកួយ)

ជួយផ្គត់ផ្គង់សំលៀកបំពាក់ និង សម្ភារៈ ដល់ក្រុមសម្តែងរបាំយីកេដែលជាជនជាតិកួយ

- ជួយគាំទ្រដល់អនាគតសារមន្ទីរធម្មជាតិសកលនៅខេត្តព្រះវិហារ
- អ្នកជំនាញក្នុងការបង្កើតនូវខ្លឹមសារក្នុងការដាក់តាំងបង្ហាញពិព៌ណនៅក្នុងសារមន្ទីរត្រូវបានអញ្ជើញឲ្យចូលរួម
- ការស្រាវជ្រាវ និង ការបោះពុម្ពផ្សាយ ( សៀវភៅមួយក្បាល និពន្ធដោយសាស្រ្តាចារ្យ Gérad Diffloth ដែលជាសមាជិកសាលា បារាំងចុងបូព៌ា) ជនជាតិកួយៈ វាក្យស័ព្ទប្រវត្តិសាស្រ្ត ។

### ៤.៩. ការស្រាវជ្រាវក្បាច់គុណបុរាណ

- បានដំណើរការស្រាវជ្រាវ ៖
  + - លើស្ថានីយបុរាណ/ប្រវត្តិសាស្រ្ត
    - ថតយករូបភាព រូបចម្លាក់ដែលពាក់ព័ន្ធនិងក្បាច់គុនបុរាណនៅប្រាសាទបាយ័ន ប្រាសាទបាពួន ប្រាសាទអង្គរវត្ត ប្រាសាទបន្ទាយឆ្មារ ជញ្ជាំងព្រះវិហារវត្តកំពង់ត្រឡាចលើ ទុកដាក់ជាឯកសារ និងថតជាខ្សែវីឌីអូ
    - រកឃើញអ្នកចេះក្បាច់គុនបុរាណខ្មែរ នៅតាមខេត្ត ក្រុង ទាំង២៤ បានចំនួន ៣៥ នាក់
    - លើកសំណើសុំអន្តរាគមន៍ពីអន្តរជាតិ ដើម្បីសង្គ្រោះក្បាច់គុណបុរាណខ្មែរ ១គម្រោង ។

### ៤.១០. ការងារអភិវឌ្ឍន៍តំបន់ត្រីកោណ CLV/DATA

- បានចូលរួមរាល់ការប្រជុំនៅខេត្ត អាត់តាក់ពើ រវាងប្រទេសកម្ពុជា ឡាវ វៀតណាម ស្តីពី " គម្រោងការការងារអភិវឌ្ឍន៍តំបន់ត្រីកោណ CLV/DATA " ។

### ៤.១១. ការងារប្រយុទ្ធនឹងជំងឺអេដស៍/គ្រឿងញៀន

- បានចូលរួមរាល់ការប្រជុំ សិក្ខាសាលា សន្និបាតដែលរៀបចំដោយគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺអេដស៍
- មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តបានសហការជាមួយអង្គការក្រៅរដ្ឋាភិបាល បាននិពន្ធ និងរៀបចំកម្មវិធីសម្តែងសិល្បៈទស្សនីយភាពអប់រំអំពី " បញ្ហាគ្រឿងញៀន និងជំងឺអេដស៍ " ចំនួន១៤៤ រឿង ចេញសម្តែងបាន៥១២ លើក ( ២៤ខេត្ត ក្រុង )
- បានសហការផ្សព្វផ្សាយខ្លឹមសារសំខាន់ៗ នៃកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ជាមួយមជ្ឈមណ្ឌល MAHKOTA Medical Centre ។

**៤.១២.ការងារបេតិកភណ្ឌអរូបីរាជធានី-ខេត្ត ៖**

**មន្ទីររាជធានីភ្នំពេញ** បានប្តូរច្បាប់កាហ្វេវីដេអូបានចំនួន២២៧ច្បាប់-ច្បាប់លក់ថាសចំនួន៧១ច្បាប់ និងច្បាប់សេវាកំសាន្តហ្គេមកំព្យូទ័រចំនួន៧៧ច្បាប់ ។ បានបញ្ជូនសំណុំលិខិតសុំច្បាប់អាជីវកម្មភាពយន្ត-វីដេអូ ជូនថ្នាក់ក្រសួងពិនិត្យ និងសម្រេច ។ បានដឹកនាំក្រុមសិល្បៈមហាជន រាជធានីភ្នំពេញ (ក្រុមល្ខោនបាសាក់ ល្ខោននិយាយ និងឆាកកំប្លែង) ចូលរួមប្រឡងក្នុងពិធីមហោស្រពសិល្បៈមហាជនទូទាំងប្រទេស នៅសាលសន្និសីទចតុមុខ។ បានរៀបចំប្រឡងចម្រៀងបុរាណ-សម័យ ជ្រើសរើសអ្នកចម្រៀងឯកចំនួន៤នាក់ (ស្រី២នាក់) ចម្រៀងសម័យ២នាក់ (ស្រី១នាក់) ដើម្បីចូលរួមមហោស្រពចម្រៀងសកលខ្មែរលើកទី២ នៅមជ្ឈមណ្ឌលកោះពេជ្រ។ រៀបចំការកំសាន្តក្នុងបុណ្យចូលឆ្នាំថ្មីនៅមណ្ឌលវត្តភ្នំមានៈ ប្រគុំតន្ត្រីសម័យជូនទស្សនាចំនួន០២យប់ អាយ៉ៃឆ្លងឆ្លើយ និងឆាកកំប្លែងចំនួន០១យប់-ចាត់តាំងឱ្យមានល្បែងប្រជាប្រិយចំនួន០៣ថ្ងៃ និងចាក់ធុងបាស់ជូនកំសាន្តចំនួន០៣យប់ នៅស្ពាននាគ និងនៅសួនច្បារមុខវត្តបុទុម ដោយទទួលបានលទ្ធផលល្អ ។ បានចូលរួមរៀបចំកម្មវិធីសិល្បៈ (អាយ៉ៃឆ្លងឆ្លើយ-តន្ត្រីសម័យ និងឆាកកំប្លែង) នៅមណ្ឌលវត្តភ្នំ ក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណា ព្រះបាទបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងពិធីបុណ្យជាតិផ្សេងៗ។ ក្រុមការងារត្រួតពិនិត្យស្លាកយីហោ ប៉ាណូផ្សព្វផ្សាយពាណិជ្ជកម្មរាជធានីភ្នំពេញ (គណៈកម្មការថ្នាក់ក្រុងដែលមានមន្ទីរចូលរួមជាមួយ) ចុះធ្វើការត្រួតពិនិត្យគ្រប់សាលាខណ្ឌ សម្រេចផ្តល់អាជ្ញាប័ណ្ណ (ស្លាកយីហោ ស្លាកសញ្ញា ប៉ាណូផ្សព្វផ្សាយពាណិជ្ជកម្ម) ដែលមានលក្ខណៈត្រឹមត្រូវតាមសេចក្តីណែនាំរបស់ក្រសួងបានចំនួន៣.០០២ច្បាប់ ។ បានប្តូរលិខិតអនុញ្ញាតច្បាប់អាជីវកម្មសិល្បៈសូនរូបលើមុខរបរ៥យ៉ាងចំនួន៣៣៩ច្បាប់ និងចេញច្បាប់ថ្មីបានចំនួន២៩ច្បាប់។ បានចុះស្រាវជ្រាវតាមមូលដ្ឋាន សង្កាត់ ខណ្ឌ ក្នុងរាជធានីភ្នំពេញ ដើម្បីផ្តល់ព័ត៌មានពីក្បាច់គុនបុរាណខ្មែរជូនក្រសួងជ្រាប និងសហការជាមួយនឹងមន្ត្រីក្រសួងចុះធ្វើការស្រាវជ្រាវពីឯកសារត្បាញហូលផាមួង នៅមូលដ្ឋានសង្កាត់កោះដាច់ ខណ្ឌឫស្សីកែវ ដោយទទួលបានលទ្ធផលល្អ ។ ទោះបីមន្ទីរ រួមជាមួយការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈខណ្ឌទាំង៨ ខិតខំដោយស្មារតីប្រុងប្រយ័ត្នខ្ពស់ក្នុងការអនុវត្តការងារជំនាញតាមទិសដៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ របស់សាលារាជធានីភ្នំពេញយ៉ាងណាក្តី ក៏លទ្ធផលដែលសម្រេចបានគឺនៅតែមានភាពឆកល្វែងជានិច្ចព្រោះបញ្ហាធនធានមនុស្ស ល្បឿននៃការរីកចម្រើនរបស់រាជធានីភ្នំពេញមានសន្ទុះខ្លាំងក្លា ព្រមទាំងកត្តាគួបផ្សំគឺកង្វះខាតថវិកា មធ្យោបាយ និងមូលដ្ឋានសម្ភារៈ បើប្រៀបធៀបទៅនឹងផែនការឆ្នាំគឺសម្រេចបានត្រឹមតែ៩០ភាគរយប៉ុណ្ណោះ ។

**មន្ទីរខេត្តកណ្តាល** បានជ្រើសរើស និងបង្ហាត់ល្ខោនបាសាក់-ល្ខោនយីកេ-របាំ-ឆៃយ៉ាំ ដល់សិស្សវិទ្យាល័យក្នុងក្រុងតាខ្មៅ។ ក្រុមសិល្បៈមហាជនដែលជ្រើសរើសក្នុងមូលដ្ឋានខេត្ត បានទៅចូលរួមក្នុងមហោស្រពសិល្បៈមហាជនទូទាំងប្រទេស នៅរាជធានីភ្នំពេញ។ បាននិពន្ធបទភ្លេង ចម្រៀងថ្មីចំនួន៤បទ ចូលរួមមហោស្រពតន្ត្រីសម័យ នៅក្រសួងព័ត៌មាន។ បានរៀបចំរបាំត្រុដិ របាំជូនពរ និងក្រុមភ្លេងពិណពាទ្យ ចុះសម្តែងបណ្តេញឧបទ្រព្យចង្រៃពីឆ្នាំចាស់ និងជូនពរឆ្នាំថ្មីតាមភូមិគ្រឹះថ្នាក់ដឹកនាំក្នុងខេត្ត និងឥស្សរជនមួយចំនួននៅរាជធានីភ្នំពេញចំនួន១៥លើក ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។ បានហ្វឹកហាត់ និងថតនៅទូរទស្សន៍ប៉ុស្តិ៍បាយ័នសិល្បៈយីកេរឿង "ចិត្តតិរច្ឆាន"។ បានចុះបញ្ជីសារពើភណ្ឌបេតិកភណ្ឌអរូបីចំនួន០៩ស្រុក-ក្រុង។ ការជម្រុញឱ្យអាជីវករធ្វើច្បាប់លើកដាក់តាំងផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម និងផ្ទាំងសញ្ញាសម្រេចបានសរុបចំនួន៣៣៤

ច្បាប់។ ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ បានចុះពិនិត្យក្រុមក្បាច់គុនខ្មែរ នៅភូមិពោធិរាល់ ឃុំភ្នំបាត និងឯកឧត្តម និងប្រតិភូក្រសួងព័ត៌មាន ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងទូរទស្សន៍អប្សរាបានចុះពិនិត្យ និងថតការបង្ហាញពីរបៀបថ្វាយបង្គំគ្រូ និងការបង្ហាញក្បាច់គុនមួយចំនួននៅតំបន់ភ្នំព្រះរាជទ្រព្យ។ លោកវរៈសេនីយ៍ត្រី អ៊ុន សំអាត នាយសេនាធិការតំបន់ប្រតិបត្តិការសឹករងកណ្តាល និងជាសិក្ខាកាមវគ្គទី៣ ផ្នែកភាពយន្ត នៃសមាគមន៍អ្នកនិពន្ធខ្មែរ ថតខ្សែភាពយន្តឯកសារស្តីពី ប្រវត្តិទីទួល និង វិហារប្រទេស ស្ថិតក្នុងភូមិសាស្រ្ត ភូមិព្រៃកតាបែន ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្តាល ចប់ជាស្ថាពរ។

ការប្រឈមៈ ការគ្រប់គ្រងចុះបញ្ជីសារពើភណ្ឌ ដូចជាការកំណត់ព្រំប្រទល់ទីទួលបុរាណនានា ការបោះបង្គោលស្លាកនីយ៍បុរាណធ្វើមិនទាន់បានទូលំទូលាយ។ ការអនុញ្ញាតធ្វើច្បាប់អាជីវកម្មលើកដាក់តាំងផ្ទាំងយីហោ ក៏ជាបញ្ហាលំបាក ដោយអាជីវករមិនព្រមធ្វើច្បាប់ សំអាងថាបានបង់ពន្ធដាររួចហើយ។ ការលួចចម្លងថាសនៅបន្តធ្វើសកម្មភាព ការជួលលក់ថាសខុសច្បាប់នៅតែលួចលាក់ធ្វើចរាចរតាមទីផ្សារ ទោះបីមានការចុះបង្ក្រាបពីគណៈកម្មការចម្រុះអន្តរក្រសួងបន្តបន្ទាប់ក៏ដោយ។ មន្ទីរក្នុងឆ្នាំនេះមានការរីកចម្រើនបង្គួរដោយផ្នែកជំនាញធ្វើការទប់ស្កាត់ករណីលួចវត្ថុបុរាណនៅតាមទីវត្តអារាម និងការជីកកកាយនៅតាមទីទួលស្ថានីយ៍បុរាណនានាក្នុងខេត្តយើងសម្រេចបានបង្គួរ នៅមានករណីលួចឆាយទួលខ្លះក្នុងដីកម្មសិទ្ធិ។ ការងារសិល្បៈទស្សនីយភាព សិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ យើងបាននឹងកំពុងធ្វើសកម្មភាពយ៉ាងសកម្ម ។

**មន្ទីរខេត្តតាកែវ** បានបង្ហាត់ល្ខោនយីកេរឿង "មាយាស្ត្រី" ដល់សិល្បៈមហាជនក្រុងដូនកែវ និងបង្ហាត់អំពីក្បាច់បាទដល់សិស្សជំនាន់ក្រោយជាប្រចាំ។ ចុះបង្ហាត់សិល្បៈមហាជន៣ក្រុម ក្នុងស្រុកបាទីបាន០៦លើក-បង្ហាត់របាំដល់សិស្សក្រៅប្រព័ន្ធបាន០៣របាំ និង ហាត់រឿងសុវណ្ណសាម និងរឿងពុទ្ធប្រវត្តិ។ សម្តែងរបាំជូនពរ អបអរសាទរខួបអនុស្សាវរីយ៍លើកទី៣២ ថ្ងៃជ័យជំនះ ៧មករា បាន០១លើក និងពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិ មានរបាំជូនពរ របាំត្រុដ តាមមន្ទីរ អង្គភាពក្នុងខេត្ត និងសម្តែងល្ខោនយីកេ ប្រគុំតន្ត្រីសម័យ ចំនួន៣យប់។ ចុះផ្សព្វផ្សាយអនុក្រឹត្យស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈភាពយន្ត វីដេអូ និងសារាចរណែនាំដល់អាជីវករប្រកបអាជីវកម្មលើវិស័យនេះបាន០៤វគ្គ អ្នកចូលរួមចំនួន៥៧នាក់ ព្រមទាំងធ្វើការអប់រំផងដែរដល់អាជីវករមិនអនុញ្ញាតឱ្យបញ្ចាំងរូបអាសអាភាស។ សម្តែងអំពីក្បាច់យីកេថតដាក់ទូរទស្សន៍អាស៊ីអាគ្នេយ៍បាន១លើក។ ចុះស្រាវជ្រាវអំពីសិប្បកម្មតម្បាញសូត្របាន៣លើក ដើម្បីចងក្រងទុកជាឯកសារ។ បានចុះស្រាវជ្រាវអំពីក្បាច់គុនបុរាណខ្មែរបាន២លើក នៅស្រុកកោះអណ្តែត។ ចងក្រងឯកសារ ស្តីពីប្រវត្តិភូមិ-ឃុំ-ស្រុកក្នុងខេត្តដោយបានរៀបចំធ្វើសៀវភៅចំនួន១៥ក្បាល និងបានចូលរួមមហោស្រពខ្លែង នៅកោះពេជ្របានចំនួន១លើក។ មន្ទីរសម្រេចបាននូវសកម្មភាពតាមផែនការដែលបានលើកឡើងរួមមាន ការចុះផ្សាយអប់រំដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានឃុំនានាក្នុងខេត្ត អំពីកិច្ចការពារសម្បត្តិបេតិកភណ្ឌវប្បធម៌ជាតិ។ ការងារសារមន្ទីរ បានរៀបចំវត្ថុសិល្បៈបុរាណដើម្បីងាយស្រួលក្នុងការគ្រប់គ្រងសម្បត្តិវប្បធម៌។ ការងារសិល្បៈទស្សនីយភាព បានចុះអប់រំដល់ក្រុមសិល្បៈមហាជនដើម្បីតម្រង់ទិសឱ្យត្រូវក្បួនខ្នាតជាតិ។ ការងារសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ ចុះត្រួតពិនិត្យសកម្មភាពបញ្ចាំងភាពយន្ត-វីដេអូអាសអាភាសនៅតាមមូលដ្ឋានស្រុកក្នុងខេត្តធ្វើកិច្ចសន្យាជាមួយអាជីវករក្នុងការហាមបញ្ចាំងរឿងអាសអាភាស កន្លែងជួល-លក់កាសែ្សតថាស ដែលគ្មានទិដ្ឋាការ។

**មន្ទីរខេត្តកំពត** សិល្បៈទស្សនីយភាព បានហាត់រំលឹកស្នាដៃរបាំប្រពៃណី និងរបាំឆៃយ៉ាំ នៅរៀងរាល់ចុងសប្តាហ៍។ ផ្សព្វផ្សាយថាសភ្លេងពិណពាទ្យខ្មែរជូនការិយាល័យវប្បធម៌ស្រុក-ក្រុង។ ដឹកនាំក្រុមល្ខោនយីកេស្រុកឈូក ទៅចូលរួមមហោស្រពសិល្បៈមហាជនទូទាំងប្រទេស ឆ្នាំ២០១១។ សហការចាត់តាំងកម្មវិធីកំសាន្តល្បែងប្រជាប្រិយ អបអរពិធីបុណ្យចូលឆ្នាំថ្មី រយៈពេល០៣ថ្ងៃ និង សហការរៀបចំកម្មវិធីកំសាន្ត ល្បែងប្រជាប្រិយសម្រាប់ថតផ្សព្វផ្សាយតាមរយៈទូរទស្សន៍ជាតិ នៅឃុំត្រពាំងធំ ស្រុកទឹកឈូ។ សហការជាមួយបណ្តាការិយាល័យវប្បធម៌ស្រុក-ក្រុង ក្នុងការងារស្រាវជ្រាវ និងសិក្សាក្បាច់គុនបុរាណខ្មែរ។ ចាត់តាំងការបញ្ចាំងភាពយន្តបម្រើសាធារណៈជននៅស្រុកឈូកដើម្បីអបអរទិវាវប្បធម៌ជាតិលើកទី១៣ នៅតំបន់ប្រាសាទភ្នំថ្មពូក។ សហការជាមួយការិយាល័យវប្បធម៌ក្រុងកំពត ក្នុងការចុះស្រង់ស្ថិតិសិល្បៈសូនរូប និងសិប្បកម្ម ឆ្ពោះទៅកម្មវិធីផ្តល់សេវាសាធារណៈច្រកចេញចូលតែមួយ។ ការងាររបស់មន្ទីរ បើប្រៀបធៀបទៅនឹងឆ្នាំ២០១០ យើងបានសម្រេចការវិវត្តផ្នែកគុណភាពមួយពិតមែនតែពុំទាន់ឆ្លើយតបបានល្អទៅនឹងតម្រូវការចាំបាច់នៃការអភិវឌ្ឍវិស័យវប្បធម៌។ ទោះបីជាជួបការលំបាកលើផ្នែកធនធានមនុស្ស និងថវិកាក៏ដោយ ក៏យើងត្រូវតែបន្តខិតខំសម្រេចទិសដៅប្រចាំឆ្នាំជាជំហានៗ ។

**មន្ទីរខេត្តកែប** បានដឹកនាំក្រុមសិល្បៈមហាជន ផ្នែកល្ខោនបាសាក់០១ក្រុម ទៅចូលរួមទិវាវប្បធម៌ជាតិ ០៣ មីនា ឆ្នាំ២០១១ លើកទី១៣ និងពិធីបិទមហោស្រពសិល្បៈមហាជនទូទាំងប្រទេស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ។ បានសហការជាមួយសមាគមសិល្បករគោកធ្លក សម្តែងសិល្បៈជូនប្រជាពលរដ្ឋទស្សនាកំសាន្តចំនួន០៤ទីតាំងនៅក្នុងខេត្ត ដែលបាននាំមកនូវផ្ទាំងទស្សនីយភាពចំនួន០២រឿងគឺ "ព្រះធិនវង្ស នាងពៅ" សម្តែងជាយីកេដិកង់ និងរឿង "សព្វសិទ្ធ" សម្តែងជាល្ខោនស្បែកតូច។ បានចុះណែនាំដល់ម្ចាស់សិប្បកម្មក្បាច់ចម្លាក់ឱ្យគោរពទៅតាមក្បួនខ្នាត និងរចនាបទខ្មែរ និងបានចុះសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីត្រួតពិនិត្យស្លាកយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម និងស្លាកសញ្ញាផ្សេងៗចំនួន០៥លើក ។

**មន្ទីរខេត្តព្រះសីហនុ** បានចុះបង្រៀនដល់សិល្បៈមហាជន ក្រុមបក្សីចាំក្រុង មានភ្លេងពិណពាទ្យ ភ្លេងប្រពៃណី របាំគោះត្រឡោក និងឆៃយ៉ាំ។ បានដឹកនាំក្រុមសិល្បៈមហាជន បក្សីចាំក្រុង ទៅសម្តែងជូនភ្ញៀវជាតិ អន្តរជាតិចំនួន០៦លើក នៅម៉ូលតែល សុខា។ ទៅចូលរួមប្រឡងមហោស្រពសិល្បៈមហាជនទូទាំងប្រទេសឆ្នាំ២០១១ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ ដោយលើកយករឿង "គ្រោះគ្រឿងញៀន"។ ទៅសម្តែងក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ នៅវត្តក្រោម ជូនមហាជនទស្សនាមានដូចជាៈ ឆៃយ៉ាំ រាំវង់ លាក់កន្សែង ចោលឈូង និងទាញព្រ័ត។ ការផ្តល់សេវាកម្មលើវិស័យវប្បធម៌ក្នុងការិយាល័យច្រកចេញចូលតែមួយមានទទួលពាក្យស្នើសុំមានចំនួន៣៧ច្បាប់ និងចេញប័ណ្ណអនុញ្ញាតចំនួន២៧ច្បាប់ និង លិខិតអនុញ្ញាតចំនួន១០ច្បាប់។ បានត្រួតពិនិត្យស្លាកសញ្ញាយីហោ របស់ក្រុមហ៊ុន ផ្សព្វផ្សាយពាណិជ្ជកម្ម ផល សារ៉េត បានចំនួន០៦លើក តាមរយៈមន្ទីរជំនាញបានចំនួន៤៧ច្បាប់។ បានចុះធ្វើច្បាប់ឱ្យអាជីវករធ្វើអាជីវកម្មលើស្លាកសញ្ញាបានចំនួន០២កន្លែង និងណែនាំដល់អាជីវករលើផ្នែកបច្ចេកទេស ក្នុងការដំឡើងផ្ទាំងស្លាកយីហោត្រូវសរសេរឱ្យបានត្រឹមត្រូវ។ បានដាក់បញ្ចាំងខ្សែភាពយន្តខ្នាតធំចំនួន០៦លើក របស់អនុព័ន្ធមជ្ឈមណ្ឌលវប្បធម៌បារាំង នៅឆ្នេរអូរឈើទាល មានអ្នកចូលរួមទស្សនាចំនួន៩០៨នាក់ និង បានចុះ

បញ្ជីខ្សែភាពយន្តរបស់ក្រុមហ៊ុន សាន់ ដេ មានចំនួន០៥រឿង ស្មើនិង៦០ភាគ ។ បានដឹកនាំបេក្ខជន០៣នាក់ ចូលរួមមហោស្រពចម្រៀងខ្មែរសកល នៅមជ្ឈមណ្ឌលកោះពេជ្រ។

**មន្ទីរខេត្តកោះកុង** បានដឹកនាំក្រុមសិល្បៈសិស្សានុសិស្សខេត្តចូលរួមសម្តែងរឿង "ថៅកែគីរីវិចិរិល" នៅក្នុងមហោស្រពសិល្បៈមហាជនទូទាំងប្រទេស។ បានហ្វឹកហាត់រាំ និងរឿងដែលទាក់ទងទៅនឹងការអប់រំអំពីគ្រឿងញៀនដល់សិស្សសម្រាប់ចេញទៅសម្តែងក្នុងពិធីបុណ្យផ្សេងៗ និងបានទទួលសិស្សានុសិស្សដែលស្ម័គ្រចិត្តចូលមកហាត់របាំបានចំនួន៦៥នាក់។ មន្ទីរបានដឹកនាំក្រុមសិល្បៈទៅសម្តែងនៅខេត្តក្រាត ប្រទេសថៃ បាន០១លើក ក្នុងទិវាកុមារអន្តរជាតិ។ បានចុះផ្សព្វផ្សាយអំពីការលក់កាសែតថាសថតចម្លងខុសច្បាប់នៅស្រុកបុទុមសាគរ និងចុះធ្វើការផ្សព្វផ្សាយហាមឃាត់អំពីការធ្វើអាជីវកម្មខ្សែភាពយន្តរឿង "ក្រុមអាល់កៃដា នៅក្នុងទ្វីបអារ៉ាប់" ដល់អាជីវករលក់កាសែតវីដេអូគ្រប់កន្លែងនៅក្នុងខេត្ត និងគ្រប់ស្រុកដើម្បីជ្រាប។ បានចុះពិនិត្យស្លាកសញ្ញាផ្ទាំងផ្សាយពាណិជ្ជកម្មនៅក្នុង ក្រុងខេមរភូមិន្ទបានចំនួន១២លើក និង នៅស្រុកបុទុមសាគរ និងស្រុកស្រែអំបិលបាន០២លើក។ ចុះត្រួតពិនិត្យសិប្បកម្មគ្រប់ប្រភេទក្នុងក្រុងខេមរភូមិន្ទបានចំនួន០៥លើក និង បានអញ្ជើញអាជីវករដែលធ្វើអាជីវកម្មពាក់ព័ន្ធនឹងវិស័យសូនរូបមកប្រជុំបានចំនួន០៣លើក។ សកម្មភាពការងាររបស់មន្ទីរក្នុងឆ្នាំនេះអនុវត្តបាន៨៥ភាគរយ នៃផែនការឆ្នាំ ។

**មន្ទីរខេត្តកំពង់ស្ពឺ** បានបើកមហោស្រពប្រឡងចម្រៀងខ្មែរ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ដែលមានចម្រៀងពីរប្រភេទគឺចម្រៀងខ្មែរសម័យជំនាន់មុន និងចម្រៀងខ្មែរជំនាន់ថ្មី នៅមណ្ឌលកំសាន្តអំពែភ្នំ រយៈពេល០៣ថ្ងៃ និងប្រណាំងគោលឿននៅទីលានខាងលិចផ្សារព្រៃផ្តៅ ឃុំត្រពាំងគង ស្រុកសំរោងទង ជាលទ្ធផលទទួលបានជោគជ័យ។ អនុវត្តតាមសារាចរណែនាំរបស់ក្រសួងស្តីពីការបង្កើតព្រឹត្តិការណ៍អបអរសាទរខួបអនុស្សាវរីយ៍ នៃការបញ្ចូលប្រាសាទព្រះវិហារ ជាសម្បត្តិបេតិកភណ្ឌពិភពលោក មន្ទីរបានរៀបចំជាក្បួនដង្ហែចេញពីមន្ទីរវប្បធម៌ មានរថយន្តដាក់តាំងរូបប្រាសាទព្រះវិហារ សមាជិកហែរក្បួនកាន់ទង់ជាតិឆ្ពោះទៅព័ទ្ធជុំវិញផ្សារកំពង់ស្ពឺ ដែលមានសមាសភាពចូលរួម សិល្បករ សិល្បការិនី គរុសិស្ស និងសិស្សសរុបចំនួន៥០០នាក់។ ការងារវិនិយោគសាធារណៈលើការអភិរក្ស អភិវឌ្ឍរមណីយដ្ឋានភ្នំចាស់ និងបណ្តុះបណ្តាលវិជ្ជាជីវៈសិល្បៈក្រៅប្រព័ន្ធ ដល់សិស្ស-កុមារកំព្រានៅតាមមូលដ្ឋានក្នុងខេត្តសរុបមានចំនួន១៥០នាក់ ក្នុងនោះស្រី៨០នាក់។ ដៃគូវិនិយោគសាធារណៈដែលមានទឹកប្រាក់៩០.០០០ដុល្លា សម្រាប់ធ្វើអភិរក្ស និងអភិវឌ្ឍទួលគុហារមានឫទ្ធិ ស្ថិតនៅក្នុងភូមិសាស្រ្តទំនប់បាក់ ឃុំដំណាក់រាំង ស្រុកឧដុង្គ ឱ្យទៅជារមណីយដ្ឋានវប្បធម៌ធម្មជាតិ។ បានបង្ហាត់ភ្លេងពិណពាទ្យដល់សិស្សចំនួន០៩នាក់នៅមន្ទីរ និងបានចាត់គ្រូរបាំចំនួន០២រូប ទៅបង្ហាត់របាំដល់មណ្ឌលកុមារកំព្រា និងបង្ហាត់ឆៃយ៉ាំ សិល្បៈមហាជនចំនួន១១នាក់ នៅស្រុកភ្នំស្រួច។ បានរៀបចំការប្រឡងចម្រៀងខ្មែរជាសកលលើកទី២ ជ្រើសរើសបេក្ខជនបាន០៤នាក់ ក្នុងនោះស្រី០២នាក់ (ចម្រៀងសម័យ០២នាក់)។ ធ្វើច្បាប់បន្តសុំកាន់កាប់ការធ្វើអាជីវកម្មបញ្ចាំងភាពយន្តវីដេអូបានចំនួន១០៤ច្បាប់ និង ច្បាប់ថ្មីបានចំនួន១៧ច្បាប់។ បានបញ្ជូនច្បាប់លើកស្លាកយីហោចំនួន៦៥ច្បាប់ជូនឯកឧត្តមអភិបាលខេត្តសម្រេច។ បានបើកបង្រៀនមន្រ្តីរាជការចំនួន០៧នាក់ ស្តីពីសិល្បៈសូនរូប មួយសប្តាហ៍បង្រៀន២ថ្ងៃ និង បានដឹកនាំប្រតិភូចំនួន០៣នាក់ ជាគ្រូក្បាច់គុនបុរាណខ្មែរចូលរួមសម្តែងបង្ហាញក្បាច់គុនបុរាណខ្មែរ នៅពហុកីឡាដ្ឋានជាតិអូឡាំពិក រយៈពេល០២ថ្ងៃ ។

**មន្ទីរខេត្តកំពង់ឆ្នាំង** មន្ទីរបានចេញច្បាប់អនុញ្ញាតបន្តឱ្យធ្វើអាជីវកម្មភាពយន្តចំនួន៥៩ច្បាប់-សហការជាមួយមជ្ឈមណ្ឌលបារាំងបញ្ចាំងភាពយន្តចល័តជូនប្រជាជនទស្សនាចំនួន០៣លើក។ ធ្វើការហ្វឹកហាត់សិល្បៈមហាជន សម្តែងល្ខោននាដកម្មចំនួន០២រឿង ដើម្បីចូលរួមមហោស្រពសិល្បៈមហាជនទូទាំងប្រទេសទទួលបានលទ្ធផលជោគជ័យ។ បង្កើតក្រុមល្ខោនបាសាក់ចំនួន០១វង់មាននាម " ពន្លឺពេជ្រភ្នំក្រាំងដីមាស " ស្ថិតនៅស្រុករលាប្អៀរ។ ធ្វើការផ្សព្វផ្សាយជ្រើសរើសក្រុមតន្ត្រីសម័យដើម្បីចូលរួមមហោស្រពតន្ត្រីថ្នាក់ជាតិ នៅក្រសួងព័ត៌មានបានចំនួន០១ក្រុម។ រៀបចំប្រឡងចម្រៀងសម័យ-បុរាណ ជ្រើសរើសបេក្ខជនបាន០៤នាក់ (ស្រី០២នាក់) ក្នុងនោះអ្នកចម្រៀងសម័យ០២នាក់ (ស្រី០១នាក់) ដើម្បីចូលរួមមហោស្រពចម្រៀងខ្មែរសកល នៅមជ្ឈមណ្ឌលកោះពេជ្រ។ ធ្វើការស្រាវជ្រាវអំពីអត្ថប្រយោជន៍នៃដើមត្នោតខ្មែរចំនួន០១អត្ថបទ-ស្រាវជ្រាវអំពីប្រវត្តិអ្នកតា និងពិធីឡើងអ្នកតា "តាត្រាវកញ្ជ្រោង" ០១អត្ថបទ-ស្រាវជ្រាវសាវតាវត្តត្រពាំងស្លោ០១អត្ថបទ-ស្រាវជ្រាវសាវតាវត្តយាយទេព០១អត្ថបទ-ស្រាវជ្រាវសាវតាភូមិក្រាំងលាវ០១អត្ថបទ-ស្រាវជ្រាវសាវតាវត្តកាន់យួរ០១អត្ថបទ និងស្រាវជ្រាវអ្នកចេះក្បាច់គុនចំនួន០២នាក់ និងបានបញ្ជូនស្ត្រី០១នាក់ចេះក្បាច់គុនទៅចូលរួមបញ្ចេញក្បាច់គុននៅភ្នំពេញរយៈពេល២ថ្ងៃ។ ក្រុងកំពង់ឆ្នាំង ការិយាល័យច្រកចេញចូលតែមួយ បានចុះស្រាវជ្រាវស្ដីពីស្លាកសញ្ញាបានចំនួន៣៤៧ស្លាក ស្ថិតនៅសង្កាត់៣។ ចងក្រងឯកសារ"រូបឆ្នាំង" ជានិមិត្តរូបខេត្តកំពង់ឆ្នាំង បាន០១អត្ថបទ។ ពិនិត្យជារួមឃើញថាវិស័យវប្បធម៌ និងវិចិត្រសិល្បៈទូទាំងខេត្តកំពង់ឆ្នាំងមានការកើនឡើងមួយកម្រិតបើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នានាឆ្នាំ២០១០កន្លងទៅ សកម្មភាពលេចធ្លោគឺបានបង្កើតក្រុមសិល្បៈមហាជន ប្រភេទល្ខោនបាសាក់បាន០១ក្រុម-ស្រាវជ្រាវអ្នកចេះក្បាច់គុន០២រូប។ ធ្វើការស្តារ និងជួសជុលឡើងវិញប្រាសាទកំពង់ព្រះ ដែលបណ្តាលមកពីការជីកបង្គោលអង់តែនទូស័ព្ទចល័តរបស់ក្រុមហ៊ុន ខាំឈីនស៊ីណាវ៉ាត្រា។ បានចុះកំណត់ព្រំប្រទល់បណ្តោះអាសន្ន ទីទួលបុរាណចំនួន២ស្រុក គឺស្រុកកំពង់លែង និងស្រុកកំពង់ត្រឡាចបានចំនួន៤៣កន្លែង។

**មន្ទីរខេត្តពោធិសាត់** បានបង្ហាត់រាំ កំណាព្យ និងផ្សព្វផ្សាយអំពីវប្បធម៌ខ្មែរដល់គរុសិស្សចំនួន៤៨លើក-បណ្តុះបណ្តាលសិស្សនៅសាលាបឋមសិក្សាបាកាន ស្រុកបាកានបាន៥របាំ និងបានបង្ហាត់របាំដល់មន្ត្រីអង្គការអេស៊ីលីដាបានចំនួន០៣របាំ។ ចុះស្រាវជ្រាវប្រវត្តិជាក់ស្តែងនៃពិធីសែនចាក់ស្មាន់ ប្រពៃណីវត្តសុវណ្ណស្លាកែត។ រៀបចំប្រឡងចម្រៀងសម័យ-បុរាណជ្រើសរើសបេក្ខជន០៤នាក់ (ស្រី០២នាក់) ចូលរួមមហោស្រពចម្រៀងខ្មែរសកលលើកទី២ នៅមជ្ឈមណ្ឌលកោះពេជ្រ។ បានសិក្សាស្រាវជ្រាវពីទំនៀមទម្លាប់របស់ប្រជាជនក្នុងការសែន និងការឡើងអ្នកតា នៅស្រុកភ្នំក្រវាញ។ បន្តផ្សព្វផ្សាយខ្នាតក្បាច់ចម្លាក់ខ្មែរ ដល់បណ្តាវត្តអារាមនានាទូទាំងខេត្ត ។

**មន្ទីរខេត្តបាត់ដំបង** បានហាត់ក្បាច់បាតល្ខោន និងរបាំត្រៀមសម្រាប់សម្តែងកម្មវិធីសំខាន់ៗ-រំលឹកបទភ្លេងមហោរី និងពិណពាទ្យឡើងវិញ។ បង្រៀនបទភ្លេងពិណពាទ្យដល់តន្ត្រីករថ្មី និង បានដឹកនាំក្រុមសិល្បៈល្ខោនខោល ចូលរួមមហោស្រពនៅរាជធានីភ្នំពេញ។ បានត្រួតពិនិត្យថាស និងកាសែ្សត ភ្លេងកំដរសព ភ្លេងពិណពាទ្យដែលបានប្រមូលតាមស្រុកនានាក្នុងខេត្តយកមកពិនិត្យនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ដើម្បីស្រាវជ្រាវរកឱ្យឃើញបទភ្លេងដែលជាលក្ខណៈថៃ បានណែនាំឈប់ឱ្យចាក់បទភ្លេងរបស់ថៃទាំងនោះ។ បានបញ្ជូនមន្ត្រីជំនាញសិល្បៈពីររូបទៅបង្ហាត់ភ្លេង និងរបាំនៅសកលវិទ្យាល័យ UBB

ក្នុងខេត្តមាននិស្សិតចូលរួមចំនួន៦០នាក់។ នៅអង្គការCCT "ទំនុកចិត្តកុមារកម្ពុជា" មានកុមារចំនួន២០នាក់-បង្ហាត់នៅមណ្ឌលប៉ូវីកុមារកំព្រារបាត់ដំបង២ មានក្មេង៧ចំនួន៤៥នាក់ និងបានបង្ហាត់ភ្លេងពិណពាទ្យ និងភ្លេងប្រពៃណីនៅសកលវិទ្យាល័យបាត់ដំបងដែលមាននិស្សិតចូលរួមហាត់ចំនួន៣០នាក់។ សិល្បករ០៣រូបបានចុះបង្ហាត់របាំត្រុដិ នៅសាលាបឋមសិក្សាភ្នំតូច ស្រុកភ្នំព្រឹក ដែលមានសិស្សចំនួន១៨នាក់។ បានអនុញ្ញាតច្បាប់តន្ត្រីសម័យបានចំនួន១៩ច្បាប់ និងតន្ត្រីបូរាណចំនួន០៣ច្បាប់។ បានអនុញ្ញាតច្បាប់សិប្បកម្មចម្លាក់ឈើចំនួន១០ច្បាប់-ចម្លាក់ស៊ីម៉ងត៍០៧ច្បាប់-លក់គ្រឿងចម្លាក់ និងវត្ថុអនុស្សាវរីយ៍១០ច្បាប់ និងសិប្បកម្មចម្លាក់គ្រប់ប្រភេទចំនួន០៣ច្បាប់។ បានចុះណែនាំដល់អ្នកផលិតព្រះភូមិ និងរូបសូនពីស៊ីម៉ងត៍មួយកន្លែង ឃុំគារ ស្រុកមោងឫស្សី ដើម្បីឱ្យធ្វើក្បាច់ផ្សេងៗជាទម្រង់ក្បាច់ខ្មែរ។ មន្ទីរបានធ្វើលិខិតជូនទៅលោក ទិត វ៉ាន់ថុន តំណាងម្ចាស់ផ្សារទំនើបប៉ូវីថ្មី ដើម្បីសំណើសុំជួយកែលម្អព្រះភូមិ ដែលមានលក្ខណៈថៃឱ្យមានលក្ខណៈជាព្រះភូមិរបស់ខ្មែរ ដោយបានភ្ជាប់ជាមួយនឹងលិខិតនេះនូវរបាយការណ៍ពិនិត្យ និងវាយតម្លៃរបស់គណៈកម្មការបច្ចេកទេស នៃនាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម និងគំរូក្បាច់ខ្មែរជាច្រើនសន្លឹក។ បានអនុញ្ញាតច្បាប់បញ្ចាំងភាពយន្តចល័តចំនួន៤ច្បាប់-មីក្រូវីដេអូចុងបាស់១១៩ច្បាប់ វីដេអូកំដរភ្ញៀវ១០ច្បាប់ ជួលលក់ថាស៤៧ច្បាប់ និងច្បាប់វីដេអូចល័តខ្នាតធំចំនួន០២ច្បាប់។ បានអនុញ្ញាតច្បាប់ម្ហូបការចំនួន៩៧ច្បាប់-សម្អាងការ២១ច្បាប់-ថតរូប១០ច្បាប់-ផ្លាកយីហោ១០ច្បាប់-បណ្ណាគារ៣ច្បាប់-បោះពុម្ព៤២ច្បាប់ និងច្បាប់អ៊ុតសក់ចំនួន០៣ច្បាប់។ នៅតាមវត្តអារាមមួយចំនួននៅក្នុងស្រុកបានចូលរួមលេងល្បែងប្រជាប្រិយ ហើយនៅតាមវត្តខ្លះទៀតក៏មានរៀបចំប្រឡងចម្រៀងបន្ថែមពីលើការលេងល្បែងនេះទៀតផង ដើម្បីអបអរសាទរក្នុងថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ។ បណ្ណាល័យខេត្តមានសាធារណៈជនអានសរុបមានចំនួន១.១៥៨នាក់។ ការិយាល័យច្រកចេញចូលតែមួយ (ក្រុងបាត់ដំបង): ទទួលពាក្យស្នើសុំចំនួន១៣០សេវា ចេញលិខិតអនុញ្ញាតបាន១៣០សេវា (រយៈពេលខ្លីចំនួន២២សេវា-មួយឆ្នាំចំនួន៣០សេវា និង រយៈពេលពីរឆ្នាំចំនួន៧៨សេវា)។ មួយឆ្នាំនេះ មន្ទីរខេត្តបាត់ដំបង តែងបានយកចិត្តទុកដាក់ដឹកនាំអនុវត្តការងារវប្បធម៌ ដើម្បីរួមចំណែកធ្វើឱ្យវិស័យវប្បធម៌ក្នុងខេត្តកាន់តែបានទទួលលទ្ធផលល្អ និងរីកចម្រើន ទោះបីមន្ទីរជួបការលំបាកខ្វះខាតជាថវិកា ខ្វះបទពិសោធន៍នៅតាមស្រុកជាច្រើនក្តី អនុវត្តការងារកន្លងមកយើងបានទទួលលទ្ធផលផ្លែផ្កាជាច្រើន ហើយដែលលេចធ្លោជាងគេនោះគឺៈ ការអនុវត្តបានសម្រេចជាមួយនឹងអ្នកជំនាញនៃនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ការបោះបង្គោលសីមាការពារដែនប្រាសាទ។ សហការបានល្អរបស់បណ្តាមន្ទីរពាក់ព័ន្ធនានា និងការយល់ដឹងកាន់តែមានកំរិតខ្ពស់របស់ប្រជាពលរដ្ឋ។ ការលំបាកគឺ ធនធានមនុស្សដែលមានសព្វថ្ងៃ តាមការិយាល័យជុំវិញមន្ទីរមួយចំនួនគ្មានជំនាញ-ខ្វះធនធានមនុស្សសម្រាប់បម្រើការិយាល័យតាមស្រុកមួយចំនួន។

**មន្ទីរខេត្តប៉ៃលិន** ក្រុមសិល្បៈបានចូលរួមមហោស្រពសិល្បៈមហាជនទូទាំងប្រទេស នៅរាជធានីភ្នំពេញ។ បានចុះចែកកាសែ្សតភ្លេងពិណពាទ្យចំនួន០១លើក បានចំនួន១០វត្ត។ បានចុះត្រួតពិនិត្យមើលថាស និងណែនាំឱ្យអាជីវករជួល-លក់ថាសនៅក្នុងខេត្តបានចំនួន០៥លើក និង បានចុះធ្វើអាជ្ញាប័ណ្ណនៅក្នុងខេត្តបានចំនួន១៥កន្លែង។ បានចេញច្បាប់ឱ្យអាជីវករសិល្បៈសូនរូបបានចំនួន០១កន្លែង។ អនុញ្ញាតប្រកបអាជីវកម្មបន្តសម្រាប់ឆ្នាំ២០១១ នៅក្នុងខេត្តសរុបបានចំនួន០៩កន្លែង ក្នុងនោះមានផ្នែកសម្អាងការមានចំនួន០៥កន្លែង និងបណ្ណាគារមានចំនួន០៤កន្លែង។ បានចុះស្រាវជ្រាវ ស្តីពីប្រវត្តិលោកយាយយ៉ាត

នៅក្រុងប៉ៃលិនចំនួន០១លើក និងបេក្ខភាពមរតកមនុស្សរស់ចំនួន០១លើក នៅវត្តប៉ាហ៊ី សង្កាត់ប៉ៃលិន។ ឃើញថាការងាររយៈពេលមួយឆ្នាំនេះ បានសម្រេចលទ្ធផលល្អជាងឆ្នាំកន្លងមក។ នៅមានការខ្វះខាតជាច្រើនដូចជា: ខ្វះខាតធនធានមន្ត្រីជំនាញ និងខ្វះខាតសម្ភារៈមួយចំនួនដែលជាតម្រូវការចាំបាច់សម្រាប់មន្ត្រីជំនាញចុះបំពេញការងារ ។

**មន្ទីរខេត្តបន្ទាយមានជ័យ** បានចុះផ្សព្វផ្សាយសេចក្តីជូនដំណឹង របស់អភិបាលខេត្តស្តីពីការធ្វើច្បាប់អាជីវកម្មវិស័យភាពយន្ត-វីដេអូសម្រាប់ឆ្នាំ២០១១ និង បានចុះផ្សព្វផ្សាយទប់ស្កាត់ការដាក់តាំងជួល-លក់ថាស គ្រោះថ្នាក់នៅស្ពានកោះពេជ្របានចំនួន០១លើក។ បានរៀបចំប្រឡងចម្រៀងខ្មែរសកលលើកទី២ ជ្រើសរើសបេក្ខជនបាន០៤នាក់ (ស្រី០២នាក់) ក្នុងនោះចម្រៀងសម័យ០២នាក់(ស្រី០១នាក់)។ បានធ្វើច្បាប់អាជីវកម្មបន្តវិស័យអភិវឌ្ឍវប្បធម៌បានចំនួន៨៥ច្បាប់។ ធ្វើច្បាប់អាជីវកម្មបន្តវិស័យសិល្បៈសូនរូប និងសិប្បកម្មបានចំនួន២៦ច្បាប់។ បានធ្វើច្បាប់អនុញ្ញាតឱ្យអាជីវករដឹកវត្ថុសិល្បៈចម្លងធ្វើពីអំពីថ្ម និងឈើបានចំនួន៣៦លើក ក្នុងនោះមានចម្លាក់ថ្មចំនួន២៥រូប និងឈើចំនួន១១រូប។ បានចេញច្បាប់ឱ្យអតិថិជនដឹករូបសិល្បៈសូនរូបឈើ-ថ្ម ទៅរាជធានីភ្នំពេញបានចំនួន៦៥ច្បាប់។ ច្រកចេញចូលតែមួយក្រុងប៉ោយប៉ែត បានបំពេញសេវាកម្មវិស័យវប្បធម៌លើលិខិតបាន៩៣ច្បាប់។

**មន្ទីរខេត្តឧត្តរមានជ័យ** បានទទួលឧបករណ៍ភ្លេងប្រពៃណី០១វង់ពី ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ដឹកនាំសិល្បៈ "របាំទាក់ដឺរ" ចូលរួមប្រឡងសិល្បៈមហាជនទូទាំងប្រទេស នាសាលសន្និសីទចតុមុខ ទទួលបានជ័យលាភីពានរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី ថ្នាក់ពានប្រាក់។ បានសម្តែងសិល្បៈរបាំ ទាក់ដឺរ នៅក្នុងឱកាសប្រារព្ធទិវាវប្បធម៌ជាតិ០៣ មីនា លើកទី១៣ ឆ្នាំ២០១១ នៅបរិវេណសួនច្បារសាលាខេត្តឧត្តរមានជ័យ។ បានចុះពិនិត្យសកម្មភាពធ្វើពុម្ពស៊ីម៉ង់ត៍នៅក្រុងសំរោង ស្រុកចុងកាល់ និងស្រុកបន្ទាយអំពិល-សកម្មភាពផលិតកន្ទេលផ្តៅ នៅសង្កាត់កូនក្រៀល ក្រុងសំរោង និងសកម្មភាពតម្បាញអង្រឹង ក្រចៅ នៅឃុំជើងទៀន ស្រុកចុងកាល់។ បានចុះបង្ហាត់បង្រៀនដល់សិប្បករអំពីខ្នាតព្រះពុទ្ធ។ បានចុះស្រាវជ្រាវអំពីទំនៀមទំលាប់ទៅទាក់ដឺរ របស់ជនជាតិគួយនៅសង្កាត់កូនក្រៀល-ចុះស្រាវជ្រាវក្បាច់គុនបុរាណខ្មែរ នៅស្រុកចុងកាល់-ចុះស្រាវជ្រាវទំនៀមទំលាប់ជនជាតិភាគតិច នៅឃុំអូរស្វាយ-ចុះសិក្សាស្រាវជ្រាវអំពីពិធីបញ្ចូលមេមត់ នៅសង្កាត់កូនក្រៀល ក្រុងសំរោង និងបានចុះសិក្សាអំពីមុខម្ហូបខ្មែរ លើគម្រោងចំណាត់ថ្នាក់មុខម្ហូបខ្មែរក្នុងតំបន់ នៃខេត្តឧត្តរមានជ័យ ។

សកម្មភាពការងាររបស់មន្ទីរខេត្តឧត្តរមានជ័យរយៈពេលមួយឆ្នាំនេះ សម្រេចបានលទ្ធផល៨៥ភាគរយ នៃផែនការសកម្មភាពវប្បធម៌ប្រចាំឆ្នាំ២០១១ ។

**មន្ទីរខេត្តព្រះវិហារ** ចុះត្រួតពិនិត្យ និងណែនាំដល់អាជីវករធ្វើច្បាប់ជួល-លក់ថាសនៅតាមក្រុង-ស្រុកសរុបចំនួន៧៧កន្លែង។ ដឹកនាំសិល្បៈមហាជនសម្តែងរបាំ និងរឿងកំប្លែង ក្នុងឱកាសបុណ្យ ០៧ មករា និងពិធីតាំងពិព័ណ៌លក់ផលិតផលរួមគ្នារវាងខេត្តព្រះវិហារ និងខេត្តស៊ីសាកេត ប្រទេសថៃ នៅពហុកីឡាដ្ឋានខេត្ត រយៈពេល០៣យប់ និង បានចូលរួមសម្តែងសិល្បៈជាមិត្តភាពក្នុងពិធីវប្បធម៌រួមគ្នា និងការប្រណាំងទូកខេត្តព្រះវិហារ ខេត្តចម្ប៉ាសាក់ ប្រទេសឡាវ រយៈពេល៣ថ្ងៃ (២១-២៣-២០១១)។ បានដឹកនាំក្រុមសិល្បៈទៅចូលរួមក្នុងមហោស្រពសិល្បៈទូទាំងប្រទេសនៅរាជធានីភ្នំពេញ។ បានដឹកនាំក្រុមសិល្បៈមហាជន សម្តែងសិល្បៈរបាំ ចម្រៀងបូរាណ-សម័យ និងរឿងកំប្លែង ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី និងពិធីប្រារព្ធទិវា

វប្បធម៌ជាតិ ០៣ មីនា ឆ្នាំ២០១១នៅក្នុងខេត្ត។ ចុះធ្វើច្បាប់អាជីវកម្មលើវិស័យវប្បធម៌បាន១០ក្រុម។ បានថតចម្លងកាសែត ភ្លេងពិណពាទ្យរបស់ខ្មែរ ដែលក្រសួងផ្តល់ឱ្យដើម្បីបែងចែកដល់អាជីវករចាក់ធុងបាសក្នុងស្រុកទាំង០៧ និងក្រុង០១។ បានចុះសិក្សាស្រាវជ្រាវអំពីក្បាច់គុនវាយខែល នៅក្នុងស្រុកឆែប និងចងក្រងជាឯកសារជូនទៅក្រសួងរួចហើយ។ បានចុះស្រង់ស្ថិតិធ្វើស្លាកសញ្ញាយីហោទាំងរដ្ឋ និងឯកជនសរុបចំនួន៩៧៦ផ្ទាំង ក្នុងក្រុង និងស្រុក។ មន្ទីរអាចវាយតម្លៃថា ជាទូទៅការអនុវត្តតាមទិសដៅការងាររបស់ក្រសួង ក៏ដូចជាផែនការសកម្មភាពការងារឆ្នាំ២០១១របស់មន្ទីរ មានការរីកចម្រើនមួយកម្រិតគួរឱ្យកត់សម្គាល់ផងដែរ។ ជារួមការងារថែរក្សាការពារ គ្រប់គ្រងបេតិកភណ្ឌវប្បធម៌ បានសហការជាមួយស្ថាប័នមានសមត្ថកិច្ច អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដើម្បីជួយមានវិធានការទប់ស្កាត់ការបំផ្លិចបំផ្លាញបេតិកភណ្ឌវប្បធម៌ជាតិ ត្រួតពិនិត្យការធ្វើអាជីវកម្មលើវិស័យវប្បធម៌ឱ្យត្រឹមត្រូវតាមច្បាប់រដ្ឋឱ្យកាន់តែមានប្រសិទ្ធិភាពមួយកម្រិតថែមទៀត។ លទ្ធផលសកម្មភាពការងារ រយៈពេលមួយឆ្នាំនេះសម្រេចបាន៨០ភាគរយ នៃផែនការ នេះជាការខិតខំប្រឹងប្រែងអស់ពីស្មារតី ចំពោះមន្ត្រីរាជការគ្រប់ការិយាល័យជំនាញ ទោះបីជាការយល់ដឹងមានកម្រិត និងស្ថិតក្នុងស្ថានភាពខ្វះធនធានមនុស្សក៏ដោយ ។

**មន្ទីរខេត្តសៀមរាប** ចុះបង្ហាត់សិស្សសាលាសិល្បៈបុរាណខ្មែរ និងក្រុមសិល្បៈដែលគាំទ្រដោយអង្គការនានាបាន ៣០០ថ្ងៃ និង បានដឹកនាំក្រុមសិល្បៈសិស្សសាលាសិល្បៈបុរាណខ្មែរចូលរួមក្នុងពិធីមហោស្រពសិល្បៈមហាជន ទូទាំងប្រទេសឆ្នាំ២០១១ នៅរាជធានីភ្នំពេញ ទទួលបានជ័យលាភីពានមាស។ រៀបចំប្រឡងចម្រៀងជ្រើសរើសបេក្ខជនបាន០២នាក់ (ស្រី០១នាក់) ចូលរួមមហោស្រពចម្រៀងខ្មែរសកលលើកទី២ នៅមជ្ឈមណ្ឌលកោះពេជ្រ។ សហការជាមួយសាលាខេត្ត ចុះស្រង់ស្ថិតិស្លាកយីហោ ស្លាកសញ្ញា ផ្ទាំងផ្សាយពាណិជ្ជកម្មក្នុង១២សង្កាត់ មានចំនួន៥៦៤ស្លាក និងបានណែនាំឱ្យអាជីវករចំនួន១១៨កន្លែងមកសុំច្បាប់លើកស្លាកយីហោ។ ចុះត្រួតពិនិត្យដល់អាជីវករទាំងផលិត និងលក់វត្ថុសិល្បៈសិប្បកម្មសូនរូបក្នុងស្រុកទាំង១១ និងក្រុង០១ សរុបបានចំនួន៧២លើក។ ចុះស្រាវជ្រាវក្បាច់គុនបុរាណខ្មែរ នៅសង្កាត់សាលាកំរើក-សង្កាត់ស្លក្រាម និងសង្កាត់ក្របីរៀល ក្រុងសៀមរាបសម្រេចបាន៩០ភាគរយ។ រៀបចំប្រកួតក្បាច់គុនបុរាណខ្មែរ នៅវត្តចក ក្រុងសៀមរាបបានចំនួន ០២យប់។ លើកស្លាកផ្ទាំងផ្សព្វផ្សាយខ្លឹមសារបម្រើវប្បធម៌ជាតិតាមការណែនាំរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សម្រេចបានគ្រប់ស្រុក-ក្រុង។ សហការជាមួយមន្ត្រីសាលាខេត្ត សាលាក្រុងសៀមរាប រៀបចំសេចក្តីជូនដំណឹងអំពីការដាក់តាំងស្លាកយីហោ និងចុះធ្វើការរុះរើផ្ទាំងផ្សាយពាណិជ្ជកម្មដែលលើកកាត់ទទឹងផ្លូវមានរូបមនុស្សនៅពីលើឱ្យដាក់តាំងតាមការកំណត់ចំងាយ ២០ម៉ែត្រពីអ័ក្សផ្លូវ។ ទប់ស្កាត់ការលើកស្លាកយីហោ ផ្ទាំងផ្សព្វផ្សាយពាណិជ្ជកម្ម និងបដាបាន១២ផ្ទាំង ដែលគ្មានការអនុញ្ញាត និងឱ្យកែសម្រួលស្លាកយីហោ បដា ដែលសរសេរជាភាសាបរទេសសុទ្ធបានចំនួន៣៩ផ្ទាំង។ ការិយាល័យច្រកចេញចូលតែមួយក្រុងសៀមរាប បានផ្តល់អាជ្ញាប័ណ្ណលើផ្លាកយីហោសណ្ឋាគារ អាហារដ្ឋាន ភោជនីយដ្ឋាន អ៊ិនធើណេត អង្គការ ម៉ាស្សា អាជីវកម្មលក់គ្រឿងក្រអូប ស្លាកផ្សព្វផ្សាយស្រាបៀរតាមម៉ូតូកង់បីសរុបបានចំនួន១៧៧ច្បាប់។ ចំណុចលំបាកគឺនៅតែមានការលបលួចរំលោភសង់លំនៅដ្ឋាន បូមខ្សាច់ ដាំដំណាំនៅលើផ្លូវ ត្រពាំង និងទួលបុរាណ។ ការធ្វើសកម្មភាពធំៗពាក់ព័ន្ធដល់វិស័យមួយចំនួនដូចជា ការប្រគុំតន្ត្រី ថតភាពយន្តវីដេអូ គ្មានការផ្តល់ព័ត៌មាន ឬ សុំអនុញ្ញាតពីមន្ទីរជំនាញ។ មន្ត្រីនៅស្រុកមួយចំនួនត្រូវចូលនិវត្តន៍ និងចូលក្នុងក្រុមប្រឹក្សាស្រុក ដែលធ្វើឱ្យខ្វះមន្ត្រីជំនាញសម្រាប់អនុវត្តការងារនៅទីនោះ។ រាល់ទិសដៅដែល

ក្រសួងដាក់ចុះមន្ទីរបានខិតខំអនុវត្តបានសម្រេចជាបន្តបន្ទាប់ ប៉ុន្តែក៏មិនទាន់បានសម្រេចល្អប្រសើរ១០០ភាគរយដែរ ដូចជាការងារភាពយន្ត និងវីដេអូ មូលហេតុកំពុងរង់ចាំការតែងតាំងភារកិច្ចថ្មីរបស់គណៈកម្មាការចម្រុះបង្ក្រាបបទល្មើសភាពយន្ត និងវីដេអូរបស់ខេត្តឡើងវិញ។ ការងារផ្ទាំងយីហោ និងផ្ទាំងផ្សាយពាណិជ្ជកម្ម ក៏ស្ថិតនៅក្នុងភាពលំបាកស្មុកស្មាញខ្លាំងណាស់ដែរ ដោយកន្លងមកខេត្តជាអ្នកអនុវត្តផ្ទាល់ជាមួយអ្នកម៉ៅការឯកជនម្លោះហើយភាពខុសឆ្គងកើនឡើងយ៉ាងច្រើន។ ការងារបេតិកភណ្ឌក៏នៅមានលួចចាក់ដីយកធ្វើជាកម្មសិទ្ធិច្រើន ប៉ុន្តែយើងក្តាប់បានតែ៣០ភាគរយប៉ុណ្ណោះ មូលហេតុយើងខ្វះមន្ត្រី និងមួយចំណែកក៏មានការត្រូវរ៉ូវពីអាជ្ញាធរនៅទីនោះផងដែរ។

**មន្ទីរខេត្តកំពង់ធំ** បានចេញលិខិតអនុញ្ញាតជួល-លក់កាស្សែតវីដេអូជូនអាជីវករតាមបណ្តាស្រុកបានចំនួន៨០ច្បាប់។ បានរៀបចំសម្តែងសិល្បៈ និងប្រឡងចម្រៀងសម័យ-បុរាណ ថ្ងៃ៧ មករា ឆ្នាំ២០១១ រយៈពេល០៣យប់ និង បានដឹកនាំក្រុមសិល្បៈមហាជន ទៅចូលរួមប្រឡងសិល្បៈមហាជនទូទាំងប្រទេសដែលមានចំនួន០៣ទម្រង់គឺ ល្ខោនខោល របាំ និងកំប្លែង។ បានតម្លើង និងហាត់ល្ខោនបាសាក់ចំនួន០២រឿង (ព្រះច័ន្ទគោរព និង ទឹកភាំ ផ្កាភាំ) និង ក្រុមតន្ត្រីសម័យបានហាត់បទចម្រៀងថ្មីចំនួន៤បទ។ បានបង្ហាត់សិស្សថ្នាលរៀងរាល់ថ្ងៃសៅរ៍ និងអាទិត្យ ក្នុងនោះមានរបាំ ល្ខោនបាសាក់រឿង "អច្ឆរិយមហាសេនា "។ បានផ្សព្វផ្សាយឱ្យអាជីវករគ្រប់អាជីវកម្មធ្វើច្បាប់លើសេវាអភិវឌ្ឍវប្បធម៌ និង បានចេញលិខិតអនុញ្ញាតជូនអាជីវករសម្ពាងការតាមបណ្តាស្រុកចំនួន៥៤ច្បាប់។ បានទៅចូលរួមមហោស្រពបង្ហោះខ្លែងខ្មែរទូទាំងប្រទេស នៅរាជធានីភ្នំពេញ។ បានធ្វើច្បាប់ជូនអាជីវករសិប្បកម្មបានចំនួន២២ច្បាប់។ បានបើកវគ្គបំប៉ន ស្តីពីចម្លាក់ និងគំនូររយៈពេល០៨ថ្ងៃដែល មានទីតាំងនៅសាលាបឋមសិក្សាកកោះ ឃុំសំណាក ស្រុកសន្ទុក ដែលមានគ្រូឧទ្ទេសនាមចំនួន០៣រូបដែលមកពីនាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម។ ការិយាល័យច្រកចេញចូលតែមួយ បានចេញប័ណ្ណអនុញ្ញាតជួល-លក់ថាសបានចំនួន០១ទីតាំង-សម្ពាងការ១០ទីតាំង លើកស្លាកយីហោ៩៩ទីតាំង-ប្រគុំតន្ត្រី០៧លើក-សិល្បៈចម្រៀងវីស៊ីឌី០១លើក-សូនរូប០៣ទីតាំង-បញ្ចាំងភាពយន្តវីដេអូកំដរភ្ញៀវតាមហាងកាហ្វេ០៣ទីតាំង-គ្រឿងបំពងសម្លេង០១ទីតាំង-លេងល្បែងប្រជាប្រិយ០៣លើក-ចាក់ធុងបាសផ្សព្វផ្សាយផលិតផលក្រុមហ៊ុន០៣លើក-ថតរូប០២ទីតាំង និង ជាងគំនូរបានចំនួន០២ទីតាំង ។ ឆ្នាំនេះការងារវប្បធម៌មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ ប៉ុន្តែនៅមានចំណុចខ្សោយមួយចំនួនដូចជាមន្ត្រីរាជការមួយចំនួនពុំបានឆ្លងកាត់វគ្គបច្ចេកទេស-ខ្វះមធ្យោបាយដឹកជញ្ជូនផ្ទចម្លាក់នៅតាមទីតាំងនានាយកមករក្សាទុកនៅសារមន្ទីរ។ ទោះបីមានការលំបាកខ្លះៗក្នុងការអនុវត្តការងារ ក៏ថ្នាក់ដឹកនាំ មន្ត្រីគ្រប់ការិយាល័យស្រុក-ក្រុង ខិតខំពុះពារជំនះរាល់ការលំបាករហូតបានបំពេញការងារប្រកបដោយជោគជ័យ បើគិតជាភាគរយបាន៨៥ភាគរយ នៃផែនការឆ្នាំ២០១១។

**មន្ទីរខេត្តកំពង់ចាម** គ្រូផ្នែករបាំបានចុះជួយបង្ហាត់សិល្បៈដល់សិស្សនៅសាលាបឋមសិក្សាថ្មគោលបាន០៣របាំ។ ក្រុមសិល្បៈមហាជន០២ក្រុម បានចូលរួមមហោស្រពសិល្បៈមហាជនទូទាំងប្រទេសនៅរាជធានីភ្នំពេញ។ បាននិពន្ធបទភ្លេង និងទំនុកច្រៀងថ្មីបាន៤បទ និងហាត់រយៈពេល១៨ថ្ងៃ ដើម្បីចូលរួមមហោស្រពតន្ត្រីសម័យទូទាំងប្រទេសនាខែខាងមុខនេះ។ បានចុះធ្វើការផ្សព្វផ្សាយតាមសេចក្តីណែនាំរបស់សាលាខេត្ត ស្តីពីការដាក់តាំងស្លាកយីហោដល់អាជីវករ និងឱ្យអាជីវករមកសុំការអនុញ្ញាតច្បាប់នៅសាលាខេត្ត ក្នុងនោះបានផ្តល់ច្បាប់ដល់អាជីវករតាមស្រុក និងក្រុងសរុបចំនួន៩៣៧ច្បាប់។ រយៈពេលមួយឆ្នាំនេះ

មន្ត្រីរាជការរបស់មន្ទីរខេត្តបានប្រឹងប្រែងយកអស់កំលាំងកាយចិត្តអនុវត្តតាមផែនការដាក់ចុះ។ ខិតខំតែងនិពន្ធបទភ្លេង របាំជាពិសេសបានជ្រើសរើសក្រុមសិល្បៈមហាជនទៅប្រឡងដោយទទួលលទ្ធផលជាទីមោទនៈ។ ឯការងារបេតិកភណ្ឌក៏មានភាពមមាញឹកច្រើនណាស់ដែរក្នុងការអភិរក្សប្រាសាទ ទប់ស្កាត់ការជីកកកាយពីជនទុច្ចរិតបោះបង្គោលព្រំប្រទល់ប្រាសាទជាដើម។ ទាំងនេះក៏ដោយសារការជួយជ្រោមជ្រែង ឧបត្ថម្ភទាំងថវិកា សម្ភារៈ ស្មារតីពីក្រសួង និងអភិបាលខេត្តជារៀងរហូតមក។

**មន្ទីរខេត្តក្រចេះ** បានចូលរួមក្នុងមហោស្រពសិល្បៈមហាជន នៅរាជធានីភ្នំពេញ ដោយបាននាំយករបាំឈ្មោះថា "របាំដុតក្រឡាន" ដែលជាទស្សនីយភាពតម្លើងថ្មី និងទទួលបានជ័យលាភីមេដាយប្រាក់។ បានចូលរួមប្រគុំតន្ត្រីសម័យ និងសម្តែងសិល្បៈជូនប្រជាពលរដ្ឋទស្សនាជាសាធារណៈមានៈ ទិវាជ័យជំនះ ០៧ មករា ទិវាវប្បធម៌ជាតិ ០៣ មីនា បុណ្យចូលឆ្នាំប្រពៃណីជាតិ និងព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ បានចុះពិនិត្យផ្ទះអាជីវកម្មកាហ្វេ វីដេអូកំដរភ្ញៀវក្នុងខេត្តបានចំនួន១៩លើក ស្មើនឹង៥០កន្លែង និងចុះពិនិត្យផ្ទះលក់ស៊ីឌីក្នុងក្រុងក្រចេះ និងតាមបណ្តាស្រុក ដើម្បីណែនាំពីការធ្វើអាជីវកម្មឱ្យបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួង។ បានពិនិត្យទិដ្ឋាការនាំចូលកាស្សែតវីដេអូបានចំនួន៥រឿង ស្មើនឹង៩០ភាគ របស់ផលិតកម្ម ជុង គ័រ ចេញដោយក្រុមហ៊ុនសាន់ដេវីដេអូ។ បានចុះណែនាំម្ចាស់អាជីវកម្មផលិតគ្រឿងសង្ហារឹម និងសិប្បកម្មឱ្យធានា និងរក្សាឱ្យបាននូវក្បាច់ចម្លាក់ខ្មែរ។ បានចេញលិខិតអនុញ្ញាតផ្តល់សេវាកម្មវិស័យវប្បធម៌ និងវិចិត្រសិល្បៈបានចំនួន៣២សេវា និង អនុញ្ញាតប្រកបអាជីវកម្មសេវាកម្មវិស័យវប្បធម៌ក្នុងក្រុងក្រចេះបានចំនួន០៧ប្រភេទអាជីវកម្ម។ មន្ទីរខេត្តក្រចេះបានយកចិត្តទុកដាក់ និងអនុវត្តយ៉ាងសកម្មនូវតួនាទី និងភារកិច្ចរបស់ខ្លួនទទួលលទ្ធផលល្អប្រសើរ ទាំងការងារជំនាញ និងការងារសហប្រតិបត្តិការជាមួយបណ្តាមន្ទីរអង្គភាព អាជ្ញាធរខេត្ត ក្រុង ស្រុក និងមូលដ្ឋាន បានធ្វើឱ្យមន្ទីរវប្បធម៌ខេត្តមានការអភិវឌ្ឍ និងរីកចម្រើនជាវិជ្ជមានទាំងការងារកសាងហេដ្ឋារចនាសម្ព័ន្ធ និងការងារអប់រំផ្សព្វផ្សាយ។

**មន្ទីរខេត្តស្ទឹងត្រែង** បានដឹកនាំក្រុមសិល្បៈទៅចូលរួមមហោស្រពសិល្បៈមហាជនទូទាំងប្រទេស នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ។ បានបង្ហាត់របាំជូនពរដល់សិស្សវិទ្យាល័យ ហ៊ុន សែន ស្ទឹងត្រែងចំនួន០១របាំ និងបានបង្ហាត់របាំដល់សិស្សសាលាបឋមសិក្សាអនុវត្តចំនួន០១របាំ (របាំជូនពរ)។ បានចុះស្រាវជ្រាវក្រុមសិល្បៈជនជាតិភាគតិច នៅស្រុកសៀមប៉ាង ក្នុងនោះមានក្រុមសិល្បៈគង ជនជាតិកាវ៉ែត មាន១០០នាក់ ស្រី៣០នាក់ និងក្រុមសិល្បៈកែន ជនជាតិឡាវ មាន០៥នាក់ ស្រី០១នាក់។ បានចុះណែនាំអាជីវករដែលប្រកបអាជីវកម្ម សេវាកម្មភាពយន្តវីដេអូ និងថាស ដែលមានទិដ្ឋាការមកចុះបញ្ជីនៅការិយាល័យជំនាញ នៅក្រុងស្ទឹងត្រែងបានចំនួន១៥កន្លែង និង បានចុះណែនាំអាជីវករចាក់បញ្ចាំងខារ៉ាអូខេបានចំនួន០៣កន្លែង នៅក្រុងស្ទឹងត្រែង ឱ្យយកថាសដែលមានទិដ្ឋាការមកចុះបញ្ជីនៅការិយាល័យជំនាញ។ បានរៀបចំសេចក្តីជូនដំណឹងស្តីពីនិតិវិធីនៃការគ្រប់គ្រងពាណិជ្ជកម្ម សេវាកម្មវប្បធម៌គ្រប់ប្រភេទប្រចាំឆ្នាំ២០១១ សុំការអនុញ្ញាតពីឯកឧត្តមអភិបាលខេត្តដើម្បីផ្សព្វផ្សាយដល់អាជីវករ។ បានចុះទៅសិក្សាស្រាវជ្រាវអំពីរបៀបធ្វើកន្ទេលទង នៅឃុំសំអាង។ ទិន្នន័យការងារដែលបានមកនេះគឺ ការខិតខំប្រឹងប្រែង ព្រមទាំងសហការល្អរបស់មន្ត្រីរាជការក្នុងមន្ទីរ ទើបសម្រេចបានលទ្ធផលល្អជាបន្តបន្ទាប់ ប៉ុន្តែនៅមានការលំបាកដូចជាខ្វះមធ្យោបាយសម្ភារៈសម្រាប់បម្រើការងារចុះតាមមូលដ្ឋាន និងខ្វះធនធានមនុស្ស ។

**មន្ទីរខេត្តរតនគិរី** ចូលរួមសម្តែងមហោស្រពសិល្បៈមហាជនទូទាំងប្រទេស នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ និងបានរៀបចំក្រុមសិល្បៈមហាជនសម្តែងក្នុងពិធីសែនក្រុងពាលី តាមប្រពៃណីរបស់បងប្អូនជនជាតិដើមភាគតិចនៅបរិវេណមន្ទីរវប្បធម៌ ដែលមានការចូលរួមពីក្រុមសិល្បៈចំនួន០៥ក្រុម រយៈពេល០៣យប់។ បានបង្ហាត់របាំជូនពរ និងរបាំគោះត្រឡោកដល់សិស្សសាលាវិទ្យាល័យសម្តេចឪ សម្តេចម៉ែ រៀងរាល់សប្តាហ៍។ បានរៀបចំលេងល្បែងប្រជាប្រិយក្នុងពិធីបុណ្យចូលឆ្នាំថ្មី រយៈពេល០៣ថ្ងៃ។ បានកាត់ត និងធ្វើថាសរបាំរបស់បងប្អូនជនជាតិ សម្រាប់ទុកធ្វើជាឯកសារ១៣របាំ និង រៀបចំថាសអំពីពិធីកាប់ក្របី និងរបាំជនជាតិចម្រុះទុកជាឯកសារ២៣របាំ។ បានបិទរូបថតដាក់តាំងបង្ហាញអំពីសកម្មភាពវិស័យវប្បធម៌ខេត្ត សម្រាប់ភ្ញៀវទស្សនា។ សហការជាមួយលោកប្រធានការិយាល័យវប្បធម៌ស្រុកលំផាត់ សិក្សាបន្តអំពីពិធីសែនចំការ របស់ជនជាតិទំពួន។ រៀបចំប្រឡងចម្រៀងសម័យ-បុរាណ ជ្រើសរើសបេក្ខជនបាន០៤នាក់ (ស្រី០២នាក់) ចម្រៀងសម័យ០២នាក់ (ស្រី០១នាក់)។ សកម្មភាពតាមការិយាល័យនីមួយៗឃើញថា មានទំនាក់ទំនងល្អជាមួយមន្ទីរពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក៏ដូចជាប្រជាពលរដ្ឋក្នុងខេត្តមានលក្ខណៈល្អប្រសើរ បើទោះបីជាខ្វះខាតខាងថវិកា សម្ភារៈ និងមធ្យោបាយធ្វើដំណើរក៏ដោយ ក៏មន្ត្រីជំនាញគ្រប់ការិយាល័យមានការសាមគ្គី និងសហការគ្នាដើម្បីបំពេញភារកិច្ចក្នុងវិស័យវប្បធម៌ដែលរក្សាបាននូវសិល្បៈទំនៀមទម្លាប់ប្រពៃណីគ្រប់ជនជាតិ និងបេតិកភណ្ឌក្នុងខេត្ត ក្នុងគោលបំណងអភិរក្ស និងអភិវឌ្ឍវប្បធម៌។ តាមការពិនិត្យលើការអនុវត្តសកម្មភាពរយៈពេលមួយឆ្នាំនេះ សម្រេចបានប្រមាណ៩៥ភាគរយ និងបន្តអនុវត្តនៅឆ្នាំ២០១២បន្ថែមទៀត។

**មន្ទីរខេត្តមណ្ឌលគិរី** បានបណ្តុះបណ្តាលមន្ត្រីជាប់កិច្ចសន្យាចំនួន០៥នាក់ ហាត់រៀនសម្តែងសិល្បៈគឺ ឈុតគំប្លែងខ្លី ឈុតល្ខោននិយាយ និងឈុតល្ខោនបាសាក់។ បានបង្ហាត់របាំ ដល់ក្រុមរបាំភូមិពូតាំង០១របាំគឺ របាំតម្បាញជនជាតិឥសាន្ត មានសិល្បករសរុប១៦នាក់ ស្រី០៨នាក់ ដើម្បីយកទៅប្រឡងមហោស្រពសិល្បៈមហាជនទូទាំងប្រទេស បានបង្ហាត់របាំមណ្ឌលកុមារចំការតែបាន០១ក្រុម មានសិល្បករចំនួន២២នាក់ ក្នុងនោះស្រី០៨នាក់។ បានរួមសហការជាមួយអង្គការសុខភាពគ្មានព្រំដែន បង្ហាត់ និងសម្តែងឈុតរឿងខ្លីៗពាក់ព័ន្ធនឹងការអប់រំសុខភាពម្តាយ និងទារក តាមបណ្តាស្រុកបាន០៤លើក។ ក្រៅពីការងារសម្តែង និងប្រគុំ សិល្បករបានចុះបណ្តុះបណ្តាលសិស្សតាមមណ្ឌល និងសហគមន៍ បាន០៣របាំគឺ របាំជូនពរ របាំគោះ ត្រឡោក និងរបាំកាប់ក្របីសែនស្រូវ។ បានបណ្តុះបណ្តាលផ្នែកភ្លេងពិណពាទ្យ កុមារសិស្សសាលាបឋមហាត់រៀនពេលយប់នៅមន្ទីរបានចំនួន០៨បទ។ បានដឹកនាំលេងល្បែងប្រជាប្រិយ នៅវត្តសែនមនោរម្យ-វត្តព្រះពុទ្ធមណ្ឌលគិរី និងវត្តអូរាំង ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ០៣លើករយៈពេល៣ថ្ងៃ និងបានបើកប្រឡងចម្រៀងបុរាណ-សម័យក្នុងឱកាសនោះផងដែរ។ បានដឹកនាំប្រតិភូក្រសួង ចុះសិក្សាអំពីប្រវត្តិក្បាច់គុនបុរាណ និង បានចុះពិនិត្យលើការរៀបចំអាពាហ៍ពិពាហ៍របស់ជនជាតិព្នង នៅស្រុកអូរាំង០១លើក និងបានចងក្រងអត្ថបទ ស្តីពីប្រវត្តិម្ហូបសពជនជាតិព្នងបាន១៥ទំព័រ។ មួយឆ្នាំនេះមន្ទីរបានអនុវត្តសកម្មភាពការងារទៅផែនការគ្រោងទុករបស់ខ្លួនស្របទៅតាមយុទ្ធសាស្ត្ររបស់ក្រសួង ដោយទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់។ កត្តាដែលនាំឱ្យមានការជោគជ័យនេះគឺ ដោយមន្ទីរបានតាមដានគ្រប់សកម្មភាពដែលបានអនុវត្តរាល់សកម្មភាពអទិភាពត្រូវផ្សារភ្ជាប់ជាមួយអ្នកពាក់ព័ន្ធ ដើម្បីពង្រឹងឱ្យមានការចូលរួមទាំងអស់គ្នា ទាំងភាគីផ្តល់សេវា និងអ្នកទទួលសេវាកម្ម។ លើសពីនេះយើង

មានយន្តការទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរដែនដីដើម្បីធានាថាការអនុវត្តសកម្មភាពរបស់ខ្លួនមានភាពរលូន និងទទួលបានការផ្សព្វផ្សាយយ៉ាងទូលំទូលាយ ។

**មន្ទីរខេត្តព្រៃវែង** ចុះបង្ហាត់របាំសិស្សនៅវិទ្យាល័យបាភ្នំ និងចុះពិនិត្យក្រុមល្ខោនបាសាក់មហាជនដើម្បីត្រៀមចូលរួមមហោស្រពសិល្បៈមហាជនទូទាំងប្រទេសឆ្នាំ២០១១ និង បង្ហាត់របាំនិស្សិតនៅសកលវិទ្យាល័យសម្តេច ជា ស៊ីម កំចាយមារ បានចំនួន០២លើក។ ដឹកនាំក្រុមសិល្បៈមហាជនចំនួន០៥ក្រុម ចូលរួមមហោស្រពសិល្បៈមហាជនទូទាំងប្រទេសឆ្នាំ២០១១ និង ចូលរួមរៀបចំកម្មវិធីប្រឡងចម្រៀងសម័យក្នុងកម្មវិធីបុណ្យឡើងអ្នកតាមេស នៅស្រុកបាភ្នំ ឆ្នាំ២០១១។ រៀបចំប្រឡងចម្រៀងបុរាណ-សម័យ ជ្រើសរើសបានបេក្ខជន០៤នាក់ (ស្រី០២នាក់) ក្នុងនោះចម្រៀងបុរាណ០២នាក់ (ស្រី១នាក់) ចូលរួមមហោស្រពចម្រៀងខ្មែរសកលលើកទី២ នៅមជ្ឈមណ្ឌលកោះពេជ្រ។ ចុះពិនិត្យសិប្បកម្មពុម្ពស៊ីម៉ង់តិ៍ គ្រប់ប្រភេទ-សិប្បកម្មតម្បាញហូលផាមួង និងតម្បាញកន្ទេលនៅបណ្តាស្រុកនានា។ ចុះពិនិត្យស្លាកយីហោ ផ្ទាំងផ្សាយពាណិជ្ជ កម្មគ្រប់ប្រភេទតាមទីប្រជុំជន ដើម្បីជម្រុញការសរសេរស្លាកយីហោតាមការណែនាំរបស់ក្រសួង។ បានចុះស្រាវជ្រាវក្បាច់គុនបុរាណខ្មែរ នៅស្រុកកំពង់ត្របែក។ ចូលរួមបំផុសប្រជាពលរដ្ឋឱ្យលេងល្បែងប្រជាប្រិយខ្មែរ ដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរនៅតាមវត្តអារាម។ សកម្មភាពការងាររបស់មន្ទីរ បើប្រៀបធៀបនិងការអនុវត្តនៃឆ្នាំកន្លងមក ឃើញថាឆ្នាំនេះមានការប្រែប្រួលរីកចម្រើនជាង អាស្រ័យដោយមានកិច្ចសហការល្អជាមួយអាជ្ញាធរគ្រប់ឃុំ ស្រុក ពិសេសឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តព្រៃវែង ។

**មន្ទីរខេត្តស្វាយរៀង** ការងារសិល្បៈទស្សនីយភាពក៏បានខិតខំធ្វើការហ្វឹកហាត់រៀនសូត្រមុខជំនាញរបស់ខ្លួន និងចុះធ្វើសកម្មភាពសម្តែងនៅតាមមូលដ្ឋានទទួលបានលទ្ធផលល្អ។ បាននិពន្ធ និងតម្លើងរឿងល្ខោនបាសាក់ចំនួន០២រឿង (រឿង បន្ទោងមរតក និង រឿង នាងផ្តិលមាស) និង និពន្ធបទចម្រៀងសម័យបាន០៤បទ និងបទប្រពៃណីបាន១០បទ។ បណ្តុះបណ្តាលសិស្សសាលាបំពេញវិជ្ជាជីវៈខេត្តលើមុខជំនាញសម្ភងការបាន០១វគ្គមានសិស្សចំនួន៤៥នាក់។ បានចុះធ្វើការត្រួតពិនិត្យការដាក់តាំងស្លាកយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្មនៅទូទាំងខេត្តបានចំនួន៧លើក មានស្លាកយីហោចំនួន២៦៨ផ្ទាំង។ រៀបចំសហគមន៍នៅស្រុកស្វាយជ្រំ០១ក្រុម (ផលិតសម្ភារៈប្រើប្រាស់អំពីឫស្សី) និងនៅស្រុកកំពង់រោទ៍០២ក្រុម (ផលិតកន្ទេលអញ្ចូត)។ ការងារសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ បានចុះសហការជាមួយការិយាល័យវប្បធម៌ស្រុក និងអាជ្ញាធរដែនដី ធ្វើការត្រួតពិនិត្យការធ្វើអាជីវកម្មវិស័យភាពយន្ត-វីដេអូបានចំនួន២៤លើក។ ផ្តល់ពាក្យសុំបើកថ្មីដល់អាជីវកម្មជួល-លក់ថាស និងអាជីវកម្មលើវិស័យភាពយន្ត-វីដេអូបានចំនួន២៧កន្លែង។

ការងារមន្ទីរមានបញ្ហាប្រឈមគឺខ្វះមន្ត្រីសម្រាប់បំពេញបន្ថែម នៅតាមបណ្តាការិយាល័យជំនាញ និងការិយាល័យវប្បធម៌ស្រុក-ក្រុង។ មន្ត្រីរាជការនៅក្នុងមន្ទីរមានស្មារតីខ្ពស់ក្នុងការបំពេញភារកិច្ច ។

## ៥.ការអភិវឌ្ឍធនធានមនុស្ស :

### ៥.១.សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

✳ ឆ្នាំសិក្សា ២០១០-២០១១ មាននិស្សិតសរុប**១.២២៩នាក់** (ស្រីមាន**៣៤៣នាក់**) ក្នុងនោះមាន :

-និស្សិតអាហារូបករណ៍ចំនួន**៦៣០នាក់** ( ស្រី**១៩៤នាក់**)

-និស្សិតបង់ថ្លៃសិក្សាចំនួន**៩៩៩នាក់** ( ស្រី**១៤៩នាក់**) ។

✳ឆ្នាំសិក្សា ២០១១-២០១២ មាននិស្សិតសរុប**១.៤២៧នាក់** ( ស្រីមាន**៤១២នាក់**) ក្នុងនោះមាន :

- និស្សិតអាហារូបករណ៍ចំនួន**៦៦៨នាក់** ( ស្រី**១៩៩នាក់**)

-និស្សិតបង់ថ្លៃសិក្សាចំនួន**៧៥៩នាក់** ( ស្រី**២១៣នាក់**) ។

✳សាស្ត្រាចារ្យបង្រៀនក្នុងឆ្នាំសិក្សា២០១១-២០១២ មានសាស្ត្រាចារ្យនៅក្នុង និងមកពីក្រៅសកលវិទ្យាល័យសរុបចំនួន**២៥៤នាក់** ក្នុងនោះមាន សាស្ត្រាចារ្យនៅក្នុងសកលវិទ្យាល័យចំនួន**១៣៨នាក់** និងមកពីក្រៅចំនួន**១១៦នាក់**

✳កម្រិតសញ្ញាបត្ររបស់សាស្ត្រាចារ្យមាន: បណ្ឌិតចំនួន០៨នាក់ អនុបណ្ឌិតចំនួន១៣២នាក់ បរិញ្ញាបត្រចំនួន១២៤នាក់ ។

សកលវិទ្យាល័យបានអនុវត្តកម្មវិធីសិក្សាឆមាសទី២ សម្រេចជាស្ថាពរ ប្រកបដោយជោគជ័យ ។ និស្សិតគ្រប់មហាវិទ្យាល័យបានបញ្ចប់កម្មវិធីចុះកម្មសិក្សារបស់ខ្លួន នៅតាមបណ្តាខេត្ត ។ និស្សិតមហាវិទ្យាល័យសូនរូប បានតាំងពិព័ណ៌រូបគំនូរស្នាដៃនិស្សិត ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពង់ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សកលវិទ្យាល័យបានរៀបចំពិធីទទួលគណៈប្រតិភូជាន់ខ្ពស់មាន: ឯកឧត្តមបណ្ឌិត យ៉ូហ្សេ រ៉ាមូសហកា ប្រធានាធិបតី នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត ។ បានទទួល លោក សុវណ្ណី ស៊ីសាក់វ៉ាត អនុប្រធានខុទ្ទកាល័យមជ្ឈឹមបក្ស និងជាប្រធានគ្រប់គ្រងសារមន្ទីរកែ សនភ៊ីវិហាន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។ បានទទួលលោកជំទាវ K. Shanmugam និងសមាជិកប្រតិភូការបរទេសសឹង្ហបុរី ។ បានអញ្ជើញគណៈប្រតិភូមួយក្រុមពីសកលវិទ្យាល័យជាតិអូតូ ណូម៉ា ប្រទេសមិកស៊ិកូ មកធ្វើទស្សនកិច្ច និង រៀបចំវគ្គបណ្តុះបណ្តាល ស្តីពី The Printing Press Workshop ដល់និស្សិតមហាវិទ្យាល័យសិល្បៈសូនរូប ។ លោកព្រឹទ្ធបុរសមហាវិទ្យាល័យតូរ្យតន្ត្រី បានដឹកនាំគណៈប្រតិភូតន្ត្រីករ តន្ត្រីការិនីចំនួន០៦នាក់ ទៅចូលរួមក្នុងកម្មវិធីប្រគុំតន្ត្រីសាំហ្វូនី(15th years The ASEAN-Russia Culture Dialogue Relationship) (០៤-២០.វិច្ឆិកា.២០១១)និងបានជួយសម្រួលរៀបចំការសម្តែងរបស់គណៈប្រតិភូតន្ត្រីករអ្នកចម្រៀង RUFA BAND ចូលរួមក្នុងកម្មវិធីប្រគុំតន្ត្រីរ៉ុក (១១-១៨ វិច្ឆិកា.២០១១) នៅកោះបាលី ប្រទេសឥណ្ឌូណេស៊ី ទទួលលទ្ធផលជោគជ័យ ។ លោកព្រឹទ្ធបុរសមហាវិទ្យាល័យបុរាណវិទ្យាបានសហការជាមួយសារមន្ទីរធម្មជាតិ ប្រទេសបារាំង លោក Fabric Demetter ចុះធ្វើការសិក្សាស្រាវជ្រាវ និងធ្វើកំណាយនៅស្ថានីយ៍បុរាណវិទ្យាភ្នំបោះដំបង ខេត្តកំពត ។ បានរៀបចំពិធីប្រគល់-ទទួល ឧបករណ៍តន្ត្រីតាមរយៈតំណាងស្ថានទូតជប៉ុនប្រចាំកម្ពុជា នៅសកលវិទ្យាល័យ ។ បានរៀបចំប្រឡងបញ្ចប់បរិញ្ញាបត្រនៅគ្រប់មហាវិទ្យាល័យសម្រេចជាស្ថាពរ ដោយនិស្សិតទាំង៥មហាវិទ្យាល័យបានខិតខំធ្វើកិច្ចការរបស់ខ្លួន ជាមួយសាស្ត្រាចារ្យដឹកនាំគម្រោងដោយយកចិត្តទុកដាក់ខ្ពស់ ។ សកលវិទ្យាល័យបានធ្វើសំណើសុំកែលម្អកម្មវិធីសិក្សាជូនគណៈកម្មការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន អនុវត្តឆ្នាំសិក្សា២០១១-២០១២ ។ រយៈពេលមួយឆ្នាំនេះ សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈបានបំពេញភារកិច្ចដោយទទួលលទ្ធផលគួរកត់សម្គាល់នោះគឺ:

-រៀបចំទទួលគណៈប្រតិភូជាន់ខ្ពស់អន្តរជាតិមកទស្សនកិច្ចនៅសកលវិទ្យាល័យ បានប្រកបដោយជោគជ័យ

-មានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិបានយ៉ាងល្អប្រសើរ និងកាន់តែបើកទូលាយ

-ការជួសជុលអាគារ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ធ្វើឱ្យសោភ័ណភាពសកលវិទ្យាល័យត្រូវបានលើកកម្ពស់មួយកម្រិត ។

-និស្សិតបញ្ចប់ឆ្នាំសិក្សានៅមហាវិទ្យាល័យទាំង៥ បានប្រឡងជាប់ជាស្ថាពរថ្នាក់បរិញ្ញាបត្រសិល្បៈ ក្នុងឆ្នាំសិក្សា ២០១០-២០១១ សរុបចំនួន១២៦នាក់ នារី៣៥នាក់ រួមមាន :

- មហាវិទ្យាល័យស្ថាបត្យកម្ម និងនគរោបនីយវិទ្យា ជំនាន់ទី១៧ ចំនួន៤៧នាក់ នារី១៤នាក់
- មហាវិទ្យាល័យបុរាណវិទ្យា ជំនាន់ទី១៩ ចំនួន២៣នាក់ នារី០៦នាក់

- មហាវិទ្យាល័យសិល្បៈនាដសាស្ត្រ ជំនាន់ទី៩ ចំនួន០៨នាក់ នារី០៤នាក់
- មហាវិទ្យាល័យតូរ្យតន្ត្រី ជំនាន់ទី១០ ចំនួន១២នាក់ នារី០៤នាក់
- មហាវិទ្យាល័យសិល្បៈសូនរូប ចំនួន៣៦នាក់ នារី០៧នាក់ ក្នុងនោះមាន :
  - -ផ្នែកតុបតែងលម្អស្ថាបត្យកម្ម ជំនាន់ទី១៣ ចំនួន២១នាក់ នារី០៧នាក់
  - -ផ្នែកវិចិត្រកម្ម ជំនាន់ទី១៩ ចំនួន១០នាក់
  - -ផ្នែកចម្លាក់ ជំនាន់ទី១៩ ចំនួន០៥នាក់ ។

**៩.២.សាលាមធ្យមវិចិត្រសិល្បៈ**

-ឆ្នាំសិក្សា ២០១០-២០១១ សិស្សសិក្សានៅតាមសាលាជំនាញសរុបចំនួនៈ **១.១៥៦នាក់** ក្នុងនោះស្រី**៤៦៤នាក់** សិស្សស្នាក់នៅក្នុងសាលាចំនួន**១៧៩នាក់** ក្នុងនោះនារីចំនួន**៥៨នាក់**

-ឆ្នាំសិក្សា ២០១១-២០១២ សិស្សសិក្សាសរុបចំនួន**១.១៩២នាក់** ក្នុងនោះស្រី**៤៨៦នាក់**

-សរុបលោកគ្រូ អ្នកគ្រូមានចំនួន**២៧១នាក់** ក្នុងនោះអ្នកគ្រូ**១០៩នាក់**។

សាលាមធ្យមបានពង្រឹងតួនាទីមន្ត្រីទទួលបន្ទុកអនុរក្សចំនួន១០នាក់បំពេញការងារ ពិនិត្យតាមដានការសិក្សាជាប្រចាំរៀងរាល់ពេល។ បានរៀបចំកម្មវិធីសិក្សាតាមសាលាជំនាញទាំង៥ និងបានរៀបចំប្រឡងឆមាសលើកទី២ ប្រកបដោយជោគជ័យ។ បានទទួលសិល្បករហ្វីលីពីនចំនួន១៥នាក់ មកសម្តែងសិល្បៈល្ខោននិយាយនៅក្នុងរោងមហោស្រពសាលា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ជូនដល់សិស្សចំនួន០១ថ្ងៃ នៅសាលាមធ្យមវិចិត្រសិល្បៈ។ សាលាតូរ្យតន្ត្រីទទួលអំណោយឧបករណ៍ពីប្រទេសជប៉ុន នៅទីស្តីការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ បានទទួលស្គរយីកេចំនួន០១ និងមីក្រូហ្វូនចំនួន០៨ ពីឯកឧត្តមរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ទទួលបានឧបករណ៍ភ្លេងសម័យមួយវង់ និងសំលៀកបំពាក់សម្រាប់ហាត់សមសិល្បៈចំនួន១៦សម្រាប់។ ថ្នាក់ដឹកនាំសាលាបានទទួលអំណោយសប្បុរសធម៌ពីឯកឧត្តម ហ៊ឹម ឆែម រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងលោកជំទាវ ឯកឧត្តម ចាន់ វណ្ណា ប្រធាននាយកដ្ឋានសម្ភារៈ និងបរិក្ខារ ឧបត្ថម្ភនូវគ្រឿង ឧបភោគមានអង្ករចំនួន៥០០គ.ក រួមផ្សំមីកញ្ចប់, ទឹកស៊ីអ៊ីវ, អំបិល, ស្ករស និងថវិកាមួយចំនួនចែកជូនដល់សិស្ស ដែលមានជីវភាពក្រីក្រមកពីខេត្តឆ្ងាយកំពុងស្នាក់នៅក្នុងសាលា។ រៀបចំដាំកូនឈើតាមមុខអាគារសិក្សាបានចំនួន១៤៥ដើម។ សាលារបាំ និងតូរ្យតន្ត្រីសម្តែងថ្វាយនៅព្រះបរមរាជវាំង ក្នុងឱកាសកម្មវិធីជប់លៀងសោយភោជនីហារប្រធានាធិបតីប្រទេសទីម័រ។ សិស្សជំនាញរបាំល្ខោន, តូរ្យតន្ត្រី សៀកសរុបចំនួន២១០នាក់បានទៅសម្តែងកម្មសិក្សាសិល្បៈចំនួន០២យប់ ០៣ថ្ងៃ នៅទីតាំងឃុំពាមជីកងស្រុកកងមាស ខេត្តកំពង់ចាម ដើម្បីផ្សព្វផ្សាយសិល្បៈវប្បធម៌ ដោយមានប្រជាជនចូលរួមទស្សនាយ៉ាងច្រើនកុះករ។ សិស្សសាលាសិល្បៈសូនរូបចំនួន៤៨នាក់ ចុះកម្មសិក្សានៅខេត្តសៀមរាបចំនួន៣ថ្ងៃ។ សិស្សសាលាសិល្បៈសូនរូបចំនួន៣០នាក់ ចូលរួមតុបតែងតាំងពិព័ណ៌លទ្ធផលសេដ្ឋកិច្ចកសិកម្ម នៅមុខវត្តបុទុមវត្តី រាជធានីភ្នំពេញ។ សិស្សសាលាល្ខោនចំនួន៨៥នាក់ ចូលរួមសម្តែងក្នុងទិវាចងកំហឹង ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១ នៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍បឹងជើងឯក។ សិស្សសាលាល្ខោនផ្នែកល្ខោននិយាយបានរៀបចំសម្តែងរឿង "អង្គុបកណ្តុរ" នៅរោងមហោស្រពសាលា រឿងនេះជាស្នាដៃនិពន្ធ និងដឹកនាំរឿងដោយលោកសាស្ត្រាចារ្យ នាង ខាត់ អញ្ជើញមកពីប្រទេសបារាំង ចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមរដ្ឋមន្ត្រី ក្រសួង

វប្បធម៌ និងវិចិត្រសិល្បៈ ដោយមានការចូលរួមពីភ្ញៀវកិត្តិយស លោកគ្រូ អ្នកគ្រូ សិស្សានុ សិស្សសាលាមធ្យមវិចិត្រសិល្បៈ មានចំនួនជាង២០០នាក់។ បានរៀបចំប្រឡងបញ្ចប់ដោយជោគជ័យ និងបូកសរុបពិន្ទុគ្រប់វិញ្ញាសាមានសញ្ញាបត្រសិល្បៈចំនួន **១០៥នាក់** នារី**៤៧នាក់** និង ស្នាតកបត្រសិល្បៈចំនួន**១៣៩នាក់** នារី **៦៦នាក់**។ បានរៀបចំប្រឡងសិល្បករវ័យចំណាស់នៅតាមនាយកដ្ឋាន មន្ទីរវប្បធម៌ដែលមិនទាន់ទទួលសញ្ញាបត្រ និងសិល្បករមហាជនគឺ បានប្រឡងជាប់សញ្ញាបត្រសិល្បៈ និងស្នាតកបត្រសិល្បៈសរុប ចំនួន**២៩២នាក់** ក្នុងនោះស្រី**៧៤នាក់** ។

*** ស្ថិតិសិស្សសិក្សាតាមសាលាជំនាញទាំង៥ :**

១-សាលារបាំ : ចំនួន៣៧៤នាក់ ក្នុងនោះស្រី២៧៤នាក់

២-សាលាតូរ្យតន្ត្រី : ចំនួន៤១៧នាក់ ក្នុងនោះស្រី៩៥នាក់ ( មានសិល្បៈអាយ៉ៃ ចាប៉ី១០នាក់ ស្រី០២នាក់)

៣-សាលាល្ខោន : ចំនួន១៥៣នាក់ ក្នុងនោះស្រី៧០នាក់

៤-សាលាសៀក : ចំនួន៥៣នាក់ ក្នុងនោះស្រី១១នាក់

៥-សាលាសូនរូប : ចំនួន១៩៥នាក់ ក្នុងនោះស្រី៣៦នាក់

**សរុបចំនួន : ១.១៩២នាក់ ក្នុងនោះស្រី៤៨៦នាក់ ។**

រយៈពេលមួយឆ្នាំនេះ សាលាអនុវត្តបានល្អប្រសើរលើការងារទូទៅ ការងារបណ្តុះបណ្តាលក្នុងឆ្នាំសិក្សា២០១០-២០១១ ទោះបីជួបការលំបាកខ្លះក្តី ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ សាស្ត្រាចារ្យបានយកអស់លទ្ធភាពខិតខំប្រឹងប្រែងបំពេញភារកិច្ច ដើម្បីសាលាឈានឆ្ពោះទៅរកការវិវត្តន៏រីកចម្រើន ។

**៦_ការងារសវនកម្មផ្ទៃក្នុង :**

បានចុះធ្វើសវនកម្មនៅអង្គភាព និងមន្ទីរវប្បធម៌រាជធានី-ខេត្តរួមមាន : នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ-នាយកដ្ឋានសារមន្ទីរ-សាលាមធ្យមវិចិត្រសិល្បៈ-ខេត្តស្ទឹងត្រែង-រតនគីរី-មណ្ឌលគីរី-ឧត្តរមានជ័យ-ព្រះវិហារ-កំពង់ធំ ព្រៃវែង-ក្រចេះ-កំពង់ចាម-បន្ទាយមានជ័យ-បាត់ដំបង-ប៉ៃលិន-ពោធិសាត់-កំពង់ឆ្នាំង-សៀមរាប-តាកែវ-កំពត-ស្វាយរៀង កែប-កំពង់ស្ពឺ-ព្រះសីហនុ-កោះកុង-កណ្តាល និងរាជធានីភ្នំពេញ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានអនុវត្តការងាររយៈពេលមួយឆ្នាំនេះ ទទួលបានលទ្ធផលល្អប្រសើរដោយបានការសហការល្អជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត។ បើប្រៀបធៀបទៅនឹងផែនការប្រចាំឆ្នាំសម្រេចបានលទ្ធផល៨៥ភាគរយ និងបន្តអនុវត្តឱ្យគ្រប់ផែនការនាដើមឆ្នាំ២០១២ ។

**៧_ការងារអធិការកិច្ច :**

បានធ្វើអធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុចំនួន៤អង្គភាពគឺៈ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តរតនគីរី-ខេត្តមណ្ឌលគីរី កោះកុង និងខេត្តព្រះវិហារ។ បានធ្វើអធិការកិច្ចបច្ចេកទេសចំនួន៥អង្គភាពគឺ : មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ចាម ខេត្តស្ទឹងត្រែង-ខេត្តតាកែវ-ខេត្តព្រះសីហនុ និងខេត្តឧត្តរមានជ័យ។ បានធ្វើអធិការកិច្ចការសិក្សាចំនួន៤អង្គភាពគឺៈ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្តាល-ខេត្តក្រចេះ-ខេត្តសៀមរាប និងខេត្តបាត់ដំបង។ បានទទួលបណ្តឹង និងចុះអង្កេតស្រាវ

ជ្រាវនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តពោធិសាត់-ខេត្តកំពង់ចាម និងនៅសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងបានទទួលបណ្តឹងបរិហារអនាមិកចំនួន២ករណី ( តំកល់មិនចាត់ការ ) ។

សកម្មភាពការងាររបស់អធិការដ្ឋានរយៈពេលមួយឆ្នាំនេះ ត្រូវបានថ្នាក់ដឹកនាំក្រសួងយកចិត្តទុកដាក់ ដោយបានប្រគល់ភារកិច្ចដល់អង្គភាពចុះធ្វើអធិការកិច្ច សម្រេចបាន៨០ភាគរយ នៃផែនការឆ្នាំ។

**៨_ការងារយេនឌ័រក្រសួង :**

បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា ស្តីពី សិក្សាស្រាវជ្រាវ និងធ្វើផែនការសកម្មភាពយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រលើវិស័យវប្បធម៌ រវាង UNWOMEN និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅទីស្តីការក្រសួង ដែលមានលោកជំទាវ ម៉ិញ កុសនី រដ្ឋលេខាធិការ ជាតំណាង ។

**៩_សេចក្តីសន្និដ្ឋាន :**

សកម្មភាពការងារអនុវត្តរយៈពេលមួយឆ្នាំកន្លងមកនេះ មានដំណើរការប្រក្រតី និងបានបំពេញភារកិច្ចបំរើព្រឹត្តិការណ៍នយោបាយជាតិ-អន្តរជាតិ ទទួលជោគជ័យតាមផែនការដាក់ចុះ។ ការបំពេញភារកិច្ចគ្រប់ផ្នែកជំនាញ បម្រើឱ្យវិស័យវប្បធម៌ និងវិចិត្រសិល្បៈ យើងអាចវាយតម្លៃលើសកម្មភាពលេចធ្លោមួយចំនួនជាការងារអាទិភាពរបស់ក្រសួងនោះគឺ :

<u>១.ពង្រឹងពង្រីកសមត្ថភាពស្ថាប័ន ភាពជាដៃគូអភិវឌ្ឍ បង្កើនប្រសិទ្ធភាពការងារ និង សេវាៈ</u>

ក្នុងកិច្ចពង្រឹងពង្រីកសមត្ថភាពស្ថាប័ន យើងបានធ្វើការសិក្សាស្រាវជ្រាវបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធការពង្រឹងគ្រប់គ្រងវិស័យវប្បធម៌ ដោយសម្រេចតាក់តែងសេចក្តីព្រាងអនុក្រឹត្យបានចំនួន៤ និងបានរៀបចំសេចក្តីប្រកាសរបស់ក្រសួងចំនួន៦ប្រកាស សម្រាប់បម្រើការងារគ្រប់គ្រងតាមផ្នែកជំនាញ ដើម្បីបង្កើនវិសាលភាពគ្របដណ្តប់នៅតាមមូលដ្ឋានរាជធានីខេត្ត។ ការពង្រឹងសមត្ថភាពមន្ត្រីរាជការ និងគ្រប់គ្រងធនធានមនុស្ស ជាមូលដ្ឋានគ្រឹះ ធ្វើឱ្យស្ថាប័នមានភាពរឹងមាំ យើងបានចុះផ្សព្វផ្សាយច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៅតាមមន្ទីរវប្បធម៌ខេត្ត។ ក្រសួងបានបញ្ចប់ការងារធ្វើបច្ចុប្បន្នភាពស្ថិតិមន្ត្រីរាជការតាមមុខជំនាញសញ្ញាបត្រសរុបចំនួន**១.៣០១នាក់** ក្នុងនោះមានៈ ថ្នាក់បណ្ឌិត**០៧នាក់** បរិញ្ញាបត្រជាន់ខ្ពស់**១៦២នាក់** បរិញ្ញាបត្រ**៣៧៩នាក់** បរិញ្ញាបត្ររង**៣៧នាក់** និងថ្នាក់ស្នាតកបត្រសិល្បៈ**៧១៦នាក់**។ ទន្ទឹមនេះធនធានមនុស្សវប្បធម៌ យើងបានបណ្តុះបណ្តាលនៅសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងសាលាមធ្យមវិចិត្រសិល្បៈ ដើម្បីពង្រឹងពង្រីកសមត្ថភាពស្ថាប័នវប្បធម៌ឱ្យកាន់តែរឹងមាំថែមទៀតទៅថ្ងៃអនាគត។ ឆ្នាំនេះសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និស្សិតប្រឡងបញ្ចប់ថ្នាក់បរិញ្ញាបត្រសរុបចំនួន**១២៦នាក់** និងសាលាមធ្យមវិចិត្រសិល្បៈមានសិស្សប្រឡងស្នាតកបត្រសិល្បៈសរុបចំនួន**១៣៩នាក់**។

ភាពជាដៃគូអភិវឌ្ឍ ជាអាទិភាពពិសេសដែលក្រសួងបានផ្តោតទៅលើការលើកកម្ពស់ បរិស្ថានវិនិយោគ និងការចូលរួមរបស់អង្គការ សង្គមស៊ីវិល ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ការកសាង ថែទាំហេដ្ឋារចនាសម្ព័ន្ធវប្បធម៌ និងអភិវឌ្ឍសកម្មភាពវប្បធម៌។ យើងបានទំនាក់ទំនងជាមួយ UNDP អង្គការ UNESCO និងអង្គការផ្សេងៗទៀតក្នុងការអភិរក្សអភិវឌ្ឍបេតិកភណ្ឌរូបី អរូបី និង មរតកមនុស្សរស់។ សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក៏មានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិបានយ៉ាងល្អប្រសើរ និងកាន់តែបើកទូលាយ ជាក់ស្តែងដូចជាការបង្រៀនភាសាបរទេសបន្ថែមលើមុខវិជ្ជា

បច្ចេកទេសនៅតាមមហាវិទ្យាល័យទៀតផង។ ក្រសួងបានបន្តកិច្ចសហការជាមួយអង្គការ G.H.F និងអង្គការ Waseda ជួសជុលហេដ្ឋារចនាសម្ព័ន្ធប្រាសាទបន្ទាយឆ្មារ និងប្រាសាទសំបូរព្រៃគុក។ ទន្ទឹមនេះនៅមន្ទីរាជធានី-ខេត្ត ក៏បានបង្កើនទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍតាមរយៈអង្គការ និង សង្គមស៊ីវិល ជាក់ស្តែងដូចជាខេត្តប៉ៃលិន ជួសជុលចេតិយបុរាណភ្នំយ៉ាត ខេត្តកំពង់ស្ពឺ បានទំនាក់ទំនងជាមួយអង្គការ ដើម្បីធ្វើការអភិរក្ស អភិវឌ្ឍរមណីយដ្ឋានភ្នំចាស់ និងបណ្តុះបណ្តាលវិជ្ជាជីវៈសិល្បៈក្រៅប្រព័ន្ធដល់សិស្ស កុមារកំព្រានៅតាមមូលដ្ឋានក្នុងខេត្តសរុបមានចំនួន**១៥០នាក់** ក្នុងនោះស្រី**៨០នាក់** និងខេត្តកណ្តាលបានទំនាក់ទំនងជាមួយសប្បុរសជន លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ឧបត្ថម្ភថវិកាសរុបចំនួន១៥.៣៤៦.០០០រៀល សម្រាប់បំរើសេវាកម្មនៅព្រះសត្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ។ ក្រសួងក៏បានធ្វើកិច្ចសហការជាមួយដៃគូអភិវឌ្ឍ ក្នុងការបើកមហោស្រពចម្រៀងខ្មែរសកលលើកទី២ មហោស្រពសិល្បៈមហាជនថ្នាក់ជាតិ និងរៀបចំព្រឹត្តិការណ៍វប្បធម៌ នេះជាការបំផុសស្មារតីចូលរួមសកម្មភាពវប្បធម៌ ដើម្បីអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ។ កិច្ចសហប្រតិបត្តិការវប្បធម៌ យើងបានចុះកិច្ចព្រមព្រៀងរវាងក្រសួង និងស្ថាប័នជាតិ-អន្តរជាតិមួយចំនួនមាន ការចុះអនុស្សារណៈសហប្រតិបត្តិការរវាងបណ្ណាល័យជាតិកម្ពុជា និង បណ្ណាល័យជាតិបារាំង-ចុះហត្ថលេខាបន្តកិច្ចសហប្រតិបត្តិការលើវិស័យវប្បធម៌ កម្ពុជា-វៀតណាម នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះកិច្ចព្រមព្រៀងស្រាវជ្រាវបុរាណវិទ្យារវាងក្រសួង ជាមួយសកលវិទ្យាល័យអូតាហ្គោ ប្រទេសញូហ្សេលេន-ចុះហត្ថលេខាលើគម្រោងថវិកាឧបត្ថម្ភ ការបង្កើតឯកសារភ្លេងប្រពៃណីខ្មែររវាងអង្គការសិល្បៈខ្មែរអមតៈ និង ស្ថានទូតអាមេរិក ប្រចាំកម្ពុជា និង ចុះកិច្ចព្រមព្រៀងគម្រោងរវាងក្រសួង ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។

បង្កើនប្រសិទ្ធភាពការងារ និងសេវា ក្រសួងយកចិត្តទុកដាក់ក្នុងការជម្រុញធ្វើកំណែទម្រង់រដ្ឋបាល និងបានរៀបចំផែនការបើកវគ្គបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពគ្រប់គ្រង សមត្ថភាពជំនាញ និងចូលរួមអនុវត្តគោលនយោបាយ ស្តីពីការផ្តល់សេវាសាធារណៈ។ ការបង្កើនប្រសិទ្ធភាពការងារ ក្រសួងបានដាក់ពង្រាយធនធានមន្ត្រីទៅតាមគ្រប់អង្គភាព និងមន្ទីររាជធានីខេត្ត។ ជាក់ស្តែងក្នុងឆ្នាំនេះ ក្រសួងប្រឡងជ្រើសរើសមន្ត្រីក្របខណ្ឌថ្មីបានចំនួន**៥៦នាក់** និងបានដាក់ពង្រាយតាមគោលដៅរបស់ក្រសួង។ ក្រសួងបានបើកវគ្គផ្តល់ចំណេះប្រតិបត្តិដល់មន្ត្រីរាជការចំនួន២វគ្គគឺ វគ្គផ្តល់សេវាកម្មលើវិស័យវប្បធម៌ និងវគ្គផ្តល់សេវាកម្មលើការងារសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម សរុបសិក្ខាកាមមានចំនួន**១២១នាក់** មកពីនាយកដ្ឋាន និងមន្ទីររាជធានី-ខេត្ត។ ក្រសួងក៏បានពង្រឹងការអនុវត្តយន្តការដែលពាក់ព័ន្ធការផ្តល់សេវាសាធារណៈ ក្នុងគោលបំណងប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជា **"អ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព ជូនប្រជាពលរដ្ឋ"** ។ ក្នុងឆ្នាំនេះយើងបាន ផ្តល់សេវាកម្មលើការងារមានៈសិល្បៈភាពយន្តបានផ្តល់អាជ្ញាប័ណ្ណថតភាពយន្តបរទេសចំនួន**២៦ផលិតកម្ម** និងបានផ្តល់ទិដ្ឋាការបញ្ចាំងខារាអូខេខ្មែរ បញ្ចាំងរឿងខ្មែរ រឿងបរទេស ស្ពតផ្សាយពាណិជ្ជកម្មសរុបចំនួន**២៣០ចំណងជើង**។ ផ្តល់អាជ្ញាប័ណ្ណការពារស្នាដៃ សិទ្ធិអ្នកនិពន្ធចំនួន**៤៦ស្នាដៃ** និងផ្តល់អាជ្ញាប័ណ្ណនាំវត្ថុសិល្បៈចេញក្រៅប្រទេសមានចំនួន**៥.៦៩២រូប**។ ទន្ទឹមនេះនៅមន្ទីររាជធានី-ខេត្ត ដែលបានរៀបចំការងារច្រកចេញចូល ក៏បានចូលរួមយ៉ាងសកម្មក្នុងការបម្រើសេវាកម្មច្រកចេញចូលតែមួយលើវិស័យវប្បធម៌ ទទួលលទ្ធផលវិជ្ជមាន ជាក់ស្តែងដូចជាខេត្តបាត់ដំបង បានផ្តល់សេវាកម្មសរុបចំនួន**១៣០សេវា** ខេត្តកំពង់ធំ ផ្តល់សេវាសរុបចំនួន**១២០សេវា** ខេត្តសៀមរាបចំនួន**១៧៧សេវា** និងខេត្តកណ្តាលចំនួន**៣៣៤សេវា** ។

២.ថែរក្សា ការពារ អភិវឌ្ឍតំបន់បេតិកភណ្ឌ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិ :

ការថែរក្សា ការពារបេតិកភណ្ឌ អង្គភាពជំនាញ ក៏ដូចជាមន្ទីររាជធានី-ខេត្ត មានឆន្ទៈម្ចាស់ការខ្ពស់ក្នុងការគ្រប់គ្រងវត្ថុបុរាណ នៅក្នុង និងក្រៅឃ្លាំង ទួលបុរាណ ប្រាសាទ ស្រះ ត្រពាំងបុរាណ រមណីយដ្ឋានប្រវត្តិសាស្ត្រ និងទប់ស្កាត់ការជីកកកាយស្ថានីយ រំលោភយកដីក្នុងដែនការពារបេតិកភណ្ឌ។ ការងារនេះយើងបានបំពេញភារកិច្ចក្នុងការចុះបញ្ជីបេតិកភណ្ឌក្នុងខេត្តរបស់ខ្លួន បោះបង្គោលកំណត់ទីតាំងដែនការពារ និងបានធ្វើប័ណ្ណកម្មសិទ្ធិទួលបុរាណជាសម្បត្តិវប្បធម៌ជាតិ។ ជាក់ស្តែងដូចជាមន្ទីរវប្បធម៌ខេត្តបាត់ដំបង បានកំណត់ចុះបញ្ជីទួលបុរាណចំនួន៦៧ទួល ទទួលកម្មសិទ្ធិទួលបុរាណជាសម្បត្តិរដ្ឋបាន២០ទួល។ ក្រសួងបានរៀបចំក្រុមការងារចុះសង្គ្រោះបន្ទាន់នៅប្រាសាទកំពង់ព្រះ ខេត្តកំពង់ឆ្នាំង ដែលទទួលរងការជីកដាំបង្គោលប្រព័ន្ធទូរស័ព្ទចល័តនៅលើទីតាំងប្រាសាទ ដោយយើងបានជីកដកបង្គោលចេញ ហើយយើងក៏បានបន្តធ្វើកំណាយស្តារស្ថានីយនៅទីនោះសម្រេចជាស្ថាពរ ព្រមទាំងបានកំណត់ទីតាំងប្រាសាទកំពង់ព្រះ ជាស្ថានីយបុរាណ និងជារមណីយដ្ឋានប្រវត្តិសាស្ត្រ។ ចំពោះការងារអភិរក្សបេតិកភណ្ឌនៅតាមខេត្តជាគោលដៅនោះ ក្រសួងបានរៀបចំការិយាល័យអភិរក្ស នៅតំបន់មួយចំនួនមានៈ ការិយាល័យអភិរក្សកំពង់ធំ និងព្រះវិហារ និងការិយាល័យអភិរក្សបាត់ដំបង-បន្ទាយមានជ័យ និង ឧត្តរមានជ័យ ការរៀបចំអភិរក្សដ្ឋាននេះ ដើម្បីធានាប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការអភិរក្ស អភិវឌ្ឍបេតិកភណ្ឌនៅក្នុងតំបន់។ នៅសារមន្ទីរជាតិ យើងបានជួសជុលវត្ថុបុរាណបានចំនួន២២៥រូប ដើម្បីទុកតាំងបង្ហាញបម្រើសេវាកម្មភ្ញៀវទេសចរណ៍។

ការអភិវឌ្ឍតំបន់បេតិកភណ្ឌ កិច្ចការនេះកន្លងមកក្រសួងបានកំណត់តំបន់ពីរ ជាគោលដៅអភិវឌ្ឍគឺ ប្រាសាទបន្ទាយឆ្មារ និងតំបន់ប្រាសាទសំបូរព្រៃគុក ដែលបច្ចុប្បន្នមន្ត្រីជំនាញបានសិក្សារៀបចំឯកសារប្លង់មេ ដើម្បីឈានទៅអភិវឌ្ឍជាតំបន់ទេសចរណ៍វប្បធម៌នាពេលខាងមុខ។ ការងារនេះនៅមន្ទីររាជធានី-ខេត្ត ក៏បានខិតខំទំនាក់ទំនងអភិវឌ្ឍបេតិកភណ្ឌនៅមូលដ្ឋានរបស់ខ្លួនដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ ជាក់ស្តែងដូចជាការជួសជុលកែលម្អរមណីយដ្ឋានវត្តភ្នំ (រាជធានីភ្នំពេញ) រមណីយដ្ឋានទួលបារាយណ៍អណ្តែត (ខេត្តព្រៃវែង) រមណីយដ្ឋានភ្នំចាស់ និងទួលគុហារមានឫទ្ធិ (ខេត្តកំពង់ស្ពឺ)។ ទន្ទឹមនេះមន្ត្រីជំនាញក៏បានចុះសិក្សាស្រាវជ្រាវភូមិសាស្ត្រទីតាំងប្រាសាទព្រះខ័នកំពង់ស្វាយ ដើម្បីត្រៀមអភិវឌ្ឍជាតំបន់ទេសចរណ៍វប្បធម៌នាពេលអនាគត។

ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ វិស័យបេតិកភណ្ឌចាត់ទុកជាប្រភពធនធានវប្បធម៌ ដែលមានសក្តានុពលមិនចេះរីងស្ងួតសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចជាតិ។ តាមរយៈសារមន្ទីរជាតិ អាចរកចំណូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិបានជារៀងរាល់ឆ្នាំ ជាក់ស្តែង ឆ្នាំនេះយើងទទួលថវិកាពីការបម្រើសេវាកម្មលក់សំបុត្រចូលទស្សនាវត្ថុសិល្បៈបុរាណមានចំនួន**១៤.៣៤០.០០០រៀល** និង**២៦៩.៦២២ដុល្លាអាមេរិក** និងយើងបានទទួលថវិកាពីការផ្តល់អាជ្ញាប័ណ្ណនាំចេញ-នាំចូលវត្ថុសិល្បៈអនុស្សាវរីយ៍មានចំនួនសរុប**៤០.០១១.០០០រៀល** បើប្រៀបធៀបឆ្នាំកន្លងមកឃើញថា សរុបចំណូលមានការកើនឡើង១,៥ភាគរយ។

<u>៣.ជម្រុញឱ្យកម្ពុជាក្លាយជាមជ្ឈមណ្ឌលផ្សព្វផ្សាយសិល្បៈទស្សនីយភាព :</u>

ក្រសួងបានរៀបចំបើកមហោស្រពសិល្បៈមហាជនទូទាំងប្រទេស ជាការអនុវត្តនយោបាយអភិរក្ស និងអភិវឌ្ឍវប្បធម៌ ជាការបំផុសឱ្យបង្កើតស្នាដៃថ្មី និងជាការតម្រង់ទិស កែលម្អទម្រង់សិល្បៈមហាជនឱ្យរក្សាបានខ្ចាតត្រឹមត្រូវ ដើម្បីធានាបរិមាណគុណភាពដល់ការសម្តែងបម្រើប្រជាជន។ ទន្ទឹមនេះ លោកគ្រូ អ្នកគ្រូ សិល្បករនៅអង្គភាពជំនាញ និងមន្ទីររាជធានី-ខេត្ត បាន

យកចិត្តទុកដាក់ក្នុងការចុះជួយបណ្តុះបណ្តាល បង្ហាត់បង្រៀន ពង្រឹងជំនាញសិល្បៈក្រៅប្រព័ន្ធ នៅតាមគ្រឹះស្ថានសិក្សា និងនៅសង្គមស៊ីវិលបានជាច្រើនវគ្គទៀតផង។

ការប្រគុំតន្ត្រី និងសម្តែងសិល្បៈ (មហាជន និងអាជីព) នៅតាមបណ្តារាជធានី-ខេត្ត មានសកម្មភាពជារៀងរាល់ពេលតាមរដូវកាល ក្នុងការចេញសម្តែង និងប្រគុំបម្រើទៅតាមសំណូមពររបស់អតិថិជនក្នុងពិធីបុណ្យទានផ្សេងៗ-រៀបមង្គលការសម្តែងបម្រើការងារពាណិជ្ជកម្ម និងបម្រើព្រឹត្តិការណ៍ជាតិ-អន្តរជាតិ ធ្វើឱ្យទស្សនិកជនជាតិ-អន្តរជាតិមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើបច្ចេកទេសសម្តែង-ដឹកនាំរឿង ឃើញថាមានកម្រិតខ្ពស់។ ក្រសួងក៏សូមកោតសរសើរ ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមសិល្បៈមហាជន និងសង្គមស៊ីវិល ដែលបានចូលរួមបម្រើសកម្មភាពសិល្បៈ និងខិតខំថែរក្សាគ្រប់ទម្រង់សិល្បៈទស្សនីយភាព ពិសេសទម្រង់ល្ខោនបាសាក់ដែលបានធ្វើសកម្មភាពផ្សព្វផ្សាយនៅតាមមូលដ្ឋាន ធ្វើឱ្យប្រជាជនមានការគាំទ្រយ៉ាងខ្លាំង។

ការផ្សព្វផ្សាយជារួមយើងឃើញថា អង្គភាពជំនាញ ក្រុមសិល្បៈមហាជន និងសង្គមស៊ីវិលបានបង្កើនការផលិតស្នាដៃសិល្បៈតាមគ្រប់រូបភាព ដើម្បីសហការបម្រើសកម្មភាពសម្តែងនៅតាមប្រព័ន្ធឃោសនាផ្សព្វផ្សាយ ពិសេសតាមរយៈស្ថានីយទូរទស្សន៍។ នេះជាមធ្យោបាយមួយដ៏ល្អប្រសើរ ក្នុងការផ្សព្វផ្សាយសិល្បៈទស្សនីយភាព បានទៅដល់គ្រប់មូលដ្ឋានក្នុងប្រទេស និងក្រៅប្រទេសទៀតផង។

<u>៤.ជម្រុញកម្ពុជា ជាគោលដៅនៃការថតភាពយន្ត :</u>

ក្រសួងមានក្រុមការងារមួយ ដោយមានយន្តការសម្របសម្រួលក្នុងការផ្តល់សេវាកម្មលើការថតខ្សែភាពយន្ត ព្រោះការថតភាពយន្តគឺជាសិទ្ធិរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាអ្នកផ្តល់អាជ្ញាប័ណ្ណ។ ក្រសួងបានបន្តផ្សព្វផ្សាយគ្រប់រូបភាពអំពីសម្បត្តិបេតិកភណ្ឌវប្បធម៌មាន រមណីយដ្ឋានវប្បធម៌ និងធម្មជាតិ។ ក្រសួងក៏បានខិតខំទំនាក់ទំនងរកឧបករណ៍ សម្ភារៈបច្ចេកទេសបានមួយចំនួនដើម្បីត្រៀមទុកបម្រើផលិតកម្មបរទេសមកថតក្នុងស្រុក។ យើងបានបន្តបើកវគ្គខ្លី បណ្តុះបណ្តាលបច្ចេកទេសភាពយន្តបាន៣វគ្គ មានសិក្ខាកាមសិក្សាសរុបចំនួន៣០នាក់។ ក្រសួងបានបង្កើនកិច្ចសហការគ្រប់ស្ថាប័នពាក់ព័ន្ធ មន្ទីរវប្បធម៌រាជធានី-ខេត្ត អាជ្ញាធរមូលដ្ឋាន ដើម្បីបម្រើសេវាកម្មថតភាពយន្ត។ ដើម្បីសុវត្ថិភាពក្នុងការថតភាពយន្ត ក្រសួងបានបន្តសហការជាមួយ CMAC បោសសំអាតយុទ្ធភណ្ឌមិនទាន់ផ្ទុះ នៅតំបន់ប្រាសាទ និងស្ថានីយបុរាណ។ ទន្ទឹមនេះ មន្ត្រីជំនាញបេតិកភណ្ឌក៏បានសិក្សាប្លង់មេ នៅរមណីយដ្ឋានវប្បធម៌មួយចំនួន និងនៅតាមប្រាសាទឱ្យមានខ្សែទស្សនាចរណ៍ សម្រាប់ការថតភាពយន្ត ដោយរៀបចំបរិស្ថានជុំវិញប្រាសាទ រមណីយដ្ឋាន និងបានបោះបង្គោលកំណត់ដែនដីការពារ ងាយស្រួលដល់ការថតភាពយន្ត។ ជាគោលដៅនៃការថតភាពយន្ត ឃើញថាឆ្នាំនេះ យើងបានទទួលក្រុមថតភាពយន្តបរទេសចំនួន២៦ផលិតកម្ម។ យើងក៏បានអនុញ្ញាតច្បាប់ឱ្យផលិតកម្មក្នុងស្រុកថតវីដេអូខារ៉ាអូខេខ្មែរបាន៩១លេខ-ថតរឿងខ្មែរបាន២១ចំណងជើង និងរឿងភាគ០៤ចំណងជើង។

<u>៥.ជម្រុញកម្ពុជា ជាកន្លែងផ្សព្វផ្សាយផលិតផលសិល្បៈសូនរូប និងសិល្បៈសិប្បកម្មខ្មែរ :</u>

យើងបានសិក្សាស្រាវជ្រាវ ចងក្រងឯកសារខ្នាតសិល្បៈសូនរូប និងសិល្បៈសិប្បកម្មទៅតាមរចនាបថខ្មែរ ដើម្បីរៀបចំបោះពុម្ពផ្សព្វផ្សាយជាក្បួនខ្នាតសម្រាប់កំណត់បទដ្ឋានបច្ចេកទេស។ ការពង្រឹងពង្រីកបច្ចេកទេស មន្ត្រីជំនាញ និងមន្ទីររាជធានី

ខេត្តបានបង្កើនការងារគ្រប់គ្រង និងធ្វើការផ្សព្វផ្សាយ បណ្តុះបណ្តាល កែលម្អដល់សិប្បកម្មអាជីវកម្ម សាលាវិជ្ជាជីវៈផលិតវត្ថុសិល្បៈនៅទូទាំងប្រទេស សំដៅលើកស្ទួយឱ្យសិល្បៈសូនរូបរក្សាសោភ័ណភាព-ខ្នាត-ពណ៌សម្បុរ និងអត្តសញ្ញាណខ្មែរ។ ក្រសួងបានបន្តកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអង្គការ សង្គមស៊ីវិល ដែលកំពុងធ្វើសកម្មភាពលើវិស័យសិល្បៈសូនរូប-សិប្បកម្ម និងបានសហការជាមួយគណៈកម្មការជាតិជម្រុញភូមិ១ ផលិតផល១ ដើម្បីផ្តល់លិខិតបញ្ជាក់ទទួលស្គាល់ផលិតផល។ ជាក់ស្តែងយើងបានសហការជាមួយUNDP អង្គការ UNESCO ចុះផ្សព្វផ្សាយអំពីការងារសិល្បៈសូនរូប-សិប្បកម្ម និង សហការជាមួយសង្គមស៊ីវិលរៀបចំតាំងពិព័រណ៍បង្ហាញស្នាដៃដែលមានទេពកោសល្យជូនសាធារណជនសិក្សាស្វែងយល់ពីផលិតផលវប្បធម៌ខ្មែរ។ ជារួមយើងឃើញថាក្នុងឆ្នាំនេះ ក្រសួងបានផ្តល់អាជ្ញាប័ណ្ណដល់ការនាំចេញវត្ថុសិល្បៈសូនរូប(វត្ថុអនុស្សាវរីយ៍) ទៅក្រៅប្រទេសមានចំនួន**៥.៩០៣រូប** នេះជាការលើកទឹកចិត្តដល់វិស័យឯកជន ដែលបានចូលរួមជម្រុញផលិតផលសិល្បៈសូនរូប ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាលគឺ **រដ្ឋគាំទ្រ ដៃគូឯកជនជាអ្នកអនុវត្ត** ។

ទន្ទឹមនឹងសកម្មភាពការងារយើងសម្រេចបានខាងលើនេះ នៅគ្រប់អង្គភាព និងមន្ទីររាជធានី-ខេត្ត បានខិតខំប្រមូលផ្តុំផ្តុំឡើងវិញ នូវរាល់បណ្តាស្នាដៃ លើកតម្កើងតម្លៃវប្បធម៌ ជំនឿទំនៀមទម្លាប់ ប្រពៃណីរបស់សង្គមជាតិ បំផុសការបង្កើតស្នាដៃ និងបង្កើនការផ្សព្វផ្សាយ ដើម្បីធ្វើការអភិរក្ស និងអភិវឌ្ឍសកម្មភាពវប្បធម៌ជាតិ។ ការងារនេះយើងបានបន្តធ្វើការសិក្សាស្រាវជ្រាវចងក្រង និងថែរក្សានូវសកម្មភាពវប្បធម៌មហាជន និងទំនៀមទម្លាប់ប្រពៃណីល្អៗក្នុងសង្គម ជាពិសេសប្រពៃណីទំនៀមទម្លាប់ និងសិល្បៈវប្បធម៌របស់ជនជាតិភាគតិច និងជនជាតិដើមភាគតិចនៅកម្ពុជា ដោយក្រសួងបានបំពេញភារកិច្ចលើការងារមួយចំនួនមានជាអាទិ៍គឺ :

-បានសិក្សាគូរប្លង់ផ្ទះតាមរចនាបថខ្មែរជាគំរូមានចំនួន១៨ប្លង់ផ្សេងៗគ្នា សម្រាប់ឱ្យប្រជាជនសាងសង់នៅក្នុងតំបន់អភិវឌ្ឍប្រាសាទបន្ទាយឆ្មារ

-សិក្សាស្រាវជ្រាវអំពីក្បាច់គុនបុរាណខ្មែរពីមហាជន ដើម្បីរៀបចំបទដ្ឋានត្រៀមសុំចុះបញ្ជីជាសម្បត្តិបេតិកភណ្ឌអរូបីនៃមនុស្សជាតិ

-មន្ទីរខេត្តរតនគិរី បានសិក្សាស្រាវជ្រាវពីវប្បធម៌ជនជាតិភាគតិច ដោយបានចងក្រងថតវីដេអូ និងកាត់តរូបភាពធ្វើជាថាសទុកជាឯកសារ អំពីរបាំជនជាតិភាគតិចបាន១៣របាំ ធ្វើជាថាសអំពីពិធីរបាំកាប់ក្របី និងរបាំចម្រុះជនជាតិភាគតិចសរុបបាន២៣របាំ។ បានសិក្សាស្រាវជ្រាវ អំពីពិធីសែនចំការរបស់ជនជាតិទំពួន ដើម្បីចងក្រងទុកជាឯកសារ

-ក្នុងការបំផុសបង្កើតស្នាដៃសិល្បៈមហាជន ដើម្បីផ្សព្វផ្សាយ និងអភិវឌ្ឍសកម្មភាពវប្បធម៌ ក្រសួងបានធ្វើសេចក្តីជូនដំណឹង ស្តីពីការបើកមហោស្រពសិល្បៈមហាជនថ្នាក់ជាតិ-មហោស្រពចម្រៀងខ្មែរសកលលើកទី២ថ្នាក់ជាតិ និងការបើកមហោស្រពខ្លែងខ្មែរ។ ជាលទ្ធផលយើងទទួលបានក្រុមសិល្បៈមហាជន និងមហាជនចូលរួមបញ្ចេញស្នាដៃសិល្បៈយ៉ាងច្រើនកុះករ ដោយបានទទួលលទ្ធផលជោគជ័យតាមកម្មវិធីគ្រោងទុក។ ក្នុងការជម្រុញ និងលើកស្ទួយការតែងនិពន្ធមហាជន ក្រសួងបានចេញសេចក្តីជូនដំណឹង ស្តីពីការប្រឡងជ្រើសរើសស្នាដៃតែងនិពន្ធប្រលោមលោក-កំណាព្យ សម្រាប់ពានរង្វាន់ប្រចាំឆ្នាំ២០១១ ដោយបានផ្សព្វផ្សាយទូទាំងប្រទេស (ត្រៀមប្រកាសលទ្ធផល នៅឆ្នាំ២០១២)។

ផ្អែកតាមលទ្ធផលខាងលើនេះ យើងនៅមានសកម្មភាពការងារជាច្រើនទៀតរបស់អង្គភាព និងមន្ទីររាជធានីខេត្តបាន អនុវត្តទៅតាមភារកិច្ចជាប្រចាំ ដោយទទួលលទ្ធផលជាវិជ្ជមាន។

ជារួមយើងឃើញថា រយៈពេលមួយឆ្នាំនេះ លទ្ធផលសកម្មភាពការងារវិស័យវប្បធម៌ បើប្រៀបធៀបទៅនឹងផែនការឆ្នាំ យើងសម្រេចបាន៨០ភាគរយ ចំពោះការងារ២០ភាគរយទៀតដែលនៅសេសសល់គឺ បន្តអនុវត្តនៅឆ្នាំ២០១២ ។

**១០.បញ្ហាប្រឈម :**

ការប្រឈមចំពោះមុខដែលត្រូវដោះស្រាយនៅឆ្នាំ២០១២មានជាអាទិ៍គឺ :

**១-ធនធានមនុស្ស :**

-ធនធានមនុស្សមិនទាន់បានពង្រាយ ឆ្លើយតបទៅតាមសំណូមពរនៃការងារ ដោយការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មីមាន ចំនួនកំណត់

-ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៅមានកម្រិត ពិសេសមន្ត្រីនៅតាមមន្ទីររាជធានី-ខេត្ត

-សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ការបណ្តុះបណ្តាលមានការខ្វះសាលសម្តែងរួមសម្រាប់តន្ត្រី និងសិល្បៈនាដសាស្ត្រ ខ្វះបន្ទប់សិក្សា បន្ទប់ពិសោធន៍ ខ្វះសម្ភារៈសិក្សាស្រាវជ្រាវ និងខ្វះសាស្ត្រាចារ្យជាន់ខ្ពស់

-សាលាមធ្យមវិចិត្រសិល្បៈ ក៏មានការជួបប្រទះបញ្ហាគ្រូជំនាញ ដោយសព្វថ្ងៃលោកគ្រូ អ្នកគ្រូកាន់តែមានវ័យចំណាស់ និងត្រូវចូលនិវត្តន៍ ហើយសាលាជំនាញទាំង៥ ក៏មានការខ្វះខាតយ៉ាងខ្លាំងលើសម្ភារៈឧបទ្ទេស និងសម្ភារៈសិក្សា ។

**២-ការងាររដ្ឋបាល :**

-ការសម្របសម្រួលលិខិតរដ្ឋបាលមួយចំនួនមិនទាន់រលូនសមស្របតាមការងារច្រកចេញចូលតែមួយ នៅខ្វះចន្លោះជាអន្លើៗ

-ប្រសិទ្ធភាពក្នុងការផ្តល់សេវាវិស័យវប្បធម៌តាមផ្នែកជំនាញ មិនទាន់បានបម្រើទៅតាមសំណូមពរនៃតួនាទីភារកិច្ច

-លិខិតបទដ្ឋានគតិយុត្ត ជាកត្តាកំណត់ក្នុងការពង្រឹងពង្រីកសមត្ថភាពស្ថាប័ន យើងមានការខ្វះខាតជាច្រើនដូចជា ច្បាប់ ព្រះរាជក្រឹត្យ-អនុក្រឹត្យ សម្រាប់គ្រប់គ្រងលើផ្នែកជំនាញ នៃវិស័យវប្បធម៌

-យើងអនុវត្តមិនទាន់បានល្អប្រសើរក្នុងកិច្ចសហការជាមួយដៃគូអភិវឌ្ឍ និងផ្នែកឯកជន សំដៅធ្វើការគៀងគរធនធានទាំងធនធានហិរញ្ញវត្ថុ-សម្ភារៈ និងធនធានមនុស្ស ដើម្បីរួមចំណែកធ្វើបច្ចុប្បន្នភាពហេដ្ឋារចនាសម្ព័ន្ធវប្បធម៌ និងសមត្ថភាពស្ថាប័នឱ្យបានរឹងមាំ ជឿនលឿន ស្របនឹងការរីកចម្រើនក្នុងតំបន់ និងពិភពលោក។

**៣-ការងារបេតិកភណ្ឌរូបី :**

-ប្រាសាទមួយចំនួនធំកំពុងទទួលរងនូវការសឹករិចរិលដោយធម្មជាតិ-បន្សល់ការបែកបាក់ ដោយជនល្មើសបំផ្លាញ និងមានសភាពទ្រុឌទ្រោមចាស់ជរា ដោយសារអាយុកាលនៃប្រាសាទទាំងនោះ

-បេតិកភណ្ឌវប្បធម៌រូបី ឃើញថាបានទទួលរងនូវការរំលោភយកដីប្រាសាទ-ទួលបុរាណ-ស្រះត្រពាំងបុរាណ-ការឈូសឆាយទន្រ្ទានកាន់កាប់ស្ថានីយ៍បុរាណ-ការសាងសង់សំណង់រឹងមាំ និងមានការចូលកាប់ឈើក្នុងដែនការពាររមណីយដ្ឋានប្រាសាទ

-ការសង់សំណង់អាគារ-គេហដ្ឋានមួយចំនួននៅរាជធានី-ខេត្ត មានការជីកបុកគ្រឹះសាងសង់នោះ តែងតែជួបប្រទះប៉ះចំលើស្ថានីយ៍បុរាណវិទ្យា នេះជាផលប៉ះពាល់មួយដែលអង្គភាពជំនាញកំពុងរិះរកវិធានការទប់ស្កាត់

-ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបេតិកភណ្ឌវប្បធម៌ ដែលជាគ្រឹះនៃរមណីយដ្ឋានទេសចរណ៍វប្បធម៌ និងរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ មិនទាន់ដំណើរការបានតាមសំណូមពរនៃផែនការក្រសួង

-វត្ថុបុរាណយើងសំបូរបែប ប៉ុន្តែយើងខ្វះការពង្រឹងទីតាំងថែរក្សា ការពារ និងតាំងបង្ហាញជូនភ្ញៀវទេសចរណ៍ សារមន្ទីរតាមខេត្តមិនទាន់មានដំណើរការល្អនៅឡើយ

-ការងារបុរាណវិទ្យា មិនទាន់សម្រេចបានការសុំបញ្ចូលស្ថានីយ៍បុរាណ និងរមណីយដ្ឋានប្រវត្តិសាស្ត្រចូលជាសម្បត្តិបេតិកភណ្ឌវប្បធម៌ជាតិឱ្យបានទាន់ពេលវេលានៅឡើយ

-ការបញ្ជ្រាបឯកសារ លិខិតបទដ្ឋានពាក់ព័ន្ធការងារបេតិកភណ្ឌមិនទាន់បានផ្សព្វផ្សាយចូលជ្រៅដល់ប្រជាពលរដ្ឋតាមមូលដ្ឋានក្រុង-ស្រុក នៅខេត្តជាតំបន់អាទិភាព

-ការពង្រឹងសមត្ថភាពមន្ត្រីបេតិកភណ្ឌនៅតាមមន្ទីរវប្បធម៌នៅមានកម្រិត មិនទាន់ស៊ីជម្រៅឱ្យបានគ្រប់ជ្រុងជ្រោយ ។

**៤-ការងារបេតិកភណ្ឌអរូបី ៖**

ក.ការងារសិល្បៈទស្សនីយភាព ៖

-ការតែងនិពន្ធ តម្លើងស្នាដៃថ្មី សម្រាប់សិល្បៈបម្រើការផ្សព្វផ្សាយ យើងមិនទាន់សំបូរបែបគ្រប់ទម្រង់ក្នុងការសម្តែង

-ការកសាងកម្មវិធីសម្តែងជាប្រចាំសម្រាប់ភ្ញៀវទេសចរណ៍ទស្សនានៅរាជធានី និងនៅតំបន់មានសក្តានុពលទេសចរណ៍មិនទាន់អនុវត្តឱ្យបានទូលំទូលាយ និងមានកម្មវិធីច្បាស់លាស់សម្រាប់បម្រើសេវាកម្ម

-ការជួយបង្ហាត់ពង្រឹងគុណភាពសិល្បៈមហាជន នៅតាមមូលដ្ឋានមិនទាន់ចុះបានទៀងទាត់ជាប្រចាំនៅឡើយ

-ការឃោសនា ផ្សព្វផ្សាយ តាមគ្រប់ប្រព័ន្ធព័ត៌មាន នៅមានកម្រិតនៅឡើយ ។

យើងនៅមានបញ្ហាមួយចំពោះមន្ទីររាជធានី-ខេត្ត ការគ្រប់គ្រងក្រុមសិល្បៈមហាជន ក្នុងការចេញប្រគុំសម្តែង គឺមិនទាន់គ្រប់គ្រងបាននូវចំនួននៃការចេញប្រគុំសម្តែងបានប៉ុន្មានលើកក្នុងមួយខែឱ្យបានច្បាស់លាស់ឡើយ ជាហេតុធ្វើឱ្យក្រសួងមានការលំបាកក្នុងការផ្តល់របាយការណ៍ជូនទៅស្ថាប័នពាក់ព័ន្ធ ។

ខ.ការងារសិល្បៈភាពយន្ត ៖

-ក្នុងការប្រែក្លាយកម្ពុជា ជាដែនដីស្វាគមន៍នៃការថតភាពយន្តបរទេស យើងនៅមានបញ្ហាប្រឈមជាច្រើនដូចជាធនធានមនុស្ស-កម្រិតបច្ចេកទេសនៅទាប និងឧបករណ៍សម្ភារៈ មិនទាន់ឆ្លើយតបបានទាំងស្រុងទៅនឹងការថតភាពយន្តបរទេស

-ការផ្សព្វផ្សាយពីសក្តានុពលវប្បធម៌ ជាការទាក់ទាញអ្នកថតភាពយន្តបរទេស យើងធ្វើការឃោសនានៅមានកម្រិតទាបនៅឡើយ ដោយមិនទាន់បានធ្វើទូលំទូលាយជាប្រចាំ នៅតាមប្រព័ន្ធផ្សព្វផ្សាយ ពិសេសតាមស្ថានីយទូរទស្សន៍

-ការបង្ក្រាបបទល្មើសភាពយន្ត-វីដេអូឃើញថា យើងអនុវត្តទៅលើអ្នកប្រព្រឹត្តខុសច្បាប់លើមូលដ្ឋានធំៗ ទទួលបានលទ្ធផលជាវិជ្ជមាន ប៉ុន្តែបញ្ហាប្រឈមមួយទៀតនោះគឺ បច្ចុប្បន្នជនល្មើសបានធ្វើការចែកផ្សាយថាសខុសច្បាប់ដោយប្រើរូបភាពចល័តតាមរយៈអ្នកលក់ជាយុវជន និងកុមារ ដោយដើរលក់តាមទីប្រជុំជន ភោជនីយដ្ឋាន និងហាងផឹកស៊ី ។

គ.ការងារសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ៖

-ការចុះផ្សព្វផ្សាយអំពីសិល្បៈសូនរូប និងសិល្បៈសិប្បកម្មខ្មែរមានរូបភាពឱ្យកាន់តែសម្បូរបែប និងប្រកបដោយគុណភាពនោះ យើងអនុវត្តនៅមានកម្រិត មិនទាន់បានទូលំទូលាយដល់ទីតាំងមូលដ្ឋាននៅខេត្តឆ្ងាយៗ

-ការចងក្រងឯកសារជាសៀវភៅបម្រើការងារចម្លាក់ក្បាច់ខ្មែរ សម្រាប់កំណត់បទដ្ឋានបច្ចេកទេស មិនទាន់បានបោះពុម្ពផ្សាយឱ្យសំបូរបែបនៅឡើយ

-ក្នុងការតម្រង់ទិស បំផុសបង្កើតស្នាដៃ យើងមិនទាន់អនុវត្តបានទៀងទាត់ តាមរយៈការបើកមហោស្រព ការប្រឡងស្នាដៃ និងការតាំងពិព័ណ៌

-នៅមន្ទីរវប្បធម៌មួយចំនួនមានបញ្ហាលំបាកក្នុងការគ្រប់គ្រងអាជីវកម្មសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ដោយយើងខ្វះខាតបទដ្ឋានគតិយុត្ត ណែនាំឱ្យអាជីវករមកសុំអាជ្ញាប័ណ្ណធ្វើអាជីវកម្ម។

យោងតាមបញ្ហាប្រឈមខាងលើនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សង្ឃឹម នឹងជឿជាក់លើឆន្ទៈម្ចាស់ការរបស់មន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ អង្គការ សង្គមស៊ីវិល អាជ្ញាធរដែនដី និងរួមចំណែកពីស្ថាប័នពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ សូមចូលរួមបន្តអនុវត្តផែនការសកម្មភាពការងារវិស័យវប្បធម៌ឆ្នាំ២០១២ ឱ្យបានសម្រេចលទ្ធផលល្អប្រសើរ ជូនរាជរដ្ឋាភិបាលដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាប្រមុខ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើនេះ សូម **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបជាសេចក្តីរាយការណ៍ដ៏ខ្ពង់ខ្ពស់ ។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**រ ដ្ឋ ម ន្ត្រី**

**ចម្លងជូន :**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ

-គណៈកម្មការអប់រំ ធម្មការ វប្បធម៌ ទេសចរណ៍ ព្រឹទ្ធសភា

-គណៈកម្មការទី ៧ រដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី(នាយកដ្ឋានសរុប )

-ក្រសួងផែនការ ( វិទ្យាស្ថានជាតិស្ថិតិ )

-ក្រុមសង្កេតការសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ទីស្តីការគណៈរដ្ឋមន្ត្រី)

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ឯកសារ-កាលប្បវត្តិ